01386994

E1/500.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៤៨១**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Feb-2017, 14:43
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ហាសាន អាធុរេលិយ៉ា
*(Mr. Harshan ATHURELIYA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គីមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រិុចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡៅ ជុនធី | ខ្មែរ |
| ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-223 | ខ្មែរ |
| លោកស្រី ធុច ស៊ីថន (2-TCW-842) | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖** 2-TCCP-223

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............................................................................ ទំព័រ ៣

សួរដោយលោក ឡោ ជុនធី ផ្ដើមពី............................................................................ ទំព័រ ៥

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ............................................................................ ទំព័រ ១៧

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ធុច ស៊ីថន** (2-TCW-842)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ............................................................................ ទំព័រ ៣៧

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី............................................................ ទំព័រ ៤១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ រួមទាំងថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-223 នៅពេលព្រឹក ហើយនិងស្ដាប់សក្ខីកម្មសាក្សី 2-TCW-842 នៅពេលរសៀល តាមប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកផ្ដល់សក្ខីកម្មនៅព្រឹកនេះ មានរហស្សនាម 2-TCCP-223។ ដើមបណ្ដឹងរដ្ឋប្បវេណីមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ ហើយសាក្សីដែលត្រូវផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំងនៅពេលរសៀលនេះ មានរហស្សនាម 2-TCW-842។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយនៅថ្ងៃនេះមានសាក្សីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCW-871។ សូមអរគុណលោកប្រធាន។

[០៩:០៥:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយ

ផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦។

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យ ព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះរ៉ាំរ៉ៃ វិលមុខពេលអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សុំឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:០៦:៤៨]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

មុននឹងចាប់ផ្ដើមស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-223 អង្គជំនុំជម្រះកត់ស្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានស្ដាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះស្ថិតនៅក្នុងក្រុម “ក” នៃក្រុមទាំងបីប្រភេទ នៅក្នុងអនុស្សរណៈរបស់ខ្លួន (ឯកសារ E319/35) ហើយ

បានស្នើថា ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គួរប្រើប្រាស់រហស្សនាមក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។

[០៩:០៨:០៥]

ហើយអង្គជំនុំជម្រះក៏យល់ឃើញផងដែរថា វិធានការកម្រិតបែបនេះគឺត្រឹមត្រូវ សមស្របតាមច្បាប់ក្នុងករណីជាក់ស្ដែងបែបនេះ។ ហើយការបង្គាប់នេះគឺត្រូវឲ្យមានតុល្យភាពគ្នារវាងការសាធារណភាពនៃសវនាការជាមួយនឹងសុចរិតភាពនៃការស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកភាគីផងដែរថា ឲ្យគោរពខ្ជាប់ខ្ជួននូវសេចក្ដីណែនាំ នៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេងៗ។

ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-223 មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ តាមសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យើងនឹងមិនប្រើប្រាស់ -- យើងនឹងប្រើប្រាស់តែរហស្សនាមរបស់លោកតែប៉ុណ្ណោះ។ ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណីមានរហស្សនាម 2-TCCP-223 ហើយជាធម្មតា ភាគីតែងតែប្រើប្រាស់ ហៅលោកក្នុងនាមលោកដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ អ៊ីចឹងសូមលោកយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះខ្លួនឯងប្រើនាមត្រកូល និងនាមខ្លួនលោកជាសាធារណៈនៅក្នុងសវនាការនេះឡើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការយកឯកសារ E3/9477 យកទៅជូនលោកដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យលើចំណុចដែលមាន *ហាយឡាយ*ពណ៌ទឹកក្រូច។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:១២:០៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តទៅនេះអង្គជំនុំជម្រះសូមឲ្យលោកបញ្ជាក់អំពីអត្តសញ្ញាណរបស់លោកដែលមានសរសេរនៅក្នុង E3/9477 មានលេខ ERN ជាភាសាខ្មែរ 00990857, ERN ជា

ភាសាអង់គ្លេស 01034080 និងភាសាបារាំងមានលេខ ERN 01112104។ ហើយសូមដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យមើលកន្លែងដែលមាន *ហាយឡាយ*ពណ៌ទឹកក្រូច ថាតើនាមខ្លួន នាមត្រកូល សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធ និងចំនួនកូនរបស់លោកពិតជាត្រឹមត្រូវដែរឬទេ ការសរសេរនេះ?

ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណីគ្រាន់តែឆ្លើយថាព័ត៌មានទាំងនេះពិតជាត្រឹមត្រូវ ឬមិនត្រូវបានហើយ។ ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យមើល តើព័ត៌មាននៅក្នុងឯកសារនេះត្រឹមត្រូវដែរឬទេ នូវចំណុចដែល បណ្ដាចំណុចដែលមាន *ហាយឡាយ*ពណ៌ទឹកក្រូចនោះ?

2-TCCP-223៖

**ឆ៖** ត្រឹមត្រូវ។

[០៩:១៣:២១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសូមទុកឯកសារនុំងម៉ុំចុះអ៊ីចឹងណា៎។ បាទ ដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះកោះអញ្ជើញលោកមកផ្ដល់សក្ខីកម្មថ្ងៃនេះ ក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ ហេតុដូច្នេះនៅចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោក លោកអាចមានសិទ្ធិធ្វើសេចក្ដីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម គឺមានន័យថា ជាផលអន្តរាយដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ បាទ នេះលើកក្រោយ ជាចុងក្រោយ យើងនឹងរំឭកលោកសាជាថ្មីម្ដងទៀត។

ហើយក្នុងការសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយមេធាវីនាំមុខ រួមទាំងសហ តំណាងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគី។ សូម មេធាវីនាំមុខសូម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អនុញ្ញាតលោកប្រធាន អនុញ្ញាតឲ្យលោកមេធាវី ឡោ ជុនធី ដើម្បីសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

[០៩:១៥:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកមេធាវី ឡោ ជុនធី!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំបាទ សូមគោរពអង្គជំនុំជម្រះ សូមគោរពភាគីទាំងអស់។ ហើយខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ហើយជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** នៅពេលនេះខ្ញុំបាទ សូមជម្រាបសួរសំណួរពាក់ព័ន្ធនឹងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនេះ ក្នុងអំឡុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ទៅដល់ថ្ងៃ០៦ មករា ឆ្នាំ១៩៧៩។ សូមលោកដើមបណ្តឹងរដ្ឋប្បវេណីជម្រាបទៅអង្គជំនុំជម្រះនៅពេលនេះ ថាតើមុនឆ្នាំ១៩៧៥បន្តិច ថាតើលោករស់នៅកន្លែងណា? ហើយលោកបានប្រកបមុខរបរអ្វី?

**2-TCCP-223៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាប សូមគោរពលោកមេធាវី ខ្ញុំបានរស់នៅក្នុងឆ្នាំ៧៥ គឺនៅក្រោយរំដោះថ្ងៃ១៧ មេសារួច ខ្ញុំនៅសកលវិទ្យាល័យបាត់ដំបង នៅខេត្តបាត់ដំបង។

[០៩:១៦:៤៧]

**ស៖** បាទអរគុណ។ ចំណុចដែលខ្ញុំរំពឹកអម្បាញ់មិញបានន័យថា មុន១៧ មេសា តើនៅៗកន្លែងហ្នឹងដដែលឬមួយនៅកន្លែងណា?

**ឆ៖** មុនថ្ងៃ១៧ មេសា ខ្ញុំនៅ រស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់។

**ស៖** បាទអរគុណ។ ថាតើនៅពេលនោះលោកធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំកាលនោះខ្ញុំនៅជានីរសារ គ្រប់គ្រងខាងទូរលេខ។

**ស៖** បាទអរគុណ។ អ៊ីចឹងក្រោយថ្ងៃ១៧ មេសា លោកបានទៅនៅបាត់ដំបងវិញ ហើយទីតាំង

កន្លែងណាដែរ?

**ឆ៖** ទីតាំងនៅសាកលវិទ្យាល័យបាត់ដំបង។

**ស៖** បាទ ថាតើនៅទីនោះលោកធ្វើអ្វី? ហើយជាមួយនរណាខ្លះ?

**ឆ៖** បាទ កាលនោះខ្ញុំនៅសាកលវិទ្យាល័យ ខ្ញុំមានភារកិច្ចជានីរសារគ្រប់គ្រងអង្គុលីលេខ ទូរលេខ ហើយនិងជួយរៀបចំភ្ញៀវក្នុងស្រុកនៅទីនោះ ហើយរស់នៅជាមួយឈ្មោះ ហម។

**ស៖** បាទអរគុណ។ ថាតើនៅកន្លែងដែលលោករស់នៅហ្នឹង និងធ្វើការហ្នឹងជាស្ថាប័នឈ្មោះអី ដែរ?

**ឆ៖** ជាស្ថាប័ន សម្រាប់ខ្ញុំគឺអ្នកនាំសារ ហើយនិងអ្នកទទួលភ្ញៀវ គឺខ្ញុំយល់បានតែប៉ុណ្ណឹង ព្រោះខ្ញុំ ធ្លាប់ធ្វើនៅហ្នឹងគឺដឹងតែអ៊ីចឹង។

**ស៖** បាទ អរគុណ។ ចំណុចមួយដែលជាមូលហេតុអ្វីដែលលោកបានធ្វើការនៅកន្លែងហ្នឹង?

**ឆ៖** មូលហេតុដែលខ្ញុំធ្វើការនៅកន្លែងហ្នឹង ព្រោះអីខ្ញុំបានចូលរួមធ្វើចលនាមួយគេហៅថា តស៊ូរំដោះប្រទេសនោះឯង បានខ្ញុំមានកិច្ចការងារធ្វើនៅពេលនុ៎ង។

[០៩:២០:៣៩]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសួរដូចអត់ទាន់ច្បាស់ទេ។ សួរគួរតែប្រើប្រាស់កម្រិតអង្គភាព ហើយអង្គភាពហ្នឹង ចំណុះឲ្យនៅកន្លែងណា? កាលណាលោកប្រើពាក្យស្ថាប័ននេះ មនុស្សកម្ពុជា ប្រហែលជាភាគចំនួនតិច ទេដែលអាចចេះដឹងដូចមេធាវីនោះ។ ឥឡូវសួរមិនទាន់ច្បាស់ផង ហើយទៅមុខទៀតវាមិនដឹងថា អង្គ ហេតុហ្នឹងវាកើតឡើងនៅកន្លែងណា?

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** អ៊ីចេះ ដោយសារលោកបានធ្វើការនៅកន្លែងសាកលវិទ្យាល័យបាត់ដំបងហ្នឹង ខ្ញុំចង់ ជម្រាបសួរថាតើកន្លែងសាកលវិទ្យាល័យបាត់ដំបងហ្នឹង គេឲ្យឈ្មោះអីគេកាលដែលលោកបានធ្វើការ នៅទីនោះ? ជាកន្លែងគេឲ្យថាជាមន្ទីរអីសម័យនោះ គេប្រើពាក្យជា “មន្ទីរ” ឬមួយប្រើជាកន្លែងហ្នឹងជា ឈ្មោះអី អង្គភាពអីដែរ?

**2-TCCP-223៖**

**ឆ៖** កាលនោះកន្លែងហ្នឹងគេដាក់ឈ្មោះថា "សាលាបក្ស"។

**ស៖** ហើយតើនៅក្នុងសាលាបក្សហ្នឹង មាននរណាដែលជាមេដឹកនាំកន្លែងហ្នឹង?

**ឆ៖** អង្គាល់នុំងខ្ញុំឃើញលោក វ៉ាញ ដែលគាត់រស់នៅកន្លែងហ្នឹង។

[០៩:២២:២២]

**ស៖** លោក វ៉ាញ ហ្នឹងគាត់មានតួនាទីគ្រប់គ្រងកន្លែងហ្នឹងតែម្តង ឬមួយមាននរណាជាក្រុមការងាររបស់គាត់?

**ឆ៖** កាលនោះលោក វ៉ាញ ទទួលបន្ទុកខាងពាណិជ្ជកម្មក្នុងទីក្រុង និងខេត្តបាត់ដំបងទាំងមូល តែទទួលខុសត្រូវនៅមន្ទីរបក្ស សាកលវិទ្យាល័យហ្នឹងគាត់ជាអ្នករៀបចំ។ នៅពេលដែលភ្ញៀវជាតិកម្មាភិបាលមកពីបណ្តាលខេត្ត -- បណ្តាលស្រុកផ្សេងៗមករៀនសូត្រនៅហ្នឹង ក្រោមគណៈអធិបតីរបស់គណៈភូមិភាគ ឬក៏ក្រោមអធិបតីរបស់លោក នួន ជា អ៊ីចឹងទៅ។

**ស៖** តើនៅពេលនោះ លោកបានលើកឡើងថា មានគណៈភូមិភាគ តើគណៈភូមិភាគហ្នឹងជានរណាដែរ លោកនៅចាំទេ?

**ឆ៖** បាទ គណៈភូមិភាគនោះ ដែលខ្ញុំបានចាំគឺ លោក រស់ ញឹម និងលោក កន ហៅ ក៏។

**ស៖** សូមលោកបញ្ជាក់បន្តិចមើល ថាតើគណៈភូមិភាគហ្នឹងជាភូមិភាគអ្វីដែរ? ភូមិភាគខាងណាដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

[០៩:២៤:១២]

**2-TCCP-223៖**

**ឆ៖** បាទ ពេលនោះ គេហៅថា ភូមិភាគពាយ័ព្យ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំសូមត្រឡប់ចូលក្នុងការងាររបស់លោក។ ថាតើការងាររបស់លោក ដែលលោកបានលើកឡើងអម្បាញ់មិញ ថាជាអ្នកនាំសារ ជាអ្នកទទួលភ្ញៀវ។ ចំណុចមួយ ថាតើជាអ្នកនាំសារហ្នឹងគឺនាំ

សារពីណាទៅណា? ហើយធ្វើការងារជាប្រចាំថ្ងៃ ធ្វើអ្វីដែរ?

**ឆ៖** បាទ ពេលនោះ នៅពេលដែលមានរបាយការណ៍ពីខាងក្រោម គេនឹងផ្ញើៗមកឲ្យថ្នាក់ភូមិភាគអ៊ីចឹងទៅ គេត្រូវឲ្យមកដល់ខ្ញុំ ខ្ញុំនឹងផ្ញើសារទូរលេខទៅកន្លែងភូមិភាគដែលមានឈ្មោះ កន ហៅ កឹ ហ្នឹងជាអ្នកទទួល។ ខ្ញុំបានផ្ញើសារទៅនុ៎ង។

**ស៖** បាទ មានន័យថា គេផ្ញើពីថ្នាក់ក្រោមមក តើថ្នាក់ក្រោមហ្នឹងជាកម្រិតថ្នាក់ណាដែរ?

**ឆ៖** បាទ ថ្នាក់ក្រោមហ្នឹង គឺពីថ្នាក់តំបន់។

**ស៖** តើមានតំបន់ណាខ្លះ ដែលផ្ញើមកចូលកន្លែងលោក?

**ឆ៖** មានតំបន់៥, មានតំបន់៤ ដែលខ្ញុំបានទទួល។

**ស៖** តើលោកនៅចាំទេ តំបន់៤, តំបន់៥នុ៎ង នរណាជាអ្នកដឹកនាំ?

**ឆ៖** បាទ តំបន់៥ គឺឈ្មោះ ហ៊ីង្ស ជាគណៈតំបន់។ តំបន់៤ហ្នឹង គឺឈ្មោះលោក ស៊ុយ ឬក៏លោក ស៊ូ។

[០៩:២៧:២៥]

**ស៖** បាទ អរគុណ។ តើអ្វីដែលលោកបានបញ្ជូនសារ ឬមួយបញ្ជូនរបាយការណ៍ទៅលោក ក៏តើលោកមានបានដឹងថាតើការបញ្ជូនបន្តទៅទៀត តើបញ្ជូនទៅខាងណាទៀតទេ? លោកមានទទួលព័ត៌មានហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំអត់បានទទួលព័ត៌មានហ្នឹងទេ។

**ស៖** បាទ អរគុណ។ ចំណុចមួយទៀត ដែលលោកបានលើកឡើងអម្បាញ់មិញថា ការងារលោក មានទទួលភ្ញៀវ តើទទួលភ្ញៀវមកពីខាងណាខ្លះ?

**ឆ៖** បាទ ភ្ញៀវនោះគឺមកពីបណ្តាតំបន់ទាំងប្រាំពីរតំបន់នៅក្នុងភូមិភាគពាយ័ព្យនោះ ដែលមានខេត្តពីរ គឺខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។ ហើយភ្ញៀវដែលមកពីគ្រប់តំបន់នោះ គឺមកចូលរួមបើកសិក្ខាសាលា។

**ស៖** ចូលរួមបើកសិក្ខាសាលា ឬមួយមកដល់លោកត្រូវទទួលភ្ញៀវហ្នឹង ជូនទៅទស្សនកិច្ចបន្ថែមទៀត ឬមួយយ៉ាងណា?

**ឆ៖** ម្តងម្កាល ខ្ញុំតែងតែបានជូនភ្ញៀវហ្នឹងទៅលេងអង្គរសៀមរាប។

**ស៖** លោកបានថា ជូនភ្ញៀវទៅអង្គរសៀមរាប តើភ្ញៀវហ្នឹងជាភ្ញៀវក្នុងប្រទេសយើង ឬមួយ

ជាភ្ញៀវមកខាងណា?

**ឆ៖** ភ្ញៀវក្នុងប្រទេសយើង។

**ស៖** លោកមានបានដែលទទួលនូវភ្ញៀវបរទេសខ្លះដែរទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់បានទទួលភ្ញៀវបរទេស ដូចជា ភ្ញៀវចិន ភ្ញៀវកូរ៉េ។

[០៩:៣០:៣៣]

**ស៖** តើលោកចាំឆ្នាំទេ? ថាតើឆ្នាំណាដែលលោកបានទទួលភ្ញៀវចិន ភ្ញៀវកូរ៉េ ហើយជូនគាត់ទៅទស្សនកិច្ចនៅកន្លែងណាខ្លះ?

**ឆ៖** បាទ ខ្ញុំចាំបាននៅឆ្នាំ១៩៧៦ តែខ្ញុំមិនបានជូនភ្ញៀវទាំងអស់នោះ ទៅទស្សនកិច្ចនៅកន្លែងណានោះទេ។

**ស៖** លោកនៅចាំទេ ថាតើភ្ញៀវដែលអញ្ជើញមកហ្នឹង មានគ្នាច្រើន ឬមួយជាគណៈប្រតិភូតែម្តង ឬមួយយ៉ាងណា?

**ឆ៖** បាទ រួមមានគណៈប្រតិភូ និងភ្ញៀវ មកជួយធ្វើកិច្ចការងារនៅក្នុងស្រុក។

**ស៖** អរគុណ។ តើលោកនៅធ្វើការជាអ្នកនាំសារ ឬមួយជាអ្នកបញ្ជូនសារ ហើយអ្នកទទួលភ្ញៀវហ្នឹង នៅសាកលវិទ្យាល័យបាត់ដំបងហ្នឹង រហូតទៅដល់ពេលណា?

**ឆ៖** បាទខ្ញុំនៅសាកលវិទ្យាល័យហ្នឹងក្នុងឆ្នាំ១៩៧៦ ដល់ដើមឆ្នាំ៧៧ ខ្ញុំបានចាកចេញពីសាកលវិទ្យាល័យទៅនៅមន្ទីរភូមិភាគលេខ៥៦០។

**ស៖** តើលោកអាចបញ្ជាក់ពីទីតាំងមន្ទីរ៥៦០ហ្នឹង នៅចំណុចណាបានទេ នៃខេត្តបាត់ដំបងហ្នឹង?

[០៩:៣៣:១៣]

**ឆ៖** បាទ ខ្ញុំបញ្ជាក់បាន។ នៅជងផ្លូវលេខ៥ ចាប់ពីតាដំបងក្រញូង សំដៅទៅជើងចម្ងាយប្រហែលជា ខ្ញុំស្មានថា១គីឡូដីតែប៉ុណ្ណោះ។

**ស៖** តើលោកនៅទីនោះ លោកធ្វើការងារអ្វីដែរ?

**ឆ៖** ខ្ញុំនៅធ្វើការងារនៅពេលនោះ គឺទទួលលភ្ញៀវជាកម្មាភិបាល និងបញ្ជូនសំណុំរឿង ឯកសារទៅឲ្យ៨៧០។

**ស៖** លោកថា ធ្វើការនៅទីនោះ មានបញ្ជូនឯកសារ បញ្ជូនសំណុំរឿងទៅ៨៧០។ តើ៨៧០ ជា

អ្វីដែរ? លោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** បាទ ៨៧០នោះ ជាកន្លែងមន្ទីរមជ្ឈិមរបស់កុម្មុយនីស្តកម្ពុជា។

**ស៖** ហេតុអ្វីបានជាលោកបានដឹងថាលេខ៨៧០ហ្នឹង ជាមន្ទីរគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** បាទ នៅពេលដែលខ្ញុំបានដឹង ព្រោះថ្នាក់ដឹកនាំនៅភូមិភាគហ្នឹង គាត់បានប្រាប់ខ្ញុំ។

**ស៖** ថាតើពេលដែលលោកធ្វើការងារនៅទីនោះ លោកមានធ្លាប់ទទួលជាអ្នកណាខ្លះ ដែលលោកស្គាល់ពីគណៈ៨៧០ ទៅកន្លែងលោកទេ?

**ឆ៖** កាលនោះខ្ញុំអត់ដែលបានទទួលថ្នាក់ដឹកនាំមកពី៨៧០ទេ ខ្ញុំធ្លាប់តែបានទទួលភ្ញៀវនៅក្នុងស្រុក ថ្នាក់តំបន់ ដែលមកចូលរួមប្រជុំនៅមន្ទីរភូមិភាគនុ៎ង។

**ស៖** តើការប្រជុំនៅកន្លែងនោះ តើជា នរណាជាអ្នកអញ្ជើញទៅប្រជុំ លោកអាចដឹងទេ?

**ឆ៖** អ្នកដែលអញ្ជើញនៅតាមតំបន់មកចូលរួមប្រជុំនោះ គឺមានឈ្មោះ អ៊ំសាយ ដែលជាអ្នកអញ្ជើញ ហើយការចូលរួមប្រជុំ មានប្រធានភូមិភាគ ដូចការរៀបរាប់ឈ្មោះ រស់ ញឹម និងលោក កន ហៅ ក៏ នោះឯង។

[០៩:៣៧:២៥]

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាតើអ្វីដែលលោកបាននៅទីនោះជួបការប្រជុំហ្នឹងប៉ុន្មានដង? ឬមួយលោកអាចបញ្ជាក់បានទេ ថាតើក្នុងរយៈពេលប្រជុំ ដូចជា១ខែម្តង ឬមួយ៦ខែម្តង?

**ឆ៖** បាទ ការប្រជុំនោះ ជួនកាល១ខែម្តង ជួនកាលទៅ៣ខែម្តង ជួនកាលទៅ៦ខែម្តង។ តែប្រជុំហ្នឹងមានរយៈពេលខុសៗគ្នា។

**ស៖** តើលោកបានដឹងទេ ថាតើប្រធានបទអ្វីខ្លះដែលគេបានលើកយកមកក្នុងអង្គប្រជុំ?

**ឆ៖** បាទប្រធានបទដែលគេលើកយកមក គឺនិយាយអំពីការកសាងប្រទេស ការពារប្រទេស។ ហើយកសាងប្រទេសនោះ និយាយពីរឿងធ្វើប្រព័ន្ធប្រឡាយ បង្កបង្កើនផល តែប៉ុននុ៎ង។ ហើយការពារប្រទេសហ្នឹង គេនិយាយអំពីការពង្រឹងកម្លាំងស្នូលនៅក្នុងជួរកងទ័ពហ្នឹង។

**ស៖** តើលោកអាចបញ្ជាក់បានទេថា នៅពេលដែលប្រជុំហ្នឹង គេលើកយោងទៅឯកសារប្រជុំជាឯកសារមកពីថ្នាក់ណា ឬមួយជាការណែនាំពីថ្នាក់ណា? តើលោកអាចដឹងទេ ចំណុចនេះ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ។

**ស៖** អរគុណ។ ខ្ញុំសូមជម្រាបសួរចំណុចដែលពាក់ព័ន្ធទៅនឹងថាលោកនៅទីនោះ ហើយដល់ឆ្នាំ ១៩៧៧ តើលោកត្រូវគេបញ្ជូនចេញពីទីនោះ ទៅខាងណាដែរ?

**ឆ៖** បាទ នៅឆ្នាំ១៩៧៧ ខ្ញុំនិយាយមិនច្រឡំទេ នៅរដូវលំហើយចុងឆ្នាំ៧៧ហ្នឹង ខ្ញុំត្រូវបានអង្គការបញ្ជូនមកភ្នំពេញ ដែលគេចោទប្រកាន់ថា ខ្ញុំហ្នឹងជាសែស្រឡាយជនក្បត់ជាតិ។

[០៩:៤១:៣]

**ស៖** លោកបានលើកឡើងអម្បាញ់មិញថា រដូវលំហើយឆ្នាំ១៩៧៧ ត្រូវគេបញ្ជូនទៅភ្នំពេញ ហើយគេចោទប្រកាន់ជាសែស្រឡាយអ្នកក្បត់ជាតិ តើសែស្រឡាយអ្នកក្បត់ជាតិហ្នឹង គឺពាក់ព័ន្ធទៅនឹងនរណា ជាញាតិរបស់លោក ឬមួយជានរណាដែរ?

**ឆ៖** បាទ ទី១ ប្រហែលជាគេគិតថា ខ្ញុំនៅក្រោមការគ្រប់គ្រងរបស់ពួកក្បត់ជាតិ ក្បត់បក្ស បន្ទាប់មកទៀត ប្រហែលជាគេដឹងថា ខ្ញុំហ្នឹងជាសាច់ញាតិរបស់អ្នកដែលគេចោទប្រកាន់ថា គាត់ជាជនក្បត់ជាតិនោះឯង។

**ស៖** សូមលោកអាចបញ្ជាក់ឈ្មោះបានទេ?

**ឆ៖** ឈ្មោះដែលគាត់ជាអ្នកគ្រប់គ្រងខ្ញុំនៅកន្លែងមន្ទីរ៥៦០នោះ គឺឈ្មោះ សាយ។

**ស៖** ឈ្មោះ សាយ ហ្នឹងត្រូវជាសាច់ញាតិរបស់លោកដែរឬទេ?

**ឆ៖** បាទ ឈ្មោះ សាយ ហ្នឹងត្រូវជាអ៊ំ ត្រូវជាសាច់ញាតិ។

**ស៖** តើលោកអាចបញ្ជាក់បានទេ តើ សាយ ហ្នឹងគាត់នៅកន្លែងនុ៎ង គាត់មានតួនាទីដឹកនាំការងារនៅ៥៦០ហ្នឹង ជាៗអ្វីដែរ?

**ឆ៖** បាទឈ្មោះ សាយ គឺគាត់ទទួលខុសត្រូវជាប្រធានមន្ទីរ៥៦០ គេហៅថា "មន្ទីរភូមិភាគ" នោះឯង។

[០៩:៤៤:០៩]

**ស៖** ចុះចំពោះលោក ឪពុករបស់លោកវិញពាក់ព័ន្ធនឹងលោក សាយ ហ្នឹងដែរឬទេ?

**ឆ៖** បាទ លោកឪពុកខ្ញុំ គាត់ទាក់ទងត្រង់ថា គាត់ទទួលបន្ទុកការងារផ្នែកខាងឧស្សាហកម្មនៅខេត្ត នៅភូមិភាគពាយ័ព្យហ្នឹង ហើយរាល់ពេលប្រជុំម្ដងៗ គាត់តែងតែមកចូលរួមប្រជុំនៅមន្ទីរភូមិភាគ ៥៦០នោះ ជាមួយគណៈតំបន់ និង គណៈភូមិភាគទាំងអស់នុ៎ង។

**ស៖** ហើយតើលោកទាំងពីរនាក់ហ្នឹង គេចោទថាក្បត់មូលហេតុអ្វីបានលោកដឹងថាគេចោទថា

ក្បត់? ឬមួយមានរឿងអីផ្សេង?

**ឆ៖** បាទ នៅឆ្នាំ១៩៧៧ ខ្ញុំបានទទួលដំណឹងពីលោក នួន ជា ដែលបាននាំខ្លួនខ្ញុំមកដល់ភ្នំពេញនោះ គាត់បានប្រាប់ថា "អាសាយ ជាជនក្បត់បក្ស" អ៊ីចឹងមានន័យថា សាយ ត្រូវជាអ៊ំរបស់ខ្ញុំ អ៊ីចឹង នួន ជា គាត់បានចោទប្រកាន់ថា សាយ ត្រូវបានក្បត់នឹងបក្សកុម្មុយនីស្តកម្ពុជា។

**ស៖** អ៊ីចឹងមានន័យថា លោកត្រូវគេបញ្ជូនមកភ្នំពេញ មកដល់ភ្នំពេញហើយបានជួបនឹងលោក តានួន ជា ហើយលោក តានួន ជា បាននិយាយភាសាដែលលោកបានលើកឡើងអម្បាញ់មិញហ្នឹង តើនៅក្នុងពិធីអីដែរ?

**ឆ៖** បាទ នៅពេលដែលលោក នួន ជា គាត់ប្រាប់ខ្ញុំនេះគឺគាត់បានអញ្ជើញពួកខ្ញុំរាប់រយនាក់មកពីខេត្តភូមិភាគពាយ័ព្យហ្នឹង ឲ្យមកស្ដាប់គាត់ប្រាប់ គាត់ពន្យល់ថានៅតាមបណ្ដាភូមិភាគពាយ័ព្យហ្នឹង មេដឹកនាំក្បត់។ អ៊ីចឹងបក្សយកសមមិត្តទាំងអស់មកនេះដើម្បីឲ្យរួចផុតពីពួកក្បត់ ហេតុនេះហើយបានខ្ញុំដឹងថាលោក នួន ជា និយាយថា អ៊ំសាយ របស់ខ្ញុំនេះជាជនក្បត់ ហើយមនុស្សទាំងអស់ដែលរស់នៅក្រោមការដឹកនាំរបស់ភូមិភាគហ្នឹង សុទ្ធសឹងជាអ្នកដែលត្រូវបានជនក្បត់ធ្វើទុក្ខបុកម្នេញសម្លាប់ធ្វើបាបអ៊ីចឹងទៅ។ ពេលនោះ តានួន ជា បាននិយាយថា បក្សយកសមមិត្តមកទាំងអស់នេះដើម្បីឲ្យរួចផុតពីការសម្លាប់របស់ពួកក្បត់នៅតាមបណ្ដាខេត្តហ្នឹង។

[០៩:៤៨:០៩]

**ស៖** តើលោកចាំទេ ថាតើនៅពេលដែលលោក នួន ជា បាននិយាយហ្នឹង លោកអាច -- ថាតើទីតាំងនៅភ្នំពេញហ្នឹង នៅកន្លែងណា បើលោកចាំនោះណា?

**ឆ៖** បាទ ខ្ញុំចាំបានតែទីកន្លែងដែលខ្ញុំទៅប្រជុំស្ដាប់ តានួន ជា និយាយប្រាប់នោះគឺទីកន្លែងនោះមានអគារ ដូចជាអគារដែលគេស្នាក់នៅរៀនសូត្រអ៊ីចឹង។ មានគេដាក់អគារ A, B, C, D អ៊ីចឹងទៅហូរហែប៉ុន្មានអ៊ីចឹងទៅ។ ដល់ហើយមានសាលប្រជុំមួយធំនៅកន្លែងនោះ។ ខ្ញុំមិនដឹងថាទីកន្លែងនោះជាអ្វីទេ។

**ស៖** បាទអរគុណ។ ថាតើនៅពេលដែលលោក នួន ជា បើកអង្គប្រជុំនោះ មានអ្នកដែលចូលរួមហ្នឹងប៉ុន្មាននាក់ដែរ? ហើយដែលលោកបានរំឭកអម្បាញ់មិញថា ច្រើននាក់ដែលមកពីតាមខេត្ត អ៊ីចឹងមានន័យថា អ្នកដែលមកពីតាមខេត្តហ្នឹង ដូចជាលោកជាដើម មកដល់ភ្នំពេញហ្នឹង លោកចាំទេថាលោកស្នាក់នៅកន្លែងណា? ហើយពេលដែលគេប្រជុំហ្នឹង គេដឹកលោកតាម -- ដឹកលោកបន្តមកទៀត

បានមកដល់កន្លែងប្រជុំហ្នឹង តើលោកអាចចាំទេចំណុចនេះ?

[០៩:៥០:១២]

**ឆ៖** ពេលដែលគេដឹកខ្ញុំមកដល់ទីក្រុងភ្នំពេញ គឺចុះនឹងស្ថានីយរថភ្លើង បន្តគេដឹកខ្ញុំទៅសាលាភូមិន្ទ សាលាភូមិន្ទនៅភ្នំពេញហ្នឹង ដែលមានផ្ទះស្នាក់នៅហ្នឹង នៅជិតសាលាភូមិន្ទហ្នឹងរយៈពេលប៉ុន្មានថ្ងៃទេ ខ្ញុំមិនបានចាំ។ តែក្រោយមកគេបានជ្រើសរើសមនុស្សដែលមានវ័យខុសៗគ្នាយកមកកន្លែងសាលប្រជុំមួយដែលខ្ញុំរៀបរាប់ជម្រាបមេធាវីរួចហើយ ដែលខ្ញុំមិនស្គាល់ទីតាំងប្រាកដនោះ ដែលលោក នួន ជា និយាយប្រាប់រឿងរ៉ាវកន្លងមកហ្នឹង។ ហើយប្រជុំនោះរយៈពេល៣ថ្ងៃ ក្រោយពីប្រជុំរួចហ្នឹងគេឲ្យយើងមើលកុន មើលអីរឿងខ្មែរ រឿងចិនហ្នឹង។ រឿងខ្មែរហ្នឹងឈ្មោះរឿង "វីរៈប្រជាជន កងទ័ពវីរៈប្រជាជន" រឿងវីរភាពរបស់ប្រជាជន ហើយនិងរឿងចិននោះឈ្មោះៗស្អីទេ ខ្ញុំភ្លេចបាត់ទៅ។

**ស៖** បាទអរគុណ។ អ៊ីចឹងមានន័យថា ពេលដែលលោកមកពីបាត់ដំបងមកដល់ អម្បាញ់មិញថា ស្នាក់នៅសាកលវិទ្យាល័យភ្នំពេញ។ ហើយចំណុចមួយទៀតដែលលោកមិនទាន់បានឆ្លើយ ថាតើគេដឹកលោកចេញពីសាកលវិទ្យាល័យភ្នំពេញហ្នឹង ជិះអ្វីទៅកន្លែងប្រជុំហ្នឹង? ហើយក្នុងរយៈពេលដែលជិះហ្នឹងអាចប៉ុន្មាននាទីដែរ បានទៅដល់កន្លែងប្រជុំ?

**ឆ៖** បាទ ពេលដែលគេដឹកខ្ញុំចេញពីកន្លែងសាកលវិទ្យាល័យភ្នំពេញ ភូមិន្ទភ្នំពេញហ្នឹង មានឡានទេសចរណ៍។ ហើយគេដឹកយកមកដាក់កន្លែងដែលលោក នួន ជា ត្រូវប្រាប់រឿងរ៉ាវឲ្យខ្ញុំហ្នឹងបានដឹងហ្នឹង គឺមានអគារ ដូចជារៀបចំឲ្យសិស្ស ឲ្យនិស្សិតអីស្នាក់នៅរៀននៅកន្លែងហ្នឹង។ ខ្ញុំមិន -- កាលពីមុនខ្ញុំច្រឡំថាបុរីកីឡា តែការពិតទៅមិនមែនទេ។

[០៩:៥៣:០៤]

**ស៖** តើឆ្ងាយទេ ឆ្ងាយពីសាកលវិទ្យាល័យភ្នំពេញហ្នឹង អាចគិតបានទេ?

**ឆ៖** បាទ ឆ្ងាយដែរ។ ធ្វើដំណើរពីសាកលវិទ្យាល័យភ្នំពេញហ្នឹងមកតាមផ្លូវលេខ៥មក មកសំដៅចូលទីក្រុងភ្នំពេញវិញ។ ហើយកន្លែងសាលប្រជុំនោះ ជុំវិញដែលខ្ញុំមើលឃើញគឺវាយជញ្ជាំងបាំងបិទព័ទ្ធជុំវិញទីតាំងនោះ គឺមានសុទ្ធតែស័ង្កសី ខ្ពស់លិចៗក្បាលបាត់អ៊ីចឹងទៅ។

**ស៖** បាទអរគុណ។ ខ្ញុំសូមត្រឡប់ចូលនៅក្នុងចំណុចដែលលោកបានលើកឡើងថា មានការប្រជុំជាមួយលោក តានួន ជា ថាតើនៅពេលនោះមានអ្នកដែលដឹកនាំប្រជុំហ្នឹងមានប៉ុន្មាននាក់ដែរ លោកអាចចាំបានទេ?

**ឆ៖** ខ្ញុំឃើញមានអ្នកសម្របសម្រួលម្នាក់ ហើយនិងបន្ទាប់មកឃើញលោក នួន ជា បានឡើងមកកន្លែងវេទិកាហ្នឹង គាត់និយាយរឿងរ៉ាវទាំងអស់ហ្នឹងប្រាប់ពួកខ្ញុំ។

**ស៖** តើលោកបានប្រជុំតែម្ដងហ្នឹងទេ? ហើយតើលោកមាននៅចាំពាក្យអ្វីផ្សេងទៀតទេនៅក្នុងការប្រជុំហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់បានចាំអីទៀតទេ។

**ស៖** អរគុណ។ នៅមាន -- លោកអាចរំឭកបានទេ ថាតើលោក នួន ជា នៅពេលនោះ គាត់បាននិយាយពាក់ព័ន្ធនឹងការសេដ្ឋកិច្ច ឬមួយការចាយលុយអីទេ លោកមានចាំចំណុចហ្នឹងទេ?

**ឆ៖** បាទ គាត់អត់មាននិយាយអីផង។ ខ្ញុំអត់បានចាំអីផង។

**ស៖** បាទ អរគុណ។ ហើយថាតើ ខ្ញុំចង់ជម្រាបសួរថាតើក្រោយពីប្រជុំហ្នឹងហើយ គេបញ្ជូនលោកទៅណាទៀត?

[០៩:៥៦:៤១]

**ឆ៖** បាទ ក្រោយពីប្រជុំរួចគេបានបញ្ជូនខ្ញុំទៅច្រាំងចំរេះ។ ហើយឲ្យខ្ញុំនឹងទៅកាយស្រះដែលមានស្មៅ ដែលមានទឹកជ្រៅ ដែលមានគ្រាប់ មានអីសល់ចោលច្រើននៅកន្លែងនោះ។ ហើយបន្ទាប់មកខ្ញុំត្រឡប់មកពីហ្នឹងមកវិញ គេបញ្ជូនខ្ញុំទៅខាងវត្តដង្កោ គេហៅវត្តជ័យឧត្តម ឲ្យទៅជីកស្រះ ជីកអីនៅក្រោមផ្លូវរថភ្លើង ហើយឲ្យធ្វើជី ច្រូតស្រូវ ច្រូតអីហ្នឹង។ ហើយបន្ទាប់ពីហ្នឹងមកទៀត គេបានបញ្ជូនខ្ញុំត្រឡប់មកភ្នំពេញវិញ ឲ្យធ្វើសំណង់នៅមន្ទីរពេទ្យ នៅទីក្រុងភ្នំពេញហ្នឹង មានមន្ទីរពេទ្យខ្មែរ-សូវៀត មានមន្ទីរពេទ្យផលិតថ្នាំ មានមន្ទីរពេទ្យដែលជិតកាល់ម៉ែត្រហ្នឹង មានមន្ទីរពេទ្យអីខ្លះទៀតទេខ្ញុំមិនចាំអស់។

**ស៖** បាទ អរគុណ។ តើលោក មួយអំឡុងពេលដែលលោកមកនៅភ្នំពេញហ្នឹង លោកបានប្រជុំតែមួយដងហ្នឹង ឬមួយមានការប្រជុំអីផ្សេងៗទៀត? ហើយបានជួបមេដឹកនាំណាខ្លះទៀតទេ?

**ឆ៖** បាទ ការពិតទៅ ខ្ញុំបានជួបជុំក្នុងក្រុមការងារដែរធ្វើជាមួយគ្នាហ្នឹងមានជាកង ជាក្រុមហ្នឹងប្រជុំជាប្រចាំអីចឹង ពីរឿងការងាររឿងផែនការដែលយើងត្រូវធ្វើជាប្រចាំហ្នឹង។ ហើយបន្ទាប់ពីហ្នឹងមកទៀត ជិតដល់ថ្ងៃដែលរត់ចេញពីភ្នំពេញហ្នឹងនៅសល់ប៉ុន្មានថ្ងៃទេ អ្នកស្រី អៀង ធីរិទ្ធ បានប្រជុំប្រកាសប្រាប់ អំពីការរៀបចំដកចេញពីទីក្រុងភ្នំពេញ ទៅតាមទៅខេត្តបាត់ដំបង ទៅភាគខាងលិចអីចឹងទៅ។ ខ្ញុំទទួលបានព័ត៌មានតែប៉ុណ្ណឹង។

**ស៖** ចំណុចមួយទៀត ដែលលោកបានលើកឡើងគឺ តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេថាតើពាក់ព័ន្ធទៅនឹងឪពុករបស់លោក គាត់ធ្វើជាការងារ ទទួលការងារមួយហើយ ហើយត្រូវបានបាត់ខ្លួន លោកអាចជម្រាបថា តើមូលហេតុអ្វីខ្លះដែលគាត់បានធ្វើ គឺគាត់បានធ្វើការងារអ្វីដែលពាក់ព័ន្ធនឹងអ្វីដែលគេចោទគាត់ថាក្បត់ហ្នឹងដែរឬទេ?

[១០:០០:២៨]

**ឆ៖** បាទ កាលនោះខ្ញុំបានដឹងថា គាត់មានការងារនាំកម្មករឲ្យទៅដាំក្រចៅធ្វើបាវ។ នាំកម្មករទៅដាំកប្បាសនៅអណ្ដើកហែប នៅត្រែងនុ៎ង យកមកធ្វើអំបោះ។ ហើយឃើញថា គាត់ដឹកនាំធ្វើអ៊ីចឹងមិនមានឃើញគាត់ធ្វើសកម្មភាពអីខុសពីហ្នឹងផង។

**ស៖** បាទ អរគុណ។ ថាតើក្រោយពីលោកបានបាត់ដំណឹងឪពុក ហើយក្រោយមកទៀតហ្នឹងគឺលោកមកនៅភ្នំពេញរហូតទៅដល់បច្ចុប្បន្ននេះ តើលោកមានស្វែងរកនូវដំណឹងរបស់គាត់ទេ?

**ឆ៖** ខ្ញុំបានស្វែងរកនៅមន្ទីរ២១ គុក២១នោះ គុកទួលស្លែងនោះ រកមើលរូបថតគាត់អត់ឃើញ តែខ្ញុំបានឮដំណឹងថា គាត់គេបញ្ជូនមកគុកស-២១នុ៎ងឯង ហើយត្រូវបានគេសម្លាប់នៅនុ៎ង។

**ស៖** បាទ អរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ ថាតើលោកមកដល់សព្វថ្ងៃនេះ លោកនៅតែរំពឹងថា នឹងជួបគាត់ ឬមួយយ៉ាងណា?

**ឆ៖** បាទ ខ្ញុំគ្មានសង្ឃឹមថានឹងបានជួបទេ ព្រោះខ្ញុំដឹងថា គាត់នឹងស្លាប់នៅនុ៎ង។

**លោក ឡៅ ជុនធី៖**

បាទ អរគុណលោកប្រធាន ខ្ញុំបាទអស់សំណួរហើយ។ សូមអរគុណលោក។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ ផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១០:០៣:១៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកទើបតែនិយាយអំពីឪពុករបស់លោក ដូច្នេះខ្ញុំសូមបន្តសាកសួរលោកបន្ថែមអំពីឪពុករបស់លោក។ តើលោកចាំទេ ថាលោកឃើញឪពុកលោកចុងក្រោយបំផុតនៅពេលណា មុនពេលដែលគាត់ត្រូវបានគេចាប់ខ្លួននាំយកទៅ?

**2-TCCP-223៖**

**ឆ៖** បាទ ខ្ញុំសូមគោរពលោកសហមេធាវី អូ!សហចៅក្រម។ ពេលដែលខ្ញុំបែកគ្រាចុងក្រោយគឺនៅពេលនោះ មានគេប្រាប់ខ្ញុំថា អ្នកដែលចាប់ឪពុកខ្ញុំ នាំឪពុកខ្ញុំទៅពីខេត្តបាត់ដំបងទៅ គឺអ្នកដែលទៅពីភ្នំពេញ ដែលចាប់ឪពុកខ្ញុំ។ ចាប់ពីពេលនោះទៅ ខ្ញុំក៏លែងបានជួបគាត់ទៀតទៅ។

**ស៖** តើឪពុករបស់លោក គាត់ស្នាក់នៅកន្លែងណាដែរ នៅពេលដែលគេចាប់ខ្លួនគាត់នោះ? <តើលោកដឹងថា ការចាប់ខ្លួនគាត់ធ្វើឡើងនៅកន្លែងណាដែរ?>

**ឆ៖** បាទ ឪពុកខ្ញុំពេលនោះ ខ្ញុំដឹងថា ទីកន្លែងគាត់រស់នៅរោងចក្រតម្បាញនៅបាត់ដំបង។

**ស៖** តើលោកដឹងទេថា ឪពុកលោកត្រូវបានគេចាប់ខ្លួននៅ<ពេលប្រហាក់ប្រហែលគ្នា> ឬក៏នៅក្នុងពេលជាមួយគ្នានឹងពេលដែលគេចាប់ពូរបស់លោក គឺ ពូសាយ ដែលជាប្រធាន<មន្ទីរភូមិភាគ> នោះដែរ?

[១០:០៥:៤៣]

**ឆ៖** តាម បាទតាមដែលគេប្រាប់ខ្ញុំថា ចាប់នៅពេលតែមួយនោះគឺមានគ្នាបីនាក់។ មួយឈ្មោះ សាយ, ពីរទៀត ឈ្មោះ ចែត ដែលជាឪពុករបស់ខ្ញុំ, ទី៣ ទៀតឈ្មោះ ម៉ន ដែលបន្ទុកខាងពាណិជ្ជកម្មជំនួសពីលោក វ៉ាញ។

**ស៖** លោកបញ្ជាក់ថា ឪពុករបស់លោកឈ្មោះ <ចែត> តើនេះជាឈ្មោះបដិវត្តរបស់គាត់មែនទេ? តើលោកអាចប្រាប់បានទេ ថាឈ្មោះពេញរបស់ឪពុកលោកឈ្មោះអ្វីដែរ? ហើយតើឈ្មោះហៅក្រៅរបស់ឪពុកលោកឈ្មោះអ្វីដែរ?

**ឆ៖** បាទ ឈ្មោះហៅក្រៅគឺឈ្មោះ សូ ចែត។ ឈ្មោះខាងក្នុងពីដើម ខ្ញុំចាំបាន ឈ្មោះ ជឹម។ តែខ្ញុំអត់បានចាំត្រកូលគាត់ថា ត្រកូលអីទេ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្ដល់នូវកំណត់ត្រា<ចំនួនពីរមក>ពីមន្ទីរស-២១ សុំប្រគល់ជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីឲ្យគាត់ពិនិត្យមើលទៅលើឯកសារទាំងពីរនេះ។ ហើយឯកសារដែលខ្ញុំសុំ

អនុញ្ញាតនេះគឺ E3/9646 ខ្មែរមានទំព័រ <01017058>។ ហើយឯកសារមួយទៀតគឺ E3/9996។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីប្រគល់ជូនទៅដើមបណ្តឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:០៨:១០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំបានប្រគល់នូវឯកសារពីរជូនទៅដល់លោក គឺជាឯកសារមកពីមន្ទីរស-២១ គឺលេខ១០.០៥៤ នៅលើបញ្ជីរបស់ ក.ស.ច.ស ឈ្មោះ <សូ ជឹម> ហៅ ចែត អាយុ ៤៦ឆ្នាំ ជាប្រធានរោងចក្រតម្បាញនៅបាត់ដំបង ចូលស-២១ នៅថ្ងៃ២៨ មិថុនា ឆ្នាំ១៩៧៧។ ឯកសារទាំងពីរដែលប្រគល់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី គឺជា<កំណត់ត្រាមូលដ្ឋាន ដែលលើកឡើងដោយ> ក.ស.ច.ស។ លោកដើមបណ្តឹងរដ្ឋប្បវេណី ឯកសារទី១ គឺ E3/9646 គឺជាបញ្ជីឈ្មោះអ្នកទោសដែលចូលស-២១ នៅថ្ងៃ២៨ មិថុនា ឆ្នាំ១៩៧៧។ លេខ៤៧ គឺឈ្មោះ <សូ> ជឹម ប្រធានរោងចក្រតម្បាញបាត់ដំបង។ ហើយឯកសារទី២ ដែលខ្ញុំប្រគល់ជូនលោកដែរនោះគឺ E3/9996 គឺជាបញ្ជីត្រួតពិនិត្យប្រចាំថ្ងៃទៅលើអ្នកទោស ថ្ងៃ៣០ ខែកក្កដា ឆ្នាំ១៩៧៧ ហើយមានអក្សរសរសេរដៃ ដែលនិយាយអំពី <សូ> ជឹម ហៅ ចែត ដែលជាប្រធានរោងចក្រតម្បាញនៅខេត្តបាត់ដំបង។ លោកអាចបញ្ជាក់បានទេលោកដើមបណ្តឹងរដ្ឋប្បវេណីថា បុគ្គលដែលគេបង្ហាញនៅក្នុងបញ្ជីអ្នកទោសស-២១ហ្នឹងគឺជាឪពុករបស់លោក តើមែនទេ?

**2-TCCP-223៖**

**ឆ៖** បាទ ពិតមែន ជាលោកឪពុករបស់ខ្ញុំ។

[១០:១០:២៦]

**ស៖** ឯកសារទី២ គឺមានអក្សរសរសេរដៃនៅចុងទំព័រអំពីមរណភាពរបស់គាត់ផងដែរ គឺមានតែឯកសារជាភាសាខ្មែរនោះទេ។ ដូច្នេះខ្ញុំសូមឲ្យសហការីខ្ញុំជាជនជាតិខ្មែរ ឲ្យគាត់អាននូវកំណត់ត្រាសរសេរដៃនេះ ហើយបន្ទាប់មកទៀត ខ្ញុំនឹងសួរលោក។

**កញ្ញា សុង ឆវ័ន្ត៖**

កំណត់ត្រាដែលសរសេរដោយដៃគឺឯកសារ E3/9996 នៅផ្នែកខាងក្រោម លោកសាក្សី។ គេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សរសេរដោយដៃថា "ស៊ូ ជឹម ហៅ ចែត ប្រធានរោងចក្រតម្បាញបាត់ដំបង ងាប់ដោយជំងឺរាកមួល ដំបៅខ្នងខ្លាំង បានព្យាបាលរយៈពេល១ខែ"។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារនេះបានកត់ត្រាថាឪពុករបស់លោកស្លាប់ដោយសាររាកមួល ហើយនិងដំបៅខ្នងខ្លាំង <>រយៈពេល១ខែ<ក្រោយចូលដល់ ស-២១>។ ដូច្នេះខ្ញុំចង់សួរលោកថា តើតាមដែលចាំហ្នឹង នៅពេលដែលលោកឃើញគាត់ចុងក្រោយបំផុត មុនពេលដែលចាប់ខ្លួនហ្នឹង តើឪពុកលោកមានសុខភាពល្អ ឬមួយក៏គាត់មានជំងឺតម្កាត់រួចទៅហើយ?

**2-TCCP-223៖**

**ឆ៖** បាទ ឪពុកខ្ញុំមានសុខភាពល្អ គាត់អត់មានជំងឺអី ដូចការរៀបរាប់នៅក្នុងនេះទេ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្ដល់នូវឯកសារបន្ថែមពីរទៀតជាឯកសាររបស់ស-២១ គឺសូមផ្ដល់ជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងបុគ្គលម្នាក់ដែលជាប្រធានមន្ទីរភូមិភាគពាយ័ព្យ។ ឯកសារ E3/9646 <ខ្មែរ>មានលេខ <01017054> ជាបញ្ជីឈ្មោះអ្នកទោសដែលចូល<ស-២១នៅ>ថ្ងៃ២៦ មិថុនា ឆ្នាំ១៩៧៧។ ហើយឯកសារទី២ គឺមកពីឯកសារ E3/2285 ខ្មែរមានលេខ 0009303*(ស៊ីក)* ដល់<9309> គឺជាបញ្ជីអ្នកទោសដែលបានកម្ទេចថ្ងៃ១៨ ខែតុលា ឆ្នាំ៧៧។ ហើយដូច្នេះខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារនេះជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី។

[១០:១៣:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្តិច។ សូមលោកជូនផ្ដល់ឯកសារERN ជាភាសាអង់គ្លេសផង។

**លោក ឌេល លីសាក់៖**

ឯកសារទី១គឺ E3/9646 គឺមានតែឯកសារភាសាខ្មែរប៉ុណ្ណោះ។ <វាគឺជាកំណត់ត្រាមួយនៃកំណត់ត្រាមូលដ្ឋាន យកចេញ>បញ្ជីរបស់ខាង ក.ស.ច.ស។ ហើយឯកសារទី២ គឺជាឯកសារមានបកប្រែជាភាសាអង់គ្លេសគឺ 00873637 គឺ <873637> គឺឯកសារ E3/2285 អត់មានជាភាសាបារាំង

នោះទេ។--

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមានឯកសារបកប្រែជាភាសាអង់គ្លេសទៅលើឯកសារ E3/9646 គឺ ERN មានលេខ 0113958 (សូមទោស) គឺ 01139858។

**លោក ឌេល លីសាក់៖**

បាទ គឺជាឯកសារបកប្រែមួយផ្នែកនៃភាសាខ្មែរទេ។ ឯកសារបកប្រែ E3/9646 គឺនៅថ្ងៃ -- គឺបញ្ជី<ចូល នៅថ្ងៃ> ២៨ មិថុនា ឆ្នាំ៧៧ <ប៉ុន្តែមិនមែនបញ្ជីថ្ងៃ២៦ មិថុនា ឆ្នាំ១៩៧៧ នោះទេ>។

[១០:១៥:៣១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកដើមបណ្ដឹង ខ្ញុំផ្ដល់ឯកសារពីរនេះជូនដល់លោក គឺទី១ គឺបញ្ជីអ្នកទោសចូល<ស-២១> នៅថ្ងៃ២៦ មិថុនា ១៩៧៧, លេខ២៦នៅក្នុងបញ្ជីនេះ គឺE3/9646 ខ្មែរមានលេខ 01017054។ លេខ២៦ មានឈ្មោះ រស់ ម៉ៅ ជាប្រធានមន្ទីរភូមិភាគ<ពាយ័ព្យ>។ ហើយឯកសារទី២ ដែលខ្ញុំផ្ដល់ជូនលោកគឺ E3/2285 នោះ ខ្ញុំបានគូសនូវឈ្មោះឱ្យលោកឃើញ គឺលេខ៣៥ នៅបញ្ជីនោះ គឺក្នុងចំណោមអ្នកទោស<១៧៩>នាក់ដែលបានកម្ទេចនៅ<ថ្ងៃ១៨> ខែតុលា ៧៧ ហ្នឹងគឺលេខ៣៥ ឈ្មោះ រស់ ម៉ៅ ហៅ សាយ ប្រធានមន្ទីរភូមិភាគពាយ័ព្យ។ តើលោកអាចបញ្ជាក់បានទេ ថាតើបុគ្គលនេះគឺជា ពូសាយរបស់លោកដែលលោកបានរៀបរាប់កាលពីព្រឹកមិញនេះមែនទេ?

**2-TCCP-223៖**

**ឆ៖** បាទ ពិតមែន។

**ស៖** ឥឡូវនេះ ខ្ញុំខ្ញុំចង់សួរបន្ថែមទៀតទាក់ទងទៅនឹងការចាប់ខ្លួនឪពុក និងពូរបស់លោក។ <តើនរណាជាអ្នកប្រាប់លោកដំបូង> ថាឪពុក ហើយនិងពូរបស់លោកហ្នឹង<ត្រូវបានគេ>ចាប់ខ្លួន <ឬក៏ថាតើលោកដឹងរឿងហ្នឹងដំបូង ដោយរបៀបណា>?

**ឆ៖** បាទ ខ្ញុំបានដឹងដំណឹងថា មានមនុស្សទៅពីភ្នំពេញហ្នឹងទៅចាប់គាត់។ នេះខ្ញុំឮដំណឹង មិនបានឃើញទេ។

[១០:១៧:៣៧]

**ស៖** តើលោកចាំទេ អ្នកណាប្រាប់លោក?

**ឆ៖** បាទ អ្នកដែលប្រាប់ខ្ញុំនោះគឺកងការពារនៅមន្ទីរ៥៦០នោះ។

**ស៖** ឥឡូវនេះខ្ញុំចង់និយាយអំពីបញ្ហាប្រវត្តិមួយចំនួន ទាក់ទងទៅនឹងតួនាទីរបស់លោក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ ខ្វះម្ភៃប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨ នាទី ដល់ម៉ោង ១០:៣៦ នាទី)*

[១០:៣៦:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ក្រឡាបញ្ជីត្រួតពិនិត្យមើលសហមេធាវីការពារក្តីលោក នួន ជា យ៉ាងម៉េចទៅ? បាទ សូមផ្តល់វេទិតាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកដើមបណ្តឹងរដ្ឋប្បវេណី លោកបានឆ្លើយប្រាប់អំពីទីតាំងដែលលោកធ្វើការនៅភូមិភាគពាយ័ព្យ។ តើពូរបស់លោក សាយ ដែលជាប្រធានមន្ទីរភូមិភាគ<ពាយ័ព្យ>នោះ តើគាត់ធ្វើការនៅទីតាំងតែមួយជាមួយនឹងលោក ឬក៏គាត់ធ្វើការនៅកន្លែង<>ជិតលោក? អ៊ីចឹងសូមលោកបញ្ជាក់បន្តិចមើល ថា<តើលោកធ្លាប់ធ្វើការនៅក្នុង>មន្ទីរ<តែមួយ ដូចគ្នានឹងមន្ទីរ>ពូរបស់លោកធ្វើការនោះ<>ដែរ<ទេ>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៣៨:២៦]

**2-TCCP-223៖**

**ឆ៖** ទីតាំងចម្ងាយពីលោកតាដំបងគ្រញូង នៅឯងផ្លូវលេខ៥ហ្នឹង ចម្ងាយប្រហែលជា១គីឡូម៉ែត្រ។ ហើយអ៊ំរបស់ខ្ញុំនោះគាត់នៅធ្វើការកន្លែងនោះ មិនមានទៅធ្វើការនៅកន្លែងណាទៀតទេ។

**ស៖** នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក លោកនិយាយថា លោកធ្វើជានីរសារនៅមន្ទីរភូមិភាគ លោកបានឆ្លើយថា សូមដកស្រង់៖ "ខ្ញុំទទួលតួនាទីភារកិច្ចនេះ ដោយសារថាឪពុករបស់ខ្ញុំ ធ្លាប់ស្គាល់ ខៀវ សំផន, នួន ជា, ហ៊ូ នឹម, ហ៊ូ យន់ និងមេដឹកនាំដទៃទៀត មុនពេលខ្មែរក្រហមបានឡើងកាន់កាប់អំណាចនៅក្នុងប្រទេសកម្ពុជា។" បញ្ចប់ការដកស្រង់។ តើធ្វើម៉េចបានជាលោកដឹងថា ឪពុករបស់លោកធ្លាប់ស្គាល់ នួន ជា, ខៀវ សំផន ក៏ដូចជាមេដឹកនាំដទៃទៀត មុនពេលខ្មែរក្រហមឡើងកាន់កាប់អំណាចនោះ?

**ឆ៖** បាទ មូលហេតុដែលគាត់បានស្គាល់គ្នា គាត់ធ្លាប់រស់នៅ ធ្លាប់រៀន ធ្លាប់ធ្វើការអីជុំគ្នា។

**ស៖** តើលោកដឹងព័ត៌មានអីលម្អិតទេ? តើលោកធ្លាប់បានដឹងថា ឪពុករបស់លោក ធ្លាប់ធ្វើការជាមួយ នួន ជា និងខៀវ សំផន ដែរឬទេនៅមុនថ្ងៃ១៧ មេសា ៧៥?

**ឆ៖** សូមបញ្ជាក់ម្ដងទៀតលោក ខ្ញុំស្ដាប់មិនទាន់។

**ស៖** សំណួររបស់ខ្ញុំ តើលោកដឹងទេ តើឪពុករបស់លោកធ្លាប់បានធ្វើការជាមួយ នួន ជា និងខៀវសំផន ក៏ដូចជាធ្លាប់ធ្វើការជាមួយមេដឹកនាំដទៃទៀត នៅកន្លែងណាដែរមុនថ្ងៃ១៧ មេសា ១៩៧៥?

[១០:៤១:១១]

**ឆ៖** នៅភ្នំពេញ។

**ស៖** ខ្ញុំសូមចូលទៅប្រធានបទមួយថ្មីទៀត ដែលបានលើកឡើងនិយាយនៅក្នុងពាក្យសុំរបស់លោក គឺនិយាយអំពីការប្រព្រឹត្តមកលើព្រះពុទ្ធសាសនា។ តើលោកអាចជម្រាបជូនតុលាការបានទេ ថាមានអ្វីកើតឡើងទៅដល់វត្តអារាម ក៏ដូចជា ព្រះសង្ឃនៅស្រុកកំណើតរបស់លោក គឺនៅក្នុងខេត្តបាត់ដំបង នៅក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** បាទ ខ្ញុំបានដឹងថា នៅក្នុងកិច្ចប្រជុំជាសាធារណៈមុនឆ្នាំ រំដោះឆ្នាំ៧៧ មេសា គេតែងតែប្រជុំប្រាប់មនុស្សជាទូទៅថា នៅពេលដែលយើងកាន់ការរំដោះប្រទេសហ្នឹង គេឲ្យមានតែរបបពីរទេគឺ -- វណ្ណៈពីរទេ គឺវណ្ណៈកម្មករ កសិករ។ វណ្ណៈបីទៀត ដែលគេសំដៅកំណត់ថា វណ្ណៈសក្តិភូមិ វណ្ណៈ

នាយទុន និងវណ្ណៈអនុធន ដែលជាវណ្ណៈជិះជាន់វណ្ណៈកម្មករ កសិករនោះ តាមដែលការប្រជុំប្រាប់ជាទូទៅ គឺថាគេនឹងមិនឱ្យមានទេ។

**ស៖** តើអ្នកណាជាអ្នកឡើងនិយាយនៅក្នុងអង្គប្រជុំអំពីប្រធានបទមួយនេះ?

**ឆ៖** មនុស្សជាទូទៅ ខ្ញុំមិនបានចាំឈ្មោះ។ មកដល់ថ្ងៃនេះគឺ ខ្ញុំចាំបានតែការពន្យល់ប្រាប់ថា នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យកាន់កាប់ប្រទេសទាំងស្រុង យើងមិនឱ្យមានរបប -- យើងមិនឱ្យមានវណ្ណៈបី គឺវណ្ណៈសក្តិភូមិ វណ្ណៈនាយទុន និងវណ្ណៈអនុធនឡើយ។ យើងឱ្យមានតែវណ្ណៈកម្មករ និងកសិករ។ គឺជាទូទៅ នៅពេលដែលគេបើកកិច្ចប្រជុំនៅតំបន់ជនបទដែលជាគេហៅថា ប្រជាពលរដ្ឋមូលដ្ឋាននៅតំបន់រំដោះអីទាំងអស់ហ្នឹង គឺតែងតែនិយាយជាទូទៅអ៊ីចឹង។

[១០:៤៤:០៥]

**ស៖** ខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោក នៅក្នុង<ទម្រង់>ព័ត៌មានបន្ថែម<ដែលលោកបានដាក់ជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី> គឺឯកសារ E3/6636a – E3/6636a, ERNជាភាសាខ្មែរគឺ 00579467, អង់គ្លេស 00859259 មិនមានការបកប្រែជាភាសាបារាំងទេ។ លោកបានឆ្លើយថា សូមដកស្រង់៖ “នៅក្នុងអង្គប្រជុំមួយ មេដឹកនាំភូមិភាគឈ្មោះ កន បាននិយាយថា មានវណ្ណៈតែពីរទេ គឺវណ្ណៈពលករ និងកសិករ។ ហើយមិនមានអ្វីដែលត្រូវចាំបាច់គោរពប្រណិប័តន៍ជំនឿសាសនានោះទេ។” បញ្ចប់ការដកស្រង់។ តើអង្គប្រជុំនេះ ជាអង្គប្រជុំតែមួយដែលលោកទើបបានរៀបរាប់នេះឬ? <តើមេដឹកនាំ>ភូមិភាគ<ជានរណា, កន? ព្រឹកមិញលោកនិយាយសំដៅទៅលើបុគ្គលម្នាក់ ដែលជាគណៈភូមិភាគជាមួយ ញឹម> ឈ្មោះថា កន <ហៅ កឺ។> តើ<បុគ្គល>នេះ<ឬ>ដែល<បាន>និយាយនៅក្នុងអង្គប្រជុំមួយ<>នោះ<>?

**ឆ៖** ខ្ញុំធ្លាប់ស្គាល់ថា កន ដែលជាមេដឹកនាំនៅភូមិភាគនោះឯង។ ខ្ញុំស្គាល់តែ កន ហ្នឹង។ មិនថាតែ កន ទេ មនុស្សជាទូទៅដែលពេលដែលគេប្រជុំតាមកង តាមក្រុម តាមអីទាំងអស់ហ្នឹង គេតែងតែនិយាយពាក្យហ្នឹង ដែលខ្ញុំបានដឹង។

**ស៖** សុំសួរបញ្ជាក់ឱ្យច្បាស់បន្តិច។ បុគ្គលម្នាក់នេះឈ្មោះ កន តើជាមនុស្សតែមួយដែល<លោកបានបញ្ជាក់ដែរថា> គេហៅឈ្មោះក្រៅ ថាឈ្មោះ <កឺ> ហ្នឹង ឬក៏មិនមែនទេ?

**ឆ៖** ខ្ញុំមិនបានដឹង។

[១០:៤៧:៥៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ប្រហែលជាខ្ញុំយល់ច្រឡំក៏មិនដឹង ពីមុននេះ លោកថាមានមនុស្សពីរនាក់ដែលជាសមាជិកគណៈកម្មាធិការភូមិភាគ ម្នាក់គឺ រស់ ញឹម។ ចុះម្នាក់ទៀតដែលលោកថា ជាសមាជិករបស់គណៈភូមិភាគដែរ ធ្វើការជាមួយ រស់ ញឹម ដែរហ្នឹង ឈ្មោះអ្វីទៅ?

**ឆ៖** ខ្ញុំដឹងថា ឈ្មោះ កន និងសមាជិកជាច្រើនដែលនៅក្នុងភូមិភាគហ្នឹង ក៏ធ្វើការជាមួយ រស់ ញឹម ដែរ។

**ស៖** ខ្ញុំនឹងត្រឡប់មកសួរអំពីគាត់នេះនៅពេលក្រោយ។ <ដូច្នេះ>លោក<បានមានវត្តមាន>នៅក្នុងអង្គប្រជុំមួយ <ដែល>មានការប្រកាស ហើយក្រោយពីការប្រកាសមកនោះ តើមានអ្វីកើតឡើងចំពោះវត្តអារាម ក៏ដូចជាលោកសង្ឃនៅ<ស្រុកកំណើតរបស់លោក> ក្នុងខេត្តបាត់ដំបងនោះ?

**ឆ៖** បាទ ការពិតជាទូទៅ មិនចាំបាច់តែនៅខេត្តបាត់ដំបងទេ គឺនៅកន្លែងណាក៏ដូចកន្លែងណាដែរ ព្រះសង្ឃត្រូវបានមិនមានប្រជាពលរដ្ឋ ឬក៏គ្មានអ្នកណាមួយដែលអនុញ្ញាតឲ្យមានព្រះសង្ឃបន្តទៀត។

**ស៖** តើលោកដឹងថា មេដឹកនាំដទៃទៀតនៅមជ្ឈិមនេះ <បានជាប់ពាក់ព័ន្ធ ឬក៏>មានបានចេញបញ្ជាណាមួយ ពាក់ព័ន្ធទៅនឹងការបិទ ឬក៏ថាការលុបបំបាត់វត្តអារាមនៅទូទាំងប្រទេសនោះដែរទេ? លោកដឹងថា មានថ្នាក់មជ្ឈិមណាបានចេញសេចក្ដីសម្រេចនេះដែរទេ?

**ឆ៖** បាទ អត់ៗដឹងទេ។

[១០:៤៩:១៩]

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឲ្យច្បាស់បន្តិច។ ចម្លើយពាក់ព័ន្ធទម្រង់ស្ដីអំពីព័ត៌មានបន្ថែម <នៅត្រង់ទំព័រដដែល> គឺឯកសារ E3/6636a។ ហើយក្រោយលោករៀបរាប់អំពីអង្គប្រជុំនេះមក គឺលោកបន្តឆ្លើយដូចតទៅ សូមដកស្រង់៖ "ក្រោយមក ក្នុងឆ្នាំ១៩៧៦ មានបញ្ជាពី នួន ជា ឲ្យលុបបំបាត់វត្តអារាមនៅស្រុកមោងឫស្សី ដើម្បីយកទៅប្រើប្រាស់ជាឃ្លាំងផ្ទុកផ្សេងៗ គឺខ្មែរក្រហមនោះគឺមានផែនការដើម្បីលុបបំបាត់សាសនា ក៏ដូចជាចាប់ផ្សឹកព្រះសង្ឃតាំងពីមុនឆ្នាំ១៩៧៥មកម្ល៉េះ។" បញ្ចប់ការដកស្រង់។ លោកថាមានបញ្ជាមួយចេញពី នួន ជា ឲ្យលុបបំបាត់វត្តអារាមនេះ។ <តើហេតុអីបានជាលោកនិយាយបែបនេះ?> តើធ្វើម៉េចបានជាលោកដឹង<>ថា នួន ជា គឺជាអ្នកចេញបញ្ជាឲ្យលុបបំបាត់វត្តអារាម ក៏ដូចជាចាប់ផ្សឹកព្រះសង្ឃនោះ?

**ឆ៖** បាទ ព្រោះអីលោក កន គាត់ឧស្សាហ៍ជួបជាមួយលោក នួន ជា។ ពេលនោះលោក កន

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានជិតស្និទ្ធជាមួយខ្ញុំ គាត់ក៏បាននិយាយរឿងហ្នឹងប្រាប់ខ្ញុំ ឲ្យខ្ញុំបានដឹង។

**ស៖** តើលោកដឹងទេថា កន នេះបានជួបជាមួយនឹង នួន ជា នៅឯណាដែរ?

**ឆ៖** បាទ ពេលវេលាខុសៗគ្នា។ ជួនកាលគាត់ជួបនៅខាងមោង ជួនកាលគាត់ជួបនៅបាត់ដំបង ជួនកាលគាត់អាចទៅជួបនៅភ្នំពេញ។

**ស៖** នៅក្នុងរបបនោះ តើលោកមានដឹងថា នួន ជា នេះជាអ្នកដែលមានស្រុកកំណើតមកពីបាត់ដំបងដែរឬទេ?

**ឆ៖** បាទ ខ្ញុំដឹងថាគាត់នៅអំពិលប្រហោង បាត់ដំបង។

**ស៖** តើលោកដឹងថា នួន ជា គាត់មកពីភូមិអំពិលប្រហោងនេះដោយរបៀបណា? ដឹងពីអ្នកណា?

[១០:៥២:៣០]

**ឆ៖** បាទ ខ្ញុំដឹងពីម្ដាយខ្ញុំ ព្រោះអីម្ដាយខ្ញុំគាត់ធ្លាប់រស់នៅជាមួយលោក នួន ជា។ ខ្ញុំក៏ធ្លាប់រស់នៅជាមួយលោក នួន ជា កាលនៅតូចៗ តាមម្ដាយខ្ញុំ គាត់ប្រាប់។

**ស៖** អ៊ីចឹងអ្វីដែលលោកកំពុងឆ្លើយ គឺមុនឆ្នាំ១៩៧៥មែនទេ? តើលោកនៅចាំបានទេ ឲ្យពិតប្រាកដទៅ តើលោក ហើយនិងម្ដាយរបស់លោកដែលថាធ្លាប់រស់នៅ<កន្លែង>ជាមួយនឹង នួន ជា ហ្នឹង តើធ្លាប់រស់នៅក្នុងឆ្នាំណាដែរ?

**ឆ៖** បាទ បើខ្ញុំចាំមិនច្រឡំទេ កាលនុ៎ងគឺរស់នៅទីក្រុងភ្នំពេញ ក្នុងចន្លោះឆ្នាំ៥៨, ៥៩, ឬក៏៦០ អីនុ៎ង។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីកិច្ចប្រជុំរវាង នួន ជា និង កន នៅពេលក្រោយនេះបន្តិច។ ប៉ុន្តែបន្តទៅនេះខ្ញុំសួរសំណួរទូទៅ ពាក់ព័ន្ធទៅនឹងអំឡុងពេលក្រោយខ្មែរក្រហមឡើងកាន់កាប់អំណាច។ តើលោកដឹងទេ ក្រោយពេលខ្មែរក្រហមឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ មេសា ១៩៧៥ តើមានអ្វីកើតឡើងចំពោះមន្ត្រីរដ្ឋការ ក៏ដូចជាទាហានរបបលន់នល់ នៅពេលក្នុងខេត្តបាត់ដំបង? ជាពិសេសមន្ត្រីរដ្ឋការ និងទាហានដែលមានបណ្ដាស័ក្តិទាំងនោះ មានអ្វីកើតឡើងទៅដល់អ្នកទាំងអស់នោះ?

**ឆ៖** បាទ ខ្ញុំបានដឹងថា ពេលនោះមានការសម្លាប់ទៅដល់មន្ត្រីក្នុងរដ្ឋការលោក លន់ នល់។

**ស៖** តើលោកដឹងរឿងនេះ ដោយរបៀបណាដែរ?

[១០:៥៥:១២]

**ធ៖** បាទ ខ្ញុំបានដឹងដោយមនុស្សដែលខ្ញុំធ្លាប់ទំនាក់ទំនងរស់នៅ គេបាននិយាយឲ្យខ្ញុំដឹង។

**ស៖** តើឪពុករបស់លោក ឬក៏ពូរបស់លោកដែលនិយាយប្រាប់មកលោកអំពីអ្វីដែលកើតឡើងទៅដល់មន្ត្រីរដ្ឋការ ឬក៏ទាហាន លន់ នល់ ក្រោយខ្មែរក្រហមឡើងកាន់អំណាចដែរឬទេ?

**ធ៖** អត់បានដឹងពីគាត់និយាយទេ។

**ស៖** នៅក្នុងសក្ខីកម្មរបស់លោកដែលលោកបានឆ្លើយព្រឹកមិញនេះ គឺលោកនិយាយអំពីការចាប់ខ្លួនឪពុករបស់លោក និងពូរបស់លោក។ ខ្ញុំសូមសួរលោកអំពីការចាប់ខ្លួន ឬក៏ការបោសសម្អាតមុនពេលការចាប់ខ្លួនឪពុក <និង>មាររបស់លោក។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេត លោកបាននិយាយអំពីកម្មាភិបាលភូមិភាគពាយ័ព្យត្រូវដកចេញអំពីតំណែង ហើយនិងត្រូវគេបោសសម្អាតនៅដើមខែកុម្ភៈ ឬក៏នៅដើមខែមីនា ឆ្នាំ៧៧ គឺរយៈពេល៣ ទៅ៤ខែ មុនការចាប់ខ្លួនឪពុក <និង>មាររបស់លោក។ តើលោកនៅចងចាំអ្វីខ្លះដែរ នៅដើមឆ្នាំ៧៧នោះ នៅពេលដែលកម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានគេដកចេញពីមុខតំណែង និង ហើយចាប់ខ្លួនជាលើកដំបូងនោះ? អ៊ីចឹងលោកអាចរៀបរាប់ដំណើររឿងនេះ ជូនតុលាការលម្អិតបន្តិចបានទេ?

[១០:៥៧:២៧]

**ធ៖** បាទ ថ្ងៃនេះខ្ញុំនឹងរៀបរាប់អំពីរឿងដែលកើតមានឡើងក្នុងចន្លោះឆ្នាំ១៩៧៧។ បើតាមការដឹងរបស់ខ្ញុំ ពេលដែលគេបោសសម្អាត គឺគេបន្តបោសសម្អាតដំបូង ខ្ញុំនិយាយថយក្រោយបន្តិចទៅនិយាយឲ្យវាដឹងរឿងបន្តិចទៅ។ ថាដំបូង គឺគេសម្អាតភូមិភាគឧត្តរ។ អ៊ីចឹងគេសម្អាតក្នុងរួច បានគេមកសម្អាតភូមិភាគពាយ័ព្យ។ អ៊ីចឹងគេសម្អាតនោះ គេសម្អាតចាប់ពីកម្មាភិបាលថ្នាក់ខាងក្រោមៗ ដែលយកកម្មាភិបាលផ្សេងៗពីខាងក្រៅ ដែលមានពីនិរតីយកមកជំនួស ធ្វើការងារផ្សុំនឹងកម្មាភិបាលចាស់ដែលនៅមានស្រាប់ក្នុងខេត្តបាត់ដំបង។ អ៊ីចឹងជាទូទៅ នៅពេលដែលគេធ្វើកិច្ចការងារហ្នឹង គេយកមនុស្សបណ្តើរៗយកទៅ គេថា យកទៅរៀនសូត្រ ក៏ទៅបាត់ទៅ។ គេយកទៅនេះ គេយកទៅនោះ ថាទៅរៀនសូត្រ បាត់ទៅ។ រហូតដល់រឿងទាំងអស់ហ្នឹង វាកើតទៅដល់កម្មាភិបាលខាងលើដែលថ្នាក់ភូមិភាគជាអ្នកទទួលខុសត្រូវ គឺរឿងទាំងអស់ហ្នឹង វាវិល វាវិលដូចកងរទេះអ៊ីចឹង។ អាអ្នកត្រូវបានសម្លាប់គេ ចុងក្រោយអាអ្នកដែលត្រូវបានគេសម្លាប់ហ្នឹង វាសម្លាប់បន្តគ្នាអ៊ីចឹង។ ចុងក្រោយវាដួលរលំខ្លួនឯងទាំងស្រុងតែម្តងទៅ។

**ស៖** លោកនិយាយថា គេបានបញ្ជូនកម្មាភិបាលពីភូមិភាគនិរតី ទៅជំនួសកម្មាភិបាលនៅភូមិ

ភាគពាយ័ព្យ។ តើលោកដឹងថា មានកម្មាភិបាលពីភូមិភាគនិរតីហ្នឹង ត្រូវបានគេបញ្ជូនទៅពាយ័ព្យហ្នឹងប៉ុន្មាននាក់ដែរ នៅក្នុងឆ្នាំ៧៧? ហើយនៅពេលដែលកម្មាភិបាលទាំងនោះ ទៅដល់បាត់ដំបង តើពួកគេស្នាក់នៅឯណាដែរ?

[១១:០០:០២]

**ឆ៖** បាទ កម្មាភិបាលដែលគេបញ្ជូនពីភាគនិរតីមកដល់ពាយ័ព្យនោះ គឺមកស្នាក់នៅសាកលវិទ្យាល័យ ផ្នែកខាងស្រី។ ខាងប្រុសនោះ គេសម្រាកនៅវាលបែកចាន គេហៅថាព្រលានយន្តហោះបាត់ដំបង។ ហើយខាងប្រុសនោះ ខ្ញុំស្គាល់ថា គេហ្នឹងឈ្មោះ រាម តែខាងស្រីហ្នឹង ខ្ញុំមិនបានស្គាល់ឈ្មោះគេថាជាអ្នកណាអីអ្នកណាទេ។ តែមកខ្ញុំបានរៀបចំទីកន្លែងឲ្យគេស្នាក់នៅផ្ទាល់ដៃខ្ញុំតែម្តង។

**ស៖** តើលោកនៅចាំទេ កម្មាភិបាលទៅពីភូមិភាគនិរតីហ្នឹងមានប្រហែលជាប៉ុន្មាននាក់ដែរ ដែលត្រូវទៅស្នាក់នៅកន្លែងដែលគេបានរៀបចំទុកឲ្យស្នាក់ ដូចលោករៀបរាប់នេះ? តើសរុបចំនួនទាំងអស់មានប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំមិនបានចាំចំនួនមនុស្សដែលគេមកនោះទេ តែខ្ញុំគ្រាន់តែបានដឹងថា មនុស្សដែលមានមកនោះមានចំនួនច្រើន។

**ស៖** ឥឡូវនេះខ្ញុំសូមរំឭក<ការចងចាំ>លោកបន្តិច។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ E3/9477 – E3/9477 នៅសំណួរចម្លើយទី៣១ ដល់៣២ លោកបាននិយាយថា៖ “យើងជាអ្នកទទួលកម្មាភិបាលថ្មី ដែលបានបញ្ជូនទៅក្នុងដំណាក់កាលដំបូង ដែលមានមនុស្សចន្លោះ៥០០ទៅ៦០០នាក់។ ក្នុងនោះមានទាំងបុរស ទាំងនារី ទាំងស៊ីវិល និងកងទ័ព គឺនៅចុងឆ្នាំ១៩៧៦។” ហើយលោកបានរៀបរាប់ថា លោកទទួលខុសត្រូវលើការឲ្យបាយទឹក និងកន្លែងស្នាក់នៅក្នុងអគារសាកលវិទ្យាល័យបាត់ដំបង។ ហើយសំណួរចម្លើយ៣២ “សំណួរ៖ តើលោកដឹងថា កម្មាភិបាលថ្មីៗទាំងនេះ មកពីភូមិភាគណាដែរឬទេ? លោកឆ្លើយថា៖ ពួកគេមកពីភូមិភាគនិរតី។ ស្ត្រីភាគច្រើនមកពីអង្គភាពស្រែអំបិល។” តើលោកអាចនឹកឃើញបានទេ លោកដើមបណ្តឹងរដ្ឋប្បវេណី គឺថាមានមនុស្សប្រហែលជា៥០០ ទៅ៦០០នាក់ជាកម្មាភិបាល ដែលគេបញ្ជូនមកពីខាងនិរតីនោះ?

[១១:០២:៥៨]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកដឹងទេ ថាតើមានមេដឹកនាំបក្សមកពីខាងទីក្រុងភ្នំពេញ ឬក៏មកពីមជ្ឈិម តើពួកគាត់

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។

បានចូលរួមនៅក្នុងការបោសសម្អាត ឬក៏ការចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យ ដែលចាប់ផ្តើមនៅឆ្នាំ ៧៧ នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវនេះខ្ញុំសូមអាននូវសម្រង់មួយទៀត ពីកំណត់ហេតុស្តាប់ចម្លើយរបស់លោកដដែលនេះគឺ E3/9477។ ខ្ញុំសូមសួរលោកអ៊ីចេះវិញ ក្នុងពេលដែលគេចាប់ផ្តើមបោសសម្អាតនោះ គឺចាប់ផ្តើមបោសសម្អាតទៅលើកម្មាភិបាលពាយ័ព្យ តើលោកដឹងទេថា ប៉ុល ពត ឬក៏ នួន ជា បានមកបាត់ដំបងហើយចូលរួមប្រជុំជាមួយនឹងមេដឹកនាំខាងពាយ័ព្យ? តើលោកដឹងទេ ប្រសិនបើដឹង តើលោកអាចប្រាប់លម្អិតបន្តិចបានទេអំពីការប្រជុំនេះ?

**ឆ៖** បាទ ខ្ញុំគ្រាន់តែបានដឹង តែខ្ញុំអត់បានដឹងខ្លឹមសារនៃការប្រជុំនេះយ៉ាងដូចម្តេចឡើយ។

[១១:០៤:៥៤]

**ស៖** ខ្ញុំដឹងថាវាជារឿងកើតឡើងយូរមកហើយ ដូច្នេះ ខ្ញុំសូមអាននូវអ្វីដែលលោកបានឆ្លើយជាមួយខាងអ្នកស៊ើបអង្កេតគឺឯកសារ E3/9477។ សំណួរចម្លើយ៤៩ គឺលោកបានផ្តល់ចម្លើយដូចតទៅនេះ៖ "ខ្ញុំដឹងថា នៅពេលមានចាប់ខ្លួនម្តងៗគឺមានបញ្ជាចេញមកពីមជ្ឈិម។ មុនការចាប់ខ្លួនម្តងៗ គឺគេមានការប្រជុំដែលដឹកនាំដោយ ប៉ុល ពត ជាមួយ រស់ ញឹម។ ហើយក៏មានកិច្ចប្រជុំផ្សេងទៀតដែរដែលដឹកនាំដោយ នួន ជា គឺប្រជុំជាមួយ កន ហៅ កី។ ការប្រជុំនេះគឺធ្វើឡើងនៅផ្ទះរបស់ រស់ ញឹម ឬក៏ កន គឺដាច់ដោយឡែកពីគ្នា។"

ហើយនៅចម្លើយ៥១ និង៥២ គឺគេសួរថា៖ "តើលោកចាំបានទេ ប៉ុល ពត និង នួន ជា ទៅចូលរួមប្រជុំបែបនេះប៉ុន្មានដងក្នុងពេលនោះ? ឆ្លើយ៖ ខ្ញុំចាំបានថា នួន ជា ធ្លាប់ទៅប្រជុំនៅទីនោះបានបីដងគឺមួយដងនៅក្នុងឆ្នាំ១៩៧៦ និងពីរដងនៅក្នុងឆ្នាំ១៩៧៧។ រីឯ ប៉ុល ពត ទៅប្រជុំមួយដងក្នុងឆ្នាំ១៩៧៦ ធ្វើដំណើរតាមយន្តហោះ និងម្តងទៀតនៅក្នុងឆ្នាំ១៩៧៧។ សំណួរ៖ តើហេតុដូចម្តេចបានលោកដឹងថាកិច្ចប្រជុំនោះពិភាក្សាអំពីការចាប់ខ្លួនមនុស្ស? ឆ្លើយ៖ អ៊ំរបស់ខ្ញុំឈ្មោះ សាយ ជាអ្នកប្រាប់ខ្ញុំ ព្រោះគាត់ក៏បានចូលរួមការប្រជុំនោះដែរ។" សូមបញ្ចប់ការដកស្រង់។

តើអ្វីដែលខ្ញុំអាចហ្នឹងធ្វើឲ្យលោកនឹកឃើញដែរឬទេ? <តើ>លោក<ចាំទេ តើអ្វី>ដែល<>អ៊ំរបស់លោកឈ្មោះ សាយ បានប្រាប់<លោក>អំពីការប្រជុំដែល<ចូលរួម>ដោយ ប៉ុល ពត និង នួន ជា នោះ?

[១១:០៧:០៣]

**ឆ៖** បាទ លោក នួន ជា គាត់បានមកប្រជុំនៅសាកលវិទ្យាល័យបាត់ដំបង និងខ្ញុំបានឃើញគាត់ផ្ទាល់ ហើយគាត់ស្លៀកពាក់អាវស ខោខ្មៅ។ អាវសហ្នឹង កម្ពល។ ហើយចំណែកលោក ប៉ុល ពត ពេលដែលនិយាយតាមវិទ្យុទាក់ទង ដំបូងគេថា ប៉ុល ពត មក ពេលក្រោយមក គេថា សុន សេន ទៅវិញ។ ពេលនោះគាត់ចុះនៅព្រលានយន្តហោះបាត់ដំបង -- ព្រលានយន្តហោះបែកចាន។ ខ្ញុំចំណុចត្រង់ហ្នឹង ខ្ញុំដឹងថាគេប្រាប់ខ្ញុំថា ប៉ុល ពត មក ដល់ពេលហើយក្រោយមក ឮថាមិនមែន ប៉ុល ពត ទេ សុន សេន។ នេះជាការច្រឡំរបស់ខ្ញុំដែលនិយាយថា ប៉ុល ពត បែរជាមិនមែន ប៉ុល ពត គឺ សុន សេន ទេ។ បាទ រឿងនេះ គឺៗខាងយោធាគេប្រាប់ខ្ញុំ ហ្នឹងគឺខាងលោក សាន។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើលោក សាន ហ្នឹងជានរណាដែរ? ហើយគាត់មានតួនាទីអ្វីដែរនៅក្នុងកងទ័ពខាងពាយ័ព្យនោះ?

**ឆ៖** លោក សានៗ ហ្នឹងជាកង ទទួលបន្ទុកកងពលទី២ ហើយក្រោយមកទៀត លោក សាន បាននៅជិតនឹងខ្ញុំហ្នឹង នៅក្នុងមន្ទីរភូមិភាគ៥៦០។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកហ្នឹង គឺលោកបានបញ្ជាក់ថា អ៊ំរបស់លោក ឈ្មោះ សាយ ហ្នឹង គឺថា អ៊ំសាយ ជាអ្នកប្រាប់លោក ថាការប្រជុំហ្នឹងគឺប្រជុំទាក់ទងនឹងការចាប់ខ្លួនហ្នឹង ហើយ<ចម្លើយរបស់លោកគឺថា អ៊ំរបស់លោកឈ្មោះ សាយ ជាប្រធានមន្ទីភូមិភាគ បាន>ប្រាប់លោកអំពីការប្រជុំនោះ ព្រោះគាត់បានចូលរួមនៅក្នុងការប្រជុំនេះ។ លោកដើមបណ្ដឹង តើលោកចាំទេថា អ៊ំសាយ របស់លោកហ្នឹងប្រាប់លោកអ្វីខ្លះទាក់ទងទៅនឹងការពិភាក្សាអំពីការចាប់ខ្លួននៅក្នុងកិច្ចប្រជុំនោះ?

[១១:០៩:៥០]

**ឆ៖** បាទ ខ្ញុំចង់ជម្រាបជូនថាខ្ញុំនិយាយថា ឈ្មោះ សាន អំមិញនេះ គាត់ប្រាប់ពី ប៉ុល ពត និង សុន សេន។ កាលដំបូងខ្ញុំថា ប៉ុល ពត មក ក្រោយមក បងសាន ហ្នឹងគាត់បានប្រាប់ថាមិនមែន ប៉ុល ពត ទេគឺ សុន សេន។ ឯកិច្ចប្រជុំដែលរវាងលោក ខៀវ សំផន -- លោក នួន ជា និងលោក ប៉ុល ពត ដែលមកប្រជុំនោះគឺនុ៎ង អ៊ំសាយ ខ្ញុំ គាត់អ្នកប្រាប់ឲ្យខ្ញុំបានដឹង។

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ យើងបានពិភាក្សាគ្នារួចហើយ អំពីអ្វីដែលបានកើតឡើងចំពោះឪពុក និងអ៊ំរបស់លោក។ <>ហើយខ្ញុំក៏បាន<បង្ហាញលោក>នូវឯកសារនៃស-

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

២១ <ដែលពួកគាត់ត្រូវបានគេចាប់ខ្លួន>នៅក្នុងចុងខែមិថុនា ៧៧។ ដូច្នេះខ្ញុំចង់សួរថា ក្រោយពេលដែលឪពុករបស់លោក ហើយនិងអ៊ំរបស់លោកត្រូវបានគេចាប់ខ្លួន តើក្រោយនោះប៉ុន្មានខែដែរ ដែលលោកត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅ<ភ្នំពេញ>នោះ?

**ឆ៖** បាទ ការពិតទៅខ្ញុំ កាលពីមុនខ្ញុំចាំច្រឡំ តែបើខ្ញុំសិក្សាស្ដាប់នេះទៅគឺ ប្រហែលជាចន្លោះ ៤ខែក្រោយពីការចាប់ខ្លួន ឬក៏៣ខែ ៤ខែហ្នឹង ត្រូវបានខ្ញុំ ត្រូវបានគេចាប់ខ្លួនខ្ញុំមកភ្នំពេញដែរ។

**ស៖** អ៊ីចឹង<បើ>ឪពុក ហើយនិងអ៊ំរបស់លោកត្រូវបានចាប់ខ្លួននៅក្នុងខែមិថុនា ៧៧ ហើយលោកត្រូវបានគេចាប់ខ្លួនប្រហែលជាបីបួនខែក្រោយ។ អ៊ីចឹងប្រហែលជានៅក្នុងខែកញ្ញា ឬក៏តុលា ៧៧ គឺនៅពេលនុ៎ងឬ ដែលគេបញ្ជូនលោកមកភ្នំពេញ តើវាអ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ចុះសាច់ញាតិឪពុកលោកផ្សេងទៀតនោះ តើមានអ្វីកើតឡើងចំពោះសាច់ញាតិ ឬក៏គ្រួសារខាងឪពុករបស់លោកហ្នឹង គឺក្រោយពេលដែលគេចាប់ខ្លួន តើមានអ្វីកើតឡើងចំពោះសាច់ញាតិរបស់ឪពុកលោកដែរ?

[១១:១២:៥០]

**ឆ៖** មកដល់ថ្ងៃនេះសាច់ញាតិឪពុកខ្ញុំត្រូវបានស្លាប់អស់ ឥតមានសល់ផង។

**ស៖** តើលោកដឹងទេថា សាច់ញាតិខាងឪពុករបស់លោកហ្នឹងមានអ្វីកើតឡើង? តើពួកគាត់ត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ចោលដូចដែលគេធ្វើចំពោះឪពុកលោក និងអ៊ំលោកដែរឬទេ?

**ឆ៖** តាមសាច់ញាតិ និងអ្នករស់នៅក្នុងតំបន់ស្រុកភូមិហ្នឹង គាត់បានប្រាប់ខ្ញុំថា មានការធ្វើទុក្ខបុកម្នេញតាមចាប់ និងទៅលើពួកគាត់ហ្នឹង ហើយក្រោយមកឮថាត្រូវបានស្លាប់បាត់បង់អស់ទៅ ខ្ញុំអត់ដែលបានជួបគាត់នៅពេលដែលប្រទេសយើងចប់សង្គ្រាមរួចហើយ ទៅរកជួបជុំសាច់ញាតិក៏មិនមានឃើញសាច់ញាតិណានៅរស់ទេ។

**ស៖** ឥឡូវនេះ យើងពិភាក្សាអំពីពេលដែលគេយកលោកមកភ្នំពេញ លោកបាននិយាយអំពីការដែលគេនាំលោកយកមកសាកលវិទ្យាល័យភូមិន្ទ។ ហើយនៅព្រឹកនេះលោកបាននិយាយថា <លោកនៅទីនោះ>ប្រហែលជាពីរបីខែ មុនពេលដែលគេនាំលោកមកការប្រជុំ៣ថ្ងៃ<ដែលមាននួន ជា និយាយនៅក្នុងការប្រជុំនោះ។> ថាតើលោកធ្វើអ្វីដែរ នៅពេលដែលលោកនៅសាកលវិទ្យាល័យភូមិន្ទហ្នឹង មុនពេលដែលគេបញ្ជូនលោកមកប្រជុំជាមួយ នួន ជា នោះ?

**ឆ៖** បាទ នៅសាកលវិទ្យាល័យភូមិន្ទហ្នឹង គេគ្រាន់តែឲ្យយើងសម្រាក ហើយគេកត់ប្រវត្តិរូបសួរឈ្មោះ សាច់ញាតិ ឈ្មោះយើងធ្វើអីៗ នៅឯណា អីឯណីអីចឹងរួច រយៈពេលក្រោយមកគេបានបញ្ជូនយើងមកប្រជុំជាមួយលោក នួន ជា នេះហើយ។

[១១:១៥:៣២]

**ស៖** នៅពេលដែលគេបញ្ជូនលោកពីបាត់ដំបងមកភ្នំពេញនោះ តើមានមនុស្សដទៃគេមកជាមួយលោកដែរឬទេ គឺថាតើមានអ្នកមកពីបាត់ដំបង មកសាកលវិទ្យាល័យភូមិន្ទភ្នំពេញនោះដែរទេ? ហើយប្រសិនបើមាន តើប៉ុន្មាននាក់ដែរ ដែលគេមកជាមួយលោកនោះ?

**ឆ៖** បាទ បើតាមដែលខ្ញុំឃើញពេលនោះ បើខ្ញុំនិយាយមិនច្រឡំទេ ទាំងចាស់ ទាំងក្មេង ទាំងកម្លោះក្រមុំ ដែលនិយាយថា យុវជនយុវនារីហ្នឹង គឺដល់រយនាក់។

**ស៖** តើលោកអាចប្រាប់បានទេថា អ្នកដែលគេនាំពីបាត់ដំបងមកភ្នំពេញជាមួយលោកហ្នឹង តើពួកគាត់ទាំងអស់ហ្នឹងជាអ្នកណាដែរ?

**ឆ៖** បាទ ពួកគាត់ហ្នឹង ខ្លះជាអតីតធ្វើទាហាន ដែលមានមេ ឬក៏បងប្អូនគេចាប់ខ្លួន ត្រូវបានជាសាច់ញាតិនោះ ត្រូវគេបញ្ជូនមកដូចខ្ញុំអីចឹងដែរ។

**ស៖** អីចឹងបានន័យថា អ្នកដទៃដែលគេបញ្ជូនពីបាត់ដំបងមកភ្នំពេញហ្នឹងគឺជាមនុស្សដូចលោកដែរ គឺជាមនុស្សដែលថា សាច់ញាតិរបស់គាត់ហ្នឹងត្រូវបានគេចាប់ខ្លួនដូចលោកអីចឹងដែរ អីចឹងមែនទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ឥឡូវនេះ យើងនិយាយអំពីការប្រជុំ៣ថ្ងៃដែលលោកបានចូលរួមជាមួយនឹង ដែលនៅក្នុងការប្រជុំហ្នឹង នួន ជា បាននិយាយ។ ដូច្នេះចង់សួរថាតើ នួន ជា មកនិយាយតែម្នាក់ឯងក្នុងរយៈពេល៣ថ្ងៃហ្នឹង ឬមួយក៏ថា មានអ្នកដទៃមកនិយាយដែរ? ប្រសិនបើមានអ្នកដទៃមកថ្លែង មកនិយាយដែរ តើអ្នកដទៃហ្នឹងជាអ្នកណាខ្លះ?

[១១:១៨:១៨]

**ឆ៖** ខ្ញុំមិនស្គាល់អ្នកដទៃនោះ ថាជាអ្នកណាទេ។ ខ្ញុំស្គាល់តែលោក នួន ជា ដែលគាត់បាននិយាយរ៉ាយរ៉ាប់រឿងរ៉ាវទាក់ទងដែលគេនាំខ្លួនខ្ញុំ និងមនុស្សមកជាមួយខ្ញុំទាំងអស់គ្នាហ្នឹង ថា "បក្សយកសមមិត្តមក គឺឲ្យរួចផុតពីពួកក្បត់នៅតាមភូមិភាគ ដែលអ្នកទាំងអស់នោះប្រុងសម្លាប់សមមិត្ត ធ្វើបាបអីសមមិត្តអីចឹងទៅ។" ហើយដែលខ្ញុំចាប់អារម្មណ៍ការនិយាយរបស់លោក នួន ជា គឺសង្កត់ធ្ងន់ទៅលើ

ការ គាត់និយាយនោះ គឺថា "នាំពួកសមមិត្តមកនេះ គឺសំដៅឲ្យរួចផុតពីការសម្លាប់របស់ខ្មាំង មេកម្មា-ភិបាលដែលនៅតាមភូមិភាគនុ៎ង។ បក្សយកមកឲ្យសមមិត្តរួចផុតពីការសម្លាប់នុ៎ងឯង។" រឿងដែលខ្ញុំចាំបានច្បាស់គឺប៉ុណ្ណឹង។ ហើយក្រោយមកត្រូវបានបញ្ជូនខ្លួនខ្ញុំ និងមនុស្សទាំងអស់នោះ ចាស់ទៅផ្សេងអ៊ីចឹងទៅ ក្មេងទៅផ្សេងអ៊ីចឹងទៅ ហើយមនុស្សដែលវ័យយុវជន យុវនារីហ្នឹង គេបញ្ជូនទៅកន្លែងផ្សេងបែកៗគ្នាអស់អ៊ីចឹងទៅ។

**ស៖** តើលោកជឿ<>នួន ជា <ទេ នៅពេលគាត់>និយាយថា អ៊ំរបស់លោកជាជនក្បត់ ហើយ <មេដឹកនាំ>គេព្យាយាមការពារលោក មិនឲ្យពួកលោក ត្រូវបាន<មេដឹកនាំ>ខាងពាយ័ព្យសម្លាប់នុ៎ង តើលោកជឿទេ អ្វីដែលគេនិយាយបែបនេះ?

**ឆ៖** បាទ ខ្ញុំអត់ជឿទេ ព្រោះការនិយាយ ហើយនិងសកម្មភាពជាក់ស្តែង វាអត់ស្របគ្នា។

**ស៖** ខ្ញុំចង់បញ្ជាក់ច្បាស់បន្តិច តើ នួន ជា និយាយតែម្នាក់ឯង៣ថ្ងៃ<នៃកិច្ចប្រជុំ>ហ្នឹង? <> តើ នួន ជា គាត់និយាយប៉ុន្មាន<ថ្ងៃ ប៉ុន្មាន>ម៉ោង<ទៅកាន់លោក និងអ្នកផ្សេងទៀតដែលចូលរួមប្រជុំនោះ>? តើលោកអាចបញ្ជាក់បានទេ ទៅលើចំណុចនេះ?

[១១:២១:១១]

**ឆ៖** ខ្ញុំបញ្ជាក់មិនបានទេ នៅពេលដែលនោះ គឺខ្ញុំមានការរន្ធត់សោកសៅក្នុងចិត្ត។

**ស៖** អ៊ីចឹងមានន័យថា លោកអត់ចាំទេថា នួន ជា និយាយអស់ប៉ុន្មានម៉ោង? តើលោកអាចប៉ាន់ប្រមាណមើលថា ក្នុងរយៈពេល៣ថ្ងៃហ្នឹង តើ នួន ជា គាត់និយាយអស់ប៉ុន្មានថ្ងៃ ឬក៏អស់ប៉ុន្មានម៉ោងដែរ តើលោកចាំទេ?

**ឆ៖** បាទ ខ្ញុំមិនអាចចាំបានថា ប៉ុន្មានម៉ោងនោះទេ ប៉ុន្តែខ្ញុំដឹងថាលោក នួន ជា បានមកនិយាយកន្លែងនុ៎ងប៉ុន្មានថ្ងៃនុ៎ង ដូចខ្ញុំជម្រាបជូនអ៊ីចឹង។

**ស៖** នៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ លោកបានរៀបរាប់ គឺឯកសារ E3/5000។ ខ្មែរមានលេខ 00558234, បារាំងមានលេខ 00807151, អង់គ្លេសមានលេខ 00793364។ គឺលោកនិយាយថា៖ "នៅក្នុងសិក្ខាសាលា នួន ជា បាននិយាយអំពីឧក្រិដ្ឋភាពរបស់អ្នកដែលត្រូវបានអង្គការយកមកសម្លាប់។ ហើយប្រាប់ថា អ្នកដែលត្រូវបានសម្លាប់ហ្នឹង គឺក្បត់ជាមួយនឹងបក្ស។" តើលោកចាំទេ លោកដើមបណ្តឹងរដ្ឋប្បវេណីថា នួន ជា បាននិយាយបែបនេះ នៅក្នុងការប្រជុំដែរឬទេ ដែលថាកម្មាភិ-បាលខាងពាយ័ព្យ ត្រូវបានគេចោទប្រកាន់ថា ជាជនក្បត់ ហើយត្រូវបានគេយកទៅកម្ទេចចោលនោះ?

---

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01387029



**ឆ៖** បាទ ខ្ញុំបានចាំច្បាស់ នៅពេលដែលគាត់និយាយថា ពិសេសគឺឈ្មោះ អ៊ំសាយ និងកម្មាភិបាលនៅភូមិភាគហ្នឹង ត្រូវបានក្បត់នឹងបក្ស អ៊ីចឹងបក្សចាប់គាត់យកមក។ ហើយកម្មាភិបាលទាំងអស់នោះ បានសម្លាប់មេបក្ស ដូចជា តាទូ សាមុត អ៊ីចឹង ហ្នឹងគាត់និយាយអ៊ីចឹង។

[១១:២៤:១០]

**ស៖** តើលោកចាំទេថា<តើគាត់បាននិយាយថា> ដោយសារតែពួកគាត់ជាជនក្បត់ ទើបត្រូវបានគេសម្លាប់ គឺថាពួកខាងពាយ័ព្យដែលត្រូវបានគេចាប់ហ្នឹង ត្រូវបានគេសម្លាប់។ តើគាត់ប្រើប្រាស់ពាក្យអ៊ីចឹងមែនទេ នៅពេលដែលគាត់និយាយនោះ?

**ឆ៖** បាទ ការពិត គាត់និយាយអ៊ីចឹង។

**ស៖** <តើលោកចាំទេ -->

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាខ្ញុំគួរតែដើបឲ្យបានឆាប់បន្តិច ប៉ុន្តែខ្ញុំ<នៅតែអាចធ្វើការ>កត់សម្គាល់<បាន>។ តាមការយល់ដឹងរបស់ខ្ញុំ ទៅលើសក្ខីកម្មរបស់ដើមបណ្តឹងនេះ គឺថាគាត់ប្រើប្រាស់ពាក្យ "កម្ទេច" នៅក្នុងបរិបទមួយដែលថា អ្នកដែលត្រូវបានគេចាប់ខ្លួន គឺពួកគាត់<ជាអ្នក>បានកម្ទេច ទូ សាមុត ផងដែរ។ ហើយសំណួរបន្ទាប់មកទៀត គឺមិនមែនជាសំណួរដែលត្រឹមត្រូវចំពោះដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ។ ហើយប៉ុន្តែអ្វីដែលខ្ញុំចង់បញ្ជាក់គឺថា ទូ សាមុត ត្រូវបានគេសម្លាប់នៅក្នុងឆ្នាំ<១៩៦២ ខ្ញុំនិយាយតាមចាំ ឬឆ្នាំ១៩៦០>ឯណោះ។ ដូច្នេះ គឺវាមិនសមស្របនោះទេដែលត្រូវយកពាក្យ "កម្ទេច" មកឲ្យដើមបណ្តឹងប្រើប្រាស់ឡើងវិញ<ថា ប្រជាជន រួមទាំង>អ៊ំរបស់ដើមបណ្តឹង<ផង ត្រូវបានចាប់ខ្លួន និងកម្ទេច ដែល នួន ជា បានប្រើពាក្យនេះ>។

[១១:២៥:៥១]

**លោក ឌេល លីសាក់៖**

ខ្ញុំសួរដើមបណ្តឹងឲ្យបញ្ជាក់ច្បាស់អំពីចម្លើយដែលគាត់ឆ្លើយនៅក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ ដែលនៅក្នុងទម្រង់នោះគឺថា គាត់បានបញ្ជាក់ថា នួន ជា បាននិយាយអំពីទោសកំហុសរបស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ្នកដែលអង្គការយកទៅសម្លាប់ចោល យកទៅកម្ទេចចោលនោះ ហើយបានប្រាប់<អ្នកចូលរួមប្រជុំ> ថា <អ្នកដែលត្រូវបានសម្លាប់ទាំងនោះ>គឺជាជនក្បត់<ប្រឆាំងនឹងបក្ស>។ ហើយគាត់ក៏និយាយផងដែរអំពីហេតុផលដែល អ៊ំសាយ របស់គាត់ត្រូវបានគេចាប់ខ្លួន <ពាក់ព័ន្ធទៅនឹង>ការសម្លាប់ ទូ សាមុត ផងដែរ។ ឥឡូវនេះខ្ញុំសួរដើមបណ្ដឹងមួយសាទៀត ដើម្បីឲ្យបានច្បាស់លាស់ទាំងអស់គ្នា។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** នៅពេលដែល នួន ជា និយាយអំពីជនក្បត់មកពីខាងភូមិភាគពាយ័ព្យ រួមទាំងអ៊ំរបស់លោកផងនោះ តើ នួន ជា មានបាននិយាយថា ពួកគាត់ត្រូវបានគេសម្លាប់ដោយសារតែការចោទប្រកាន់ពីសកម្មភាពរបស់ពួកគេទាំងអស់នោះដែរឬទេ?

**2-TCCP-223៖**

**ឆ៖** សុំបញ្ជាក់ម្ដងទៀត លោកសហព្រះរាជអាជ្ញា។

**ស៖** នៅពេលដែល នួន ជា និយាយអំពីអ្នកដែលគេចោទប្រកាន់ថាជាជនក្បត់នៅភូមិភាគពាយ័ព្យហ្នឹង រួមទាំងអ៊ំរបស់លោកផងហ្នឹង តើគាត់មាននិយាយទេថា អ៊ំរបស់លោក ហើយនិងអ្នកដទៃទៀតមកពីខាងពាយ័ព្យហ្នឹង ត្រូវបានគេយកទៅកម្ទេច គឺបានន័យថា គេយកទៅសម្លាប់ដែរឬទេ?

[១១:២៧:៣០]

**ឆ៖** បាទ គាត់មិនបាននិយាយថា មនុស្សផ្សេងទៀតក្រៅពីឈ្មោះ សាយ នោះឡើយ។ ហើយមនុស្សឈ្មោះ សាយ នេះដែល នួន ជា បានចោទប្រកាន់ថា កាលពីសម័យឆ្នាំ១៩៥០ជាង ចូលមក៦០ហ្នឹង សាយ ហ្នឹងបានធ្វើជានីរសាររបស់ តាទូ សាមុត។ អ៊ីចឹង សាយ ហ្នឹងជាមនុស្សក្បត់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍ បានផ្ដល់ព័ត៌មានទៅឲ្យឈ្មោះ ទៅឲ្យអ្នកផ្សេង ឲ្យមកសម្លាប់ តាទូ សាមុត ដែលជាមេបក្សកុម្មុយនីស្ត។ មិនមែន តាទូ សាមុត នោះត្រូវបានគេសម្លាប់នៅឆ្នាំរបបកម្ពុជាប្រជាធិបតេយ្យកាន់អំណាចនោះទេ។

**ស៖** តើ នួន ជា មានបាននិយាយថា មានអ្វីកើតឡើងចំពោះ អ៊ំសាយ របស់លោក ដោយសារតែការចោទប្រកាន់ថា បានចូលរួមនៅក្នុងសកម្មភាពទាំងអស់នេះទេ?

**ឆ៖** ខ្ញុំដូចជាអត់បានដឹងលើសពីហ្នឹងទេ។

**ស៖** តើ នួន ជា មានបាន<-- លោកបាន>និយាយអំពីអ្នកពាយ័ព្យដែលត្រូវបានគេចោទប្រកាន់ថា ជាជនក្បត់<>។ ហើយតើគាត់មាននិយាយអំពីមេដឹកនាំ<បក្ស>មកពីខាង<តំបន់ផ្សេងទៀត ដូច

ជាមកពីភូមិភាគ>ឧត្តរ ឬក៏ខាងភូមិភាគផ្សេងៗទៀតដែលគេចោទប្រកាន់ថា ជាជនក្បត់ដែរឬទេ? តើលោកចាំទេថា នួន ជា គាត់មាននិយាយអំពីមេដឹកនាំនៅ<តំបន់>ដទៃទៀតដែរឬទេ<បន្ថែមទៅលើភូមិភាគពាយ័ព្យនោះ>?

**ឆ៖** បាទ នួន ជា អត់បាននិយាយមេដឹកនាំតាមភូមិភាគផ្សេងទៀតទេ។

[១១:៣០:០០]

**ស៖** នៅពេលដែលគាត់និយាយអំពីការចោទប្រកាន់ចំពោះអ៊ំ សាយ របស់លោកហ្នឹង តើគាត់មានបាននិយាយអំពីចម្លើយសារភាពរបស់អ៊ំលោក ឬក៏មនុស្សដទៃទៀតមកពីខាងពាយ័ព្យដែរឬទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** ចុះមានមនុស្សប៉ុន្មាននាក់ដែរ ដែលចូលរួមប្រជុំជាមួយលោកនៅពេលដែល នួន ជា និយាយអំពីការចោទប្រកាន់ជនក្បត់មកពីខាងពាយ័ព្យនោះ?

**ឆ៖** បាទ មានមនុស្សរាប់រយនាក់។

**ស៖** តើលោកដឹងទេថា អ្នកដទៃហ្នឹង មានអ្វីកើតឡើងចំពោះអ្នកដទៃដែលចូលរួមប្រជុំហ្នឹងដែរឬទេ គឺថាក្រោយពេលដែលប្រជុំចប់ទៅ តើពួកគាត់ហ្នឹងមានអ្វី មានរឿងហេតុអីកើតឡើងដែរ?

**ឆ៖** ក្រោយពីបានប្រជុំចប់ ច្រើនថ្ងៃច្រើនខែ អ្នកទាំងអស់ហ្នឹង ខ្លះក៏នៅរស់ ខ្លះក៏បាត់ខ្លួន។

**ស៖** តើលោកដឹងដោយរបៀបណា ថាអ្នកខ្លះគាត់បាត់<ខ្លួន>នោះ? តើលោកដឹងតាមរយៈអ្វី?

**ឆ៖** បាទ ដឹងតាមរយៈឃើញរឿងពិត នៅនឹងកន្លែងដែលខ្ញុំរស់នៅ។

**ស៖** <ដូច្នេះតើមានអ្វីបានកើតឡើង តើ>លោក<បាន>ឃើញអ្នកទាំងអស់នោះ ត្រូវបានគេយកទៅ ឬក៏លោកបានឮថា គេយកពួកទាំងនោះទៅ? តើលោកអាចប្រាប់បានទេ <តើធ្វើយ៉ាងម៉េចបានលោកដឹងថា អ្នកទាំងនោះបានបាត់ខ្លួន>?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅលើសំណួរមួយនេះ។ គឺខ្ញុំជំទាស់ទៅលើការប្រើប្រាស់ពាក្យ "បាត់ខ្លួន"។ ពាក្យ "បាត់ខ្លួន" គឺជាពាក្យមួយដែលមិនអាចបកស្រាយអ្វីឲ្យបានលម្អិតនោះទេ។ <មនុស្សអាចត្រូវបានគេ>បញ្ជូន<ខ្លួន ឬអាចត្រូវបានគេដាក់ឲ្យកាន់តំណែងផ្សេង។ ដូច្នេះការសន្និដ្ឋានជាស្វ័យប្រវត្តិថា> "<ការ>បាត់ខ្លួន" បានន័យថា <ការ>ចាប់ខ្លួន ហើយ<បន្ទាប់មកទៀតត្រូវបានគេ>សម្លាប់ហ្នឹង គឺជាការប្រើប្រាស់ដែលមិនត្រឹមត្រូវមួយ។ <ដូច្នេះ ខ្ញុំជំទាស់។>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:៣២:៤៥]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់បន្តិចទៅចុះ គឺថាខ្ញុំចង់សួរលោកអំពីអ្វីដែលលោកបានឆ្លើយនៅក្នុងពាក្យសុំ<តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី>គឺ E3/5000, ខ្មែរមានលេខ 00558234, អង់គ្លេសមានលេខ 00793364, បារាំងមានលេខ 00807151។ នេះគឺជាអ្វីដែលលោកបានឆ្លើយនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី៖ "ក្រោយពេលប្រជុំ៣ថ្ងៃនោះ ខ្មែរក្រហមបានបញ្ជូនអ្នកដែលចូលរួមហើយនិងខ្ញុំហ្នឹង<>ត្រឡប់ទៅវិញ ទៅធ្វើការទាំងយប់ ទាំងថ្ងៃ។ ការងារកន្លែងធ្វើការរបស់ខ្ញុំ គឺកង៨៧០ ដែលនៅក្រោមថ្នាក់លើ ចំណុះឲ្យថ្នាក់មជ្ឈិមរបស់ថ្នាក់លើ។" ហើយលោកនិយាយថា៖ "ហើយចំពោះអ្នកដែលសកម្មនឹងការងារ ក៏រួចខ្លួនទៅ។ ហើយអ្នកដែលមិនសកម្មនឹងការងារ គឺគេយកទៅសម្លាប់ចោលតែម្ដង។"

លោកដើមបណ្ដឹងរដ្ឋប្បវេណី ដូច្នេះខ្ញុំចង់សួរលោកថា ហេតុអ្វីបានជាលោកឆ្លើយនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកដែលថាអ្នក<ខ្លះត្រូវបាន>គេយកទៅសម្លាប់ចោល? ខ្ញុំចង់សួរថា ហេតុអ្វីបានជាលោកគិតថា អ្នក<ខ្លះត្រូវបាន>គេយកទៅសម្លាប់ចោល<>?

**2-TCCP-223៖**

**ឆ៖** បាទ ពេលនោះពាក្យស្លោកគេនិយាយថា "អ្នកដែលអសកម្ម គឺថាទុកៗ ដក -- ទុកនៅមិនចំណេញ ដកចេញមិនខាត។" អ៊ីចឹងពេលនោះ សកម្មភាពដែលកើតមាន ដូចពាក្យស្លោកដែលគេបាននិយាយនោះឯង។ អ្នកដែលធ្វើការមិនសកម្ម ធ្វើតាមមិនទាន់ផែនការ អ្នកដែលឈឺច្រើន ក្នុងមួយខែឈឺប្រាំដង ប្រាំមួយដង មិនបានបំពេញកិច្ចការងារជាប់លាប់ គេថា អ្នកនោះមិនជាអ្នកសកម្ម ធ្វើឲ្យផែនការរបស់បក្សមិនបានសម្រេច។ អ៊ីចឹងមនុស្សទាំងអស់នោះ មិនយូរមិនឆាប់នឹងត្រូវបានគេនាំខ្លួនចេញពីកន្លែងដែលខ្ញុំរស់នៅនោះទៅបាត់ទៅ។ អ៊ីចឹងអត់ដឹងថាគេយកសម្លាប់ ឬក៏គេយកធ្វើម៉េចទេ តែដឹងថាគេដកអ្នកទាំងអស់ហ្នឹង បញ្ជូនអ្នកទាំងអស់ហ្នឹងទៅបាត់ទៅ។

[១១:៣៥:២៥]

**លោក ខេល លីសាក់៖**

សូមអរគុណច្រើនលោកដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដលម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

តាមកាលវិភាគបានកំណត់ នៅរសៀលនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-842 តាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង។ ហើយដោយសារបញ្ហានៅរសៀលនេះ មិនមានភាព ទាន់ភាពច្បាស់លាស់អំពីបញ្ហានៃដំណើរការស្តាប់សក្ខីកម្មសាក្សីតាមប្រព័ន្ធសោតទស្សន៍ ក៏ដូចជាសាក្សីបម្រុង ដែលយើងយើងយកមកបម្រុងទុកកាលពីព្រឹកមិញនេះ គាត់មានបញ្ហាសុខភាព។ ហេតុដូច្នេះហើយ ដើម្បីឲ្យប្រាកដហ្នឹង គឺអង្គជំនុំជម្រះសូមរក្សាទុកដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅរសៀលនេះសិន កុំអាលទាន់បញ្ជូនគាត់ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ។ ជាគោលការណ៍ គឺគាត់នឹងធ្វើសវនាការស្តាប់សក្ខីកម្មបន្តនៅព្រឹកថ្ងៃស្អែកទេ ប៉ុន្តែដោយសារមានបញ្ហាដូចខាងលើនេះ អង្គជំនុំជម្រះសូមឲ្យខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញរក្សាទុកគាត់សិន រហូតដល់ពេលរសៀលនេះយើង ដើម្បីបម្រុងទុក ថាប្រសិនបើដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សីតាមរយៈប្រព័ន្ធសោត-ទស្សន៍ពីប្រទេសបារាំងមិនអាចធ្វើបាន ហើយសាក្សីបម្រុង ដែលយើងយកមកបម្រុងទុកនេះ គាត់មានបញ្ហាសុខភាពមិនអាចផ្តល់សក្ខីកម្មបាននោះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបញ្ចប់។

ហើយនៅក្នុងអំឡុងពេលនេះ គឺបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹង -- ក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់នេះ ឲ្យគាត់នៅសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងរង់ចាំស្តាប់បទបញ្ជាពីយើងនៅរសៀលនេះ ដើម្បីថាតើត្រូវបន្តស្តាប់សក្ខីកម្មរបស់គាត់ ឬក៏ឲ្យបញ្ជូនគាត់ទៅកន្លែងគាត់ស្នាក់នៅ។

ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៧ នាទី ដល់ម៉ោង ១៣:៥៨នាទី)*

[១៣:៥៨:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅរសៀលនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-842 តាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង។

លោកស្រី សែ កុលវុឌ្ឍី តើដំណើរការរៀបចំប្រព័ន្ធបច្ចេកទេសសោតទស្សន៍សម្រាប់ដំណើរការសវនាការនាពេលនេះ បានរៀបរយហើយឬនៅ?

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន ខាងបច្ចេកទេសសោតទស្សន៍បានរៀបចំរួចរាល់អស់ហើយ ហើយសាក្សីបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្តល់សក្ខីកម្មនៅពេលនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ស្ួស្តីលោកស្រីៗសាក្សី!

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** ជម្រាបសួរតេជគុណ លោកប្រធាន។

[១៣:៥៩:៣៧]

**ស៖** អរគុណ។ ហើយតើលោកស្រីឈ្មោះអី លោកស្រីអាចប្រាប់នាមត្រកូល និងនាមខ្លួនលោកស្រីបានដែរឬទេ?

**ឆ៖** ត្រកូលខ្ញុំឈ្មោះ ធុច – ធុច ស៊ីថន។

**ស៖** បាទ អរគុណ។ ហើយលោកស្រី ធុច ស៊ីថន តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា? លោកស្រីអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ?

**ឆ៖** ចាស ខ្ញុំកើតនៅថ្ងៃទី ខែមករា ១៩៥៥។

**ស៖** បាទអរគុណ។ ហើយអាសយដ្ឋាន ទីកន្លែងដែលលោកស្រីរស់នៅសព្វថ្ងៃនោះ រស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំនៅប៉ារីស។ ទី២០ ខ្ញុំនៅប៉ារីស។

**ស៖** បាទ អរគុណ។ ហើយតើលោកស្រីប្រកបមុខរបរធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំខាងគិតលុយនៅកន្លែងសាកលវិទ្យាល័យខាងវិស្វករ។

**ស៖** បាទ ហើយចុះឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ធុច ឈិត, ម្ដាយឈ្មោះ ហាក់ អ៊ុន។

[១៤:០៦:០១]

**ស៖** បាទអរគុណលោកស្រី ធុច ស៊ីថន។ ក្នុងឋានៈលោកស្រីជាសាក្សីដែលត្រូវផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ អង្គជំនុំជម្រះតម្រូវឲ្យលោកស្រីធ្វើសម្បថ ឬក៏ធ្វើសច្ចាប្រណិធាននៅតាមជំនឿរបស់លោកស្រីជាមុនសិន តើលោកស្រីយល់ព្រមដែលឬទេ?

**ឆ៖** ចាស ខ្ញុំយល់ព្រម។

**ប្រធានអង្គជំនុំ៖**

ហើយលោកស្រី សែ កុលវុឌ្ឍី ណែនាំសាក្សីធ្វើសម្បថ ឬធ្វើសច្ចាប្រណិធាន។

**លោកស្រី ធុច ស៊ីថន៖**

ខ្ញុំត្រូវអានក្រដាសហ្នឹង?

**ក្រឡាបញ្ជី៖**

ចាស ជម្រាបសួរលោកស្រី។ តទៅនេះខ្ញុំនឹងរៀបចំនីតិវិធីសម្រាប់--

**លោកស្រី ធុច ស៊ីថន៖**

ជម្រាបសួរ!

**ក្រឡាបញ្ជី៖**

ចាស សម្រាប់លោកស្រី ហើយខ្ញុំនឹងអាននូវពាក្យសម្បថទាំងអស់នេះ ហើយចាំលោកស្រីនិយាយតាមខ្ញុំ។ ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងនិយាយតែការពិត ការពិតទាំងអស់ ហើយនិងមិននិយាយអ្វីក្រៅតែពីការពិតនោះទេ។ សូមលោកស្រីនិយាយ។

**លោកស្រី ធុច ស៊ីថន៖**

ខ្ញុំថាតាម?

[១៤:០២:០៧]

**ក្រឡាបញ្ជី៖**

ចាស។

**លោកស្រី ធុច ស៊ីថន៖**

ខ្ញុំថាតាមក្ដួយ។

**ក្រឡាបញ្ជី៖**

ចាសៗ សូមលោកស្រីនិយាយនូវពាក្យទាំង សម្បថអម្បាញ់មិញនេះ។

**លោកស្រី ធុច ស៊ីថន៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងនិយាយតែការពិត ការពិតទាំងអស់ ហើយនិងមិននិយាយអ្វីក្រៅតែពីការពិតនោះទេ។

**ក្រឡាបញ្ជី៖**

ចាស សូមអរគុណលោកស្រី។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រី ធុច ស៊ីថន តាមសមត្ថភាពដែលលោកស្រីអាចដឹង តើលោកស្រីមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ឬក៏បុគ្គលទាំងឡាយដែលទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះដែរឬទេ?

[១៤:០២:៤៧]

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** ចាស ខ្ញុំអត់មានទាក់ទងអីទាំងអស់។

**ស៖** បាទអរគុណ។ ក្នុងឋានៈលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏សូមឱ្យលោកស្រីធ្វើអត្ថាធិប្បាយរៀបរាប់ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ករណីយកិច្ច ក្នុងឋានៈជាសាក្សី លោកស្រីត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះ

សួរចំពោះលោកស្រី។ ហើយលោកស្រីត្រូវឆ្លើយតែការណ៍ណាដែលពិត ដែលលោកស្រីបានដឹងបានឮ បានឃើញបានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។

លោកស្រី ធុច ស៊ីថន តើលោកស្រីធ្លាប់បានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងពេលកន្លងមក? ហើយប្រសិនបើធ្វើ ៗប៉ុន្មានដង? ធ្វើនៅទីកន្លែងណាដែរ លោកស្រីចាំដែរទេ?

[១៤:០៣:៥៥]

**ធ៖** ចាស ខ្ញុំធ្វើម្តងនៅប៉ារីស ឆ្នាំ២០០៩ ម្តង។

**ស៖** បាទអរគុណ។ ហើយមុនពេលចូលមកទីកន្លែងនោះ មុនដើម្បីផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ តើលោកស្រីបានពិនិត្យមើលឬក៏បានអាននូវកំណត់ហេតុដែលលោកស្រីផ្តល់កិច្ចសម្ភាសន៍កាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេតនៅទីក្រុងប៉ារីស ដើម្បីរំឭកការចងចាំដែរឬទេ?

**ធ៖** ចាស ខ្ញុំបានមើលខ្លះចាស។

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង តើលោកស្រីអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុស្តាប់ចម្លើយដែលលោកស្រីបានអានដើម្បីរំឭកការចងចាំនោះ គឺវាពិតត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងសក្ខីកម្ម ដែលលោកស្រីបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ធ៖** ពួកអ្នកស៊ើបអង្កេតគេមកជួបខ្ញុំ ២០០៩ ខ្ញុំបាននិយាយ ហើយអត់មានការខុសទេ។ ប៉ុន្តែកន្លែងមួយខុស នៅពេលឆ្នាំ២០០៦ នៅពេលដែលខ្ញុំមកស្រុកខ្មែរលើកទី១ មានអ្នកធ្វើការនៅខាងតុលាការ មកជួបខ្ញុំនៅឆ្នាំ២០០៦ ហើយខ្ញុំបាយនៅភោជនីយដ្ឋានមួយ។ គាត់គ្រាន់ថាចង់សួរខ្ញុំដើម្បីសួរជាពាក្យ ជាសំណួរខ្លះ។ ខ្ញុំអានយប់មិញ ឃើញកន្លែងខ្លះអត់ត្រូវទាំងអស់ទេ ពីព្រោះគាត់អត់មានបញ្ជាក់ខ្ញុំថា អត់មានបញ្ជាក់ខ្ញុំថា តើសំណួរឲ្យអស់សេចក្តីទេ ប៉ុន្តែគាត់មានកត់ទុក កត់សម្តីរបស់ខ្ញុំ។ ដូច្នេះក្នុងជាអក្សរខ្មែរហ្នឹង បញ្ហាខ្លះអត់មានត្រូវទេ អត់ត្រូវទាំងអស់ទេ គាត់អត់មាននិយាយការប្រាប់ខ្ញុំថា ហៅខ្ញុំទៅដើម្បីសួរយ៉ាងម៉េចទេ គាត់លាក់ គាត់កត់។ ដូច្នេះខ្ញុំមើលឡើងវិញ អត់ត្រូវទាំងអស់ទេ។ ខ្ញុំសូមកែ នៅ២០០៦ *ឌុកគុម៉ង់* នៅឆ្នាំ២០០៦។

[១៤:០៦:៣០]

**ប្រធានអង្គជំនុំ៖**

អរគុណៗលោកស្រី។ លោកស្រីគ្រាន់តែអ៊ីចេះ ជាមូលដ្ឋាន ជាមូលដ្ឋានរួម ជាទូទៅហ្នឹង តើលោកស្រីពិនិត្យមើលហ្នឹង ថាតើការផ្តល់សក្ខីកម្មរបស់លោកស្រីហ្នឹង គឺត្រឹមត្រូវទាំងអស់ដែរឬទេ លើកលែងតែចំណុចខ្លះបន្តិចបន្តួចប៉ុណ្ណោះ ដែលវាមានបញ្ហា មានកំហុសដែលវាមិនសមស្រប ទៅនឹងរឿងហេតុដែលជាក់ស្តែងដែលលោកស្រីបានផ្តល់សក្ខីកម្ម អ៊ីចឹងមែនទេ?

**លោកស្រី ធុច ស៊ីថន៖**

ចាស ទាំងអស់ប្រហែល -- ចាសៗ ត្រូវសឹងទាំងអស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ធុច ស៊ីធឿន -- ធុច ស៊ីថន មុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

[១៤:០៨:២៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជម្រាបសួរលោកស្រី ធុច ស៊ីថន។

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** ជម្រាបសួរ!

**ស៖** បាទ សូមអរគុណ។ ខ្ញុំនឹងសួរសំណួរលោកស្រីនៅរសៀលនេះ ហើយក៏ប្រហែលជា៣០នាទីនៅថ្ងៃស្អែកទៀត។ ដូច្នេះ សូមឲ្យលោកស្រីឆ្លើយខ្លីៗបានហើយ។ បើខ្ញុំចង់ដឹងលម្អិត ខ្ញុំនឹងសួរ

សំណួរបន្ថែម។ បាទ មិនអីទេ លោកស្រីអាចនិយាយខ្មែរបាន តើបើសិនលោកស្រីចង់និយាយជាភាសាបារាំងក៏បានដែរ លោកស្រីអាចស្នើសុំទៅលោកប្រធានទៅ។ ខ្ញុំមានប្រធានបទបី ដើម្បីសួរលោកស្រីគឺពាក់ព័ន្ធនឹងការរៀបការរបស់លោកស្រី ហើយនិង<ការប្រជុំ> ជាពិសេសគឺតួនាទីរបស់ នួន ជា, ខៀវ សំផន ហើយនិងការបាត់ខ្លួនមនុស្សនៅក្រសួងសង្គមកិច្ច។ ដូច្នេះខ្ញុំនឹងសួរទៅលើចំណុចទាំងអស់នេះ។ ជាដំបូងខ្ញុំចង់សួរអំពីអតីតកាលរបស់លោកស្រី និងអ្វីដែលលោកបានធ្វើនៅសម័យនោះ ជាពិសេសនៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩។ សំណួរដំបូង លោកស្រីអាចជម្រាបបានទេ ថាលោកស្រីបានចូលបដិវត្តន៍ <នៅពេលណាមុនឆ្នាំ១៩៧៥នោះ> ហើយហេតុអ្វីបានជាលោកស្រីសម្រេចចិត្តចូលបដិវត្តន៍? ខ្ញុំមិនសួរឱ្យលោកស្រីឆ្លើយវែងឆ្ងាយពេកទេ សូមលោកស្រីឆ្លើយខ្លីៗបានហើយ។

[១៤:០៩:២៩]

**លោកស្រី ធុច ស៊ីថន៖**

**ធ៖** ខ្ញុំឆ្លើយ? សូមទោស ខ្ញុំឆ្លើយជាខ្មែរ ឬជាបារាំង?

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះលោកស្រីសម្រេចចិត្តខ្លួនឯង តើលោកស្រីសម្រេចថា ជ្រើសរើសភាសាណាមួយដែលលោកស្រីងាយក្នុងការឆ្លើយ ព្រោះលោកស្រីចេះភាសា ទាំងពីរភាសា។ តែទំនងជាលោកស្រីមិនសូវប្រើភាសាខ្មែរ តាមមើលនិយាយទៅ វាពិបាកស្តាប់ដែរ ព្រោះលោកស្រីពិបាកនិយាយខ្លួនឯង។ អ៊ីចឹងលោកស្រីអាចជម្រើសមួយណាក៏បានដែរ ឱ្យតែនិយាយតែមួយភាសាបានហើយ ឱ្យតែលោកស្រីសម្រេចជ្រើសរើស យើងផ្តល់លទ្ធភាពឱ្យជូនលោកស្រីតាមការជ្រើសរើសរបស់លោកស្រី។

**លោកស្រី ធុច ស៊ីថន៖**

**ធ៖** សូមអរគុណតេជគុណ លោកប្រធាន។ (និយាយជាភាសាបារាំង)៖ នៅសម័យនោះ ខ្ញុំ <បានចេញទៅ ព្រោះបងថ្លៃស្រីរបស់ខ្ញុំបានហៅ>ខ្ញុំ។ <>ពេលហ្នឹងខ្ញុំអាយុ១៦ឆ្នាំ។ គាត់បានមកប្រាប់សុំម្តាយខ្ញុំ ដើម្បីនាំខ្ញុំទៅ<តាមគាត់> ព្រោះថាគាត់មានកូនបីនាក់តូច<ៗ។ កូនក្មេង>ជាងគេហ្នឹង៣ឆ្នាំ បន្ទាប់មក៥ឆ្នាំ និងកូនមួយទៀតគឺអាយុ៧ឆ្នាំ។ គាត់មកសុំម្តាយខ្ញុំឱ្យទៅជាមួយគាត់ <ដើម្បីជូនទៅជួប>បងប្រុសរបស់ខ្ញុំ ដែលជាប្តីគាត់។--

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ លោកស្រី ខ្ញុំសូមកាត់ចម្លើយលោកស្រី។ លោកស្រីអាចនិយាយបាន មិនចាំបាច់

ឈប់ទេ ព្រោះថាយើងមានការបកប្រែជាភាសាខ្មែរ និងអង់គ្លេសហើយ។ លោកស្រីស្ដាប់ជាភាសាបារាំងតែម្ដងទៅ អ៊ីចឹងលោកស្រីមិនបាច់និយាយឈប់ និយាយឈប់អ៊ីចឹងទេ លោកស្រីអាចនិយាយទៅរហូតតែម្ដងបាន។

[១៤:១១:៥៥]

**ឆ៖** ចាស១។ (និយាយជាភាសាបារាំង)៖ អ៊ីចឹងហើយ ខ្ញុំចេញទៅជាមួយបងថ្លៃខ្ញុំនៅសម័យនុ៎ង។ អ៊ីចឹង<នេះជាមូលហេតុដែល>ខ្ញុំចូលព្រៃជាមួយនឹងបងថ្លៃខ្ញុំ ហើយនិងបងប្រុសខ្ញុំ។ ជាដំបូងខ្ញុំគិតថា <អ្វីដែលខ្ញុំត្រូវធ្វើ គឺ>ខ្ញុំគ្រាន់<តាម>គាត់ទៅទេ គ្រាន់តែទៅជាមួយគាត់ទេ គឺថាខ្ញុំមិន<បាន>គិតថា <ខ្ញុំមិនអាចត្រឡប់មកវិញបាន>អ៊ីចឹងទេ។

**ស៖** តើបងប្រុសរបស់លោកស្រីហ្នឹង ឈ្មោះ ធុច រិន ហៅ គ្រិន ហ្នឹងមែនទេ ដែលក្រោយមក<ក្រោយឆ្នាំ១៩៧៥ ជាប្រធានកំពង់ផែកំពង់សោម?>

**ឆ៖** ចាស

**ស៖** --គាត់ជាប្រធានកំពង់ផែ កំពង់សោមហ្នឹង?

**ឆ៖** ចាស គាត់ឈ្មោះ ធុច គ្រិន ចាស១។ (អ្នកបកប្រែ)៖ ចាស គឺគាត់ហ្នឹងហើយ។ (និយាយជាភាសាបារាំង) ត្រូវហើយ គឺគាត់ហ្នឹងហើយ។

**ស៖** លោកស្រីចូលបដិវត្តន៍នៅឆ្នាំ៧២មែនទេ?

**ឆ៖** ចាស នៅឆ្នាំ៧២។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសួរអំពីអ្វីដែលលោកស្រីបានធ្វើ ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥។ ពេលនុ៎ង លោកស្រីមានមុខងារអ្វីខ្លះ ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥ហ្នឹង? ហើយលោកស្រីធ្វើការនៅកន្លែងណា?

**ឆ៖** មុនដំបូងនៅពេលដែលបែកភ្នំពេញ ខ្ញុំត្រូវទៅនៅពេទ្យរុស្ស៊ី <>ព្រោះពួកពេទ្យ គេ<តម្រូវឱ្យ>ទៅពេទ្យរុស្ស៊ី។ ហើយខ្ញុំធ្វើការប្រហែលជាពីរបីខែរៀបចំថ្នាំពេទ្យ ពីព្រោះជំនាន់នោះ អត់មាន<អ្នក>ចេះភាសាបារាំង<ច្រើនទេ>។ បានទេ? ខ្ញុំបន្តទៅទៀត?

[១៤:១៤:២៣]

**លោកស្រី ហ្គីរ៉ូដ៖**

<ខ្ញុំគិតថាមានបញ្ហាមួយ។>

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** យើងពិបាកបន្តិច ព្រោះថាដូចលោកស្រីឆ្លើយមួយឃ្លាអ៊ីចឹងទៅ លោកស្រីឈប់មួយសន្ទុះ ហើយ លោកស្រីនិយាយតទៅទៀត អ៊ីចឹងខ្ញុំបានប្រាប់អំមិញហើយថា មិនបាច់ឈប់ ឆ្លើយឈប់ ឆ្លើយឈប់អ៊ីចឹងទេ លោកស្រី។ លោកស្រីអាចឆ្លើយទៅតែម្តងទៅ គេបកប្រែទន្ទឹមគ្នាហ្នឹងហើយ។ ឥឡូវនេះខ្ញុំចង់--

**លោកស្រី ធុច ស៊ីថន៖**

**ធ៖** ចាសៗ សូមទោស ខ្ញុំអត់--

**ស៖** -- ដឹងថា លោកស្រីធ្វើកន្លែងមន្ទីរពេទ្យហ្នឹង មន្ទីរពេទ្យហ្នឹងនៅក្រោមក្រសួងអីដែរ លោកស្រី?

**ធ៖** ក្រសួងមន្ទីរពេទ្យៗ ព្រោះពីដើម ខ្ញុំធ្វើការជាមួយលោក ឌី ផុន *ដង់ទីស្ត*។ ដល់ពេលគេបែកទៅ អ្នកដែលគេធ្វើការជាមួយគាត់ ត្រូវទៅមន្ទីរពេទ្យ នៅពេទ្យរុស្ស៊ី។ ខ្ញុំធ្វើការបាន៣ខែ ខ្ទង់ប៉ុណ្ណឹងដែលមានរៀបចំពេទ្យ គេអត់ឲ្យខ្ញុំធ្វើការក្នុងពេទ្យទៀតទេ ព្រោះគេត្រូវការមនុស្សដើម្បីរៀបចំអ្នកចេះអក្សរបារាំងដើម្បីរៀបចំថ្នាំពេទ្យ។ ខ្ញុំរៀបចំថ្នាំពេទ្យ ខ្ទង់ប្រហែល៣ខែ បានរៀបចំស្រួលបួលអ៊ីចឹងទៅ ព្រោះថ្នាំពេទ្យ ទៅតាមឈ្មោះរបស់វា។ បន្ទាប់ពី៣ខែហ្នឹងមក គេក្រសួងសង្គមកិច្ចចាប់ផ្តើមត្រូវការមនុស្ស។ ដោយខ្ញុំធ្វើការនៅមន្ទីរពេទ្យ ខ្ញុំរៀបថ្នាំមានគ្នាពីរនាក់ មានអ្នកទទួលខុសត្រូវដូចខ្ញុំពីរនាក់។ ហើយដូច្នេះគេទុកម្នាក់នៅនុ៎ង គេឲ្យខ្ញុំទៅក្រសួងសង្គមកិច្ច ដើម្បីរៀបចំថ្នាំពេទ្យ ព្រោះសង្គមកិច្ចត្រូវការប្រមូលថ្នាំពេទ្យដែលនៅពាសពេញ នៅភ្នំពេញយកមកទុកនៅក្នុងក្រសួង។ នៅពេលដែលខ្ញុំធ្វើការដំបូងបីនាក់ មានគ្នាបី។ បងស្រីម្នាក់គាត់ *ហ្វាម៉ាស្យែន* គាត់ខាង *ហ្វាម៉ាស្យែន* ឯខ្ញុំពីរនាក់ ប្អូនស្រីម្នាក់ទៀតស្រករៗគ្នា ក្មេងហ្នឹង ទៅរើសថ្នាំ កត់ថ្នាំនៅមន្ទីរពេទ្យ។ កូនគាត់ជា *ហ្វាម៉ាស្យែន* គាត់ស្គាល់កន្លែង គេធ្វើកន្លែងហ្វាម៉ាស៊ី គាត់នាំខ្ញុំទៅកត់ៗ ដើម្បីធ្វើស្ថិតិ មានថ្នាំអីខ្លះ ថ្នាំអីនៅកន្លែងណាៗខ្លះ។ អត់ទាន់បញ្ជូនមកសង្គមកិច្ចទេ គ្រាន់តែកត់ ពេលនុ៎ងពួកខ្ញុំបីនាក់។

[១៤:១៧:០៦]

**ស៖** <សូមអរគុណ-->

**ធ៖** បន្ទាប់មក--

**ស៖** បាទ ខ្ញុំសូមកាត់ចម្លើយលោកស្រី ដើម្បីសួរសំណួរមួយចំនួន<ទៀតទៅកាន់លោកស្រី។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាបឋម>ពាក់ព័ន្ធនឹង<ការងារលោកស្រីនៅ>មន្ទីរពេទ្យ<រុស្ស៊ី។ ខ្ញុំជឿថា> គេហៅ<មន្ទីរពេទ្យនុ៎ង> ថា មន្ទីរពេទ្យ១៧មេសា <នៅពេលនោះ>។ ខ្ញុំចង់ដឹងថា អ្នកណាជាមេផ្ទាល់របស់លោកស្រីនៅមន្ទីរពេទ្យ១៧មេសាហ្នឹង? ហើយអ្នកណាជាប្រធានធំរបស់មន្ទីរពេទ្យនុ៎ង?

**ឆ៖** អ្នកប្រធានធំដំបូង ជាប្រពន្ធលោក ទីវ អុល។ លោក ទីវ អុល បាត់ខ្លួន បាត់ឮឈ្មោះខ្លួន បាត់ឈ្មោះគាត់តាំងដំបូងមក ហើយប្រពន្ធគាត់នៅជាប្រាំប្រាំមួយខែ នៅមន្ទីរពេទ្យហ្នឹង។ ហើយអ្នកទទួលខុសត្រូវខ្ញុំ ខ្ញុំនៅតែពីរនាក់ទេ នៅខាងហ្វាម៉ាស៊ីហ្នឹង មានតែពីរនាក់ទេ ហើយខ្ញុំជាអ្នកអែបគាត់ជួយគាត់។

**ស៖** លោកស្រីអាចជម្រាបឈ្មោះអ្នកទទួលខុសត្រូវរបស់លោកស្រី ហើយនិងឈ្មោះប្រពន្ធទីវ អុល បានទេ?

**ឆ៖** ឈ្មោះបងសី <>ឈ្មោះគាត់នៅក្នុងបដិវត្តឈ្មោះ បងសី។ មានឈ្មោះពិតប្រាកដ ខ្ញុំមិន -- អត់ចាំ ចាំច្បាស់ទេ ឈ្មោះ--។ បន្ទាប់មក ប៉ុន្មានខែមកគាត់បាត់ខ្លួនមុន ខ្ញុំចេញពី មុននឹងខ្ញុំចេញពីហ្នឹងមក អត់ឮឈ្មោះគាត់ទៀតដែរ។ ខ្ញុំនៅ ធ្វើការនៅសង្គមកិច្ច ខ្ញុំនៅធ្វើការក្រោមការទទួលខុសត្រូវរបស់បងស៊ូ។ ហើយក្រសួង អ្នកទទួលខុសត្រូវលើ បងស៊ូ គឺ*ម៉ាដាម* អៀង ធីរិទ្ធ ឈ្មោះ មីងភា។ នៅទីនោះខ្ញុំចាត់ចែងថ្នាំពេទ្យ ព្រោះខ្ញុំ គេត្រូវការខ្ញុំចេះភាសាបារាំង រៀបចំថ្នាំពេទ្យ។ ថ្នាំពេទ្យដែលខ្ញុំកត់ប៉ុន្មានដែលជាមួយបងហ្វាម៉ាស៊ី ហ្នឹងបងហ្វាម៉ាស្សែនហ្នឹង គាត់ មិនដឹងគាត់ទៅណាដែរ ខ្ញុំអត់ឃើញ អត់បានដំណឹងពីគាត់ដែរ ប៉ុន្តែពេលនុ៎ងខ្ញុំទៅជាមួយប្អូនៗផ្សេងទៀត ទៅយកថ្នាំពេទ្យដែលនៅក្នុងភ្នំពេញហ្នឹងមកទុកនៅក្រសួងសង្គមកិច្ច។

[១៤:១៩:៥៤]

**ស៖** សូមអរគុណលោកស្រី។ ឥឡូវខ្ញុំនិយាយពី បងសី។ លោកស្រីនិយាយថា ក្រោយពីប្តីគាត់បាត់ខ្លួនទៅ គាត់នៅធ្វើការនៅមន្ទីរពេទ្យហ្នឹងប្រាំប្រាំមួយខែ គឺមន្ទីរពេទ្យ១៧មេសា។ លោកស្រីចាំទេថា បងសី ហ្នឹងគាត់បាត់ខ្លួននៅពេលណាដែរ? លោកស្រីសុំឆ្លើយខ្លីៗទៅបានហើយ។

**ឆ៖** បាត់ប្រហែលជាបីបួនខែក្រោយពីថ្ងៃ១៧ មករាមក ព្រោះខ្ញុំចេញ មកប្រហែលបាត់ស្រករៗខ្ញុំ<ចេញដែរ។> ព្រោះខ្ញុំនៅពេលដែល នៅពេលដែលខ្ញុំនៅនោះ ខ្ញុំចាំ គាត់ទឹកមុខគាត់ អត់ -- គាត់មានទុក្ខ។ ដឹងថាគាត់មានទុក្ខ ប៉ុន្តែខ្ញុំមិនដឹងបញ្ហាអីដែរ ព្រោះអីតាមមើល គាត់ដឹងថាប្តីគាត់បាត់ខ្លួន។ ខ្ញុំឃើញគាត់មានទុក្ខ គាត់អត់និយាយអីទេ។ ខ្ញុំយល់ថា គាត់មានការបារម្ភចំពោះខ្លួនរបស់គាត់។ ហើយ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាំងពីនោះ ខ្ញុំចេញពីមន្ទីរពេទ្យមក ខ្ញុំអត់ដែលមានទាក់ទងអ្នកនៅធ្វើការនៅ<កន្លែងចាស់>ទៀតទេ។

**ស៖** ក្រោយមកទៀតហ្នឹង លោកស្រីដឹងថា សី ដែលជាប្រធានមន្ទីរពេទ្យហ្នឹងត្រូវបានគេចោទប្រកាន់ពីបទអីទេ? ហើយ<តាមលោកស្រីប្រាប់យើងគឺថា> អៀង ធីរិទ្ធ <ហើយនិង> ស៊្វ <គឺ>ជាអ្នកទទួលខុសត្រូវរបស់លោកស្រីហ្នឹង មានបាននិយាយថា គាត់ហ្នឹង បងសី ហ្នឹងក្បត់បក្សទេ?

**ឆ៖** ខ្ញុំអត់បានដឹងអីប្រាកដច្បាស់ទេ។ គេអត់ដែល បញ្ហារឿងចាប់ខ្លួន ចាប់អី ខ្ញុំអត់ដឹង។ គ្រាន់ថា ឮគេនិយាយថា អត់មានដូច -- លែងៗឈ្មោះ បងសី ហ្នឹងនៅមន្ទីរពេទ្យ អត់ឮឈ្មោះគាត់ទេ។ ប៉ុន្តែបាត់នៅក្នុងលក្ខខណ្ឌអី ដូរការងារ ឬបាត់ខ្លួនដោយអី ខ្ញុំអត់ដឹងផង។

[១៤:២២:១៩]

**ស៖** លោកស្រីនិយាយអំពីពេលដែលគាត់បាត់ខ្លួនគឺថា ប្រហែលជាបីបួនខែក្រោយថ្ងៃទី១៧មេសា។ នៅក្នុងសំណុំរឿង យើងមានចម្លើយសារភាពរបស់ សី នៅស-២១ ដែលឈ្មោះ ឡេង ស៊ីមហាក់ ហៅ សី ជាឈ្មោះបដិវត្តន៍ ប្រធានមន្ទីរពេទ្យ១៧មេសា ប្រពន្ធរបស់ ទីវ អុល។ គាត់មានអាយុ៣៨ឆ្នាំ។ ចំពោះភាគី ឯកសារនេះគឺ E3/2936 ចម្លើយសារភាពហ្នឹងគឺមាន៣១៨ទំព័រ ហើយក្នុងនេះគេដាក់ថា ចាប់នៅថ្ងៃទី១៧ <ធ្នូ> ឆ្នាំ៧៧ កម្ទេចចោលនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៨។ មានផ្នែកផ្សេងទៀតនៃចម្លើយសារភាពរបស់គាត់ គឺមាននៅក្នុងឯកសារលេខ E3/4377 និង E3/1857។ម្យ៉ាងទៀតមានបញ្ជីជាច្រើននៃអ្នកទោសស-២១ ដែលបានបង្ហាញឈ្មោះរបស់គាត់។ ទី១គឺឯកសារ E3/2276 ERN ជាភាសាអង់គ្លេស 00887842 និងជាភាសាខ្មែរ <00048788> មិនមានជាភាសាបារាំងទេ។ ក្នុងនោះគេដាក់ថា គាត់ចូលនៅស-២១ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៧។ លោកស្រីសាក្សី លោកស្រីនឹកឃើញឡើងវិញទេថា សី មិនត្រូវបានចាប់ខ្លួបីបួនខែក្រោយថ្ងៃទី១៧ មេសាទេ គឺយូរមកទៀតនោះ បានគាត់ត្រូវបានគេចាប់ខ្លួន?

**ឆ៖** ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំអត់មានការទាក់ទងគេ អត់មានទាក់ទងនៅខាងមន្ទីរពេទ្យទៀតដែរ។ ខ្ញុំអត់ -- តាមខ្ញុំយល់ ដូចជាគាត់បាត់ អត់ឮឈ្មោះគាត់និយាយតាំងពីដែលខ្ញុំចេញពីសង្គមកិច្ចមក។ ប្រាកដទេ ឬក៏ជួនណា គេយកទៅដាក់នៅកន្លែងណាមួយសិន ហើយបានគេបញ្ជូនទៅ*អេស-ទ្វាំងតេអេងអាប់ប្រែ*។ តើបញ្ហាហ្នឹងប្រាកដទេ? ប៉ុន្តែតាមខ្ញុំ តាំងពីខ្ញុំចេញមកមន្ទីរសង្គមកិច្ច ខ្ញុំអត់មានទំនាក់ទំនងត្រឡប់ធ្វើ មានការទាក់ទងអីមន្ទីរពេទ្យទេ ប៉ុន្តែតាមខ្ញុំចាំ អត់មានឮឈ្មោះគាត់ គេនិយាយពីឈ្មោះគាត់តាំងពីខ្ញុំចេញមក ឬក៏ខ្ញុំអត់មានការទាក់ទងជាមួយមន្ទីរពេទ្យ ឬក៏បាត់ខ្លួនគាត់ ប៉ុន្តែខ្ញុំអត់មានឮសួរគេ

និយាយពី<ឈ្មោះ>របស់គាត់ស្អីឡើយ។

[១៤:២៥:៤៦]

**ស៖** កាលបរិច្ឆេទ យើងមាននៅក្នុងសំណុំរឿងហើយ។ ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីការងាររបស់លោកស្រីនៅក្រសួងសង្គមកិច្ច <ដែលគេហៅថា ក-២>។ តើត្រឹមត្រូវទេ ដែលថា អៀង ធីរិទ្ធ ជាអ្នកទទួលខុសត្រូវទៅលើមន្ទីរពេទ្យស៊ីវិលទាំងអស់នៅភ្នំពេញ ហើយនិងទទួលខុសត្រូវខាងការផលិតថ្នាំ និងការស្តុកថ្នាំ?

**ឆ៖** ចាស ជាការពិត គាត់ទទួលខុសត្រូវខាងសង្គមកិច្ច ខាងមន្ទីរពេទ្យ ផលិតថ្នាំ។ (និយាយជាភាសាបារាំង)៖ ហើយគាត់ជាមន្ត្រីក្រសួងការបរទេស មិនមែនទេ គឺក្រសួងសុខាភិបាល (ចប់ការនិយាយជាភាសាបារាំង)។ សុខាភិបាល ចាស សុខាភិបាល ហើយនិងសង្គមកិច្ច។

**ប្រធានអង្គជំនុំ៖**

លោកស្រី ធុច ស៊ីថន លោកស្រីអាចប្រើប្រាស់តែមួយភាសាបានទេ នៅក្នុងអំឡុងពេលដែលលោកស្រីផ្តល់សក្ខីកម្ម? កាលណាលោកស្រីប្រើប្រាស់ភាសាពីរក្នុងពេលតែមួយអ៊ីចឹង គឺនឹងមានផលវិបាក ក្នុងការបកប្រែភាសា ព្រោះត្រឡប់ទៅ ត្រឡប់មក។ សូម--

[១៤:២៧:០៣]

**លោកស្រី ធុច ស៊ីថន៖**

ចាស ខ្ញុំសូម ព្រោះខ្ញុំមានទម្លាប់ ខ្ញុំទម្លាប់ចង់និយាយខ្មែរ ប៉ុន្តែដល់រស់នៅស្រុកគេយូរ បញ្ហាភ្លេចខ្លួន ខ្ញុំនិយាយជាបារាំង។ សូមទោសលោកប្រធាន។ ខ្ញុំសូមនិយាយខ្មែរ ហើយបើមានការខុសឆ្គងអី ចាំខ្ញុំបកជាខ្មែរវិញ សូមទោស។ ខ្ញុំភ្លេចខ្លួន ខ្ញុំអត់ដឹងថា ខ្លួនឯងទៅនិយាយពីរផងពេលខ្លះ សូមទោស។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអញ្ជើញបន្តទៀត!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

**ស៖** មុននេះលោកបាននិយាយថា អ្នកទទួលខុសត្រូវផ្ទាល់របស់លោកស្រីឈ្មោះ ស៊ូ ហើយ អៀង ធីរិទ្ធ ជាអ្នកមេធំ។ អ៊ីចឹងខ្ញុំអាចសន្និដ្ឋានបានថា លោកស្រីជាកម្មាភិបាលរបស់ក្រសួងសង្គមកិច្ច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយលោកស្រីកាន់មនុស្សប្រហែលប៉ុន្មាននាក់ដែរ មានមនុស្សប៉ុន្មាននាក់ដែលធ្វើការនៅក្រោមបញ្ជាលោកស្រី?

[១៤:២៨:២៣]

**លោកស្រី ធុច ស៊ីថន៖**

**ធ៖** ខ្ញុំខាង ប្រហែលជាខ្ទង់២០ជាង។ ២០ៗជាងនាក់ ពេលណារៀបចំថ្នាំពេទ្យ ខ្ទង់២០។ ប៉ុន្តែមានពេលខ្លះ មានគេបញ្ជូនក្មេងមកពីខេត្ត ហើយក្មេងហ្នឹង គ្រាន់មកនៅស្នាក់បណ្តោះអាសន្ន ហើយចេញទៅ ចេញទៅខាងធ្វើថ្នាំ ខាងមន្ទីរពេទ្យ។ គេគ្រាន់តែយកមកទុកនៅកន្លែងហ្នឹង ហើយក្មេងហ្នឹងចេញទៅដោយឡែកផ្សេងទៀត។ ខ្ញុំទទួលខាងធ្វើ ឧទាហរណ៍ថា ពេលណាមានថ្នាំមកដល់ ថ្នាំច្រើនចេញមកពីខាងស្រុក មកចិន ហើយនិងថ្នាំចាស់ៗដែលនៅភ្នំពេញ។ ខ្ញុំ គេឲ្យជាលេខ ខេត្តណាធំ ខេត្តណាតូច ខ្ញុំយកថ្នាំមក ខ្ញុំចែកជាតាមខេត្ត។ នៅកន្លែងខ្ញុំហ្នឹងមានម្នាក់ គាត់ចេះបារាំងច្រើន គាត់មកពីស្រុកបារាំង។ ប៉ុន្តែគាត់ត្រូវមកជួយខ្ញុំច្រើន ព្រោះធម្មតាគាត់ត្រូវមកជួយខ្ញុំ ព្រោះគាត់ សមត្ថភាពគាត់ខ្លាំងជាងខ្ញុំ ប៉ុន្តែគាត់អត់ចូលចិត្តធ្វើការទេ។ គាត់មកស្រុកបារាំង គាត់មានបញ្ហាក្នុងផ្លូវចិត្តរបស់គាត់ ព្រោះគាត់ ប្រហែលជាគាត់ខកចិត្ត។ ដូច្នេះគាត់ដំបូងគាត់មកជួយខ្ញុំច្រើន គាត់មកជួយ។ តាមខ្ញុំយល់គាត់ហ្នឹងមក ដើម្បីឲ្យទទួលខាងខុសត្រូវខាងមន្ទីរពេទ្យទេ ព្រោះគាត់មានសមត្ថភាពខ្លាំង។ ប៉ុន្តែដោយសារគាត់មិនសូវជាស្មុះស្មាខាងធ្វើការធ្វើអី ដូច្នេះខ្ញុំធ្វើចាត់ចែងការងារហ្នឹង។ ដូច្នេះភារកិច្ចរបស់ខ្ញុំថ្នាំដែលបានមក ខ្ញុំចែកទៅ ហើយខ្ទង់ប្រហែលខាង*ឌុយម៉ិច* ខាងផលិតកម្មពេទ្យ ដែលមានៗប្រតិកម្មពេទ្យដែរ ថ្នាំពេទ្យដែរ ផ្ញើមក ខ្ញុំបញ្ជូនទៅ--

**ស៖** បាទ សូមអរគុណលោកស្រី។ ខ្ញុំសូមកាត់ចម្លើយលោកស្រីត្រឹមហ្នឹងសិន សូមលោកស្រីឆ្លើយខ្លីៗបន្តិចទៅបានហើយ ព្រោះថាយើងមានពេលខ្លីណាស់ ហើយខ្ញុំមានសំណួរច្រើន។

**ធ៖** ចាស! ចាសៗ។

**ស៖** លោកស្រីបាននិយាយអំពីអ្នកមកពីបារាំងដែលមានបញ្ហា លោកស្រីអាចរៀបរាប់ឈ្មោះបានទេ ហើយសុំរៀបរាប់បន្តិចថា មានបញ្ហាអីដែរ?

**ធ៖** គាត់ឈ្មោះ -- ឈ្មោះៗគាត់ដើម ខ្ញុំមិនចាំ ប៉ុន្តែឈ្មោះនៅក្នុង *ប៉ាឌុង!* នៅឈ្មោះបដិវត្តន៍ឈ្មោះ ខន។ គាត់មកបីនាក់ជាមួយស្រករប្តីខ្ញុំ។ ប្តីខ្ញុំមកពីស្រុកបារាំងដែរ គាត់ហ្នឹង ហើយម្នាក់ទៀតដែលធ្វើការផ្ទាល់របស់ ជាមួយនឹង *ម៉ាដាម* ជាមួយនឹង អៀង ធីរិទ្ធ។

**សៈ** សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីជោគវាសនារបស់គាត់នៅពេលក្រោយ។ លោកស្រីមានឋានៈខ្ពស់ដែរនៅក្នុងក្រសួងសង្គមកិច្ច បើខ្ញុំយល់មិនច្រឡំទេ។ អ៊ីចឹងខ្ញុំចង់ថា នៅពេលណាមួយនោះ លោកស្រីមានក្លាយទៅជាសមាជិក ឬសមាជិកត្រៀមបក្សកុម្មុយនីស្តកម្ពុជាទេ?

**ផៈ** ខ្ញុំអត់ដែលចូលផង គេមិនដែលឲ្យខ្ញុំចូល។

[១៤:៣២:១៩]

**សៈ** ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច តើមានការប្រជុំធំប្រចាំឆ្នាំ ឬក៏កន្លះឆ្នាំម្ដង ដែលក្រសួងគេរៀបចំ ដើម្បីប្រមូលផ្ដុំ<យុទ្ធជន និងបុគ្គលិក>មកប្រជុំ ដែលមានអ៊ីចឹងទេ លោកស្រី?

**ផៈ** ចាស មាន។ មានការប្រជុំ ប្រជុំ ពេលណាប្រជុំៗខាងមន្ទីរពេទ្យ ៗគ្រប់ ខាងផលិតកម្មពេទ្យអីមកជួបជុំគ្នា ប្រជុំគ្នា ១ឆ្នាំម្ដង ឬ២ឆ្នាំ -- ពីរដង ១ឆ្នាំ អាចមាន មានចាស។

**សៈ** ក្នុងពេលប្រជុំធំៗទាំងអស់នោះ តើ អៀង ធីរិទ្ធ មានវត្តមានទេ? ហើយគាត់ជាអ្នកធ្វើអធិបតីនៅក្នុងប្រជុំហ្នឹងមែនទេ?

**ផៈ** ចាស គាត់ធ្វើៗ គាត់ធ្វើ ហើយនិង បងស៊ូ គាត់ធ្វើពីរនាក់ហ្នឹង។ គាត់ច្រើនជា គាត់ធ្វើ ប៉ុន្តែ បងស៊ូ គាត់ច្រើន នេះច្រើនជាង គាត់អ្នកចាត់ចែងច្រើនជាង ជំនួស អៀង ធីរិទ្ធ។

**សៈ** ក្នុងពេលប្រជុំធំៗក្រោមអធិបតីភាពរបស់ អៀង ធីរិទ្ធ ឬ បងស៊ូ តើកម្មាភិបាលហ្នឹង គេមានបាននិយាយអំពីខ្មាំងដែលបានស៊ីរូងផ្ទៃក្នុង បង្កប់ខ្លួននៅក្នុងក្រសួងសង្គមកិច្ចទេ?

**ផៈ** គេនិយាយ គេៗតែងនិយាយពីរឿងខ្មាំង។ គេមិនប្រាកដ គេ -- ចាស ធម្មតានៅក្នុងសង្គមមួយៗគេ នៅក្នុងមាននិយាយ។

**សៈ** នៅសម័យនោះ អ្នកណាត្រូវបានគេចាត់ទុកថា ជាខ្មាំងផ្ទៃក្នុងនិងខ្មាំងខាងក្រៅ? តើ អៀង ធីរិទ្ធ ឬ បងស៊ូ ដែលធ្លាប់និយាយថា គេធ្វើយ៉ាងម៉េចបានដឹងថាអ្នកណាជាខ្មាំង អ្នកណាជាមិត្ត?

**ផៈ** ខ្ញុំមិនៗប្រាកដជាថាយ៉ាង គេគ្រាន់និយាយថាត្រូវតែកម្ទេចខ្មាំង។ ឲ្យជាគោលការណ៍ ខ្ញុំមិនជាច្បាស់ថាម៉េចទេ ប៉ុន្តែក្នុងគោលបំណងគេប្រជុំមួយៗ គេថាត្រូវកម្ទេចខ្មាំងដើម្បីការពារអង្គការ ការពារស្រុក ហើយត្រូវធ្វើទិតៀន ទិតៀនខ្លួនឯង ទិតៀនអ្នកដទៃ ជានៅក្នុងប្រជុំតូចៗ ហើយដល់ពេលប្រជុំធំអ៊ីចឹងដែរ គឺថាត្រូវកម្ទេចខ្មាំង។

[១៤:៣៦:៣៧]

**សៈ** បាទ សូមអរគុណ។ តើ អៀង ធីរិទ្ធ ឬ ស៊ូ មានបាននិយាយអំពីជនក្បត់ទេ?

**ឆះ** ពេលខ្លះៗគេចេញឈ្មោះដែរ អ្នកខ្លះដែលបាត់ខ្លួន ប៉ុន្តែអ្នកខ្លះអ្នកបាត់ខ្លួន អត់ឮស៊ូនិយាយទេ។ ជនណាដែលបាត់ខ្លួន គេលើកឡើងនៅពេលប្រជុំធំ ប៉ុន្តែអ្នកខ្លះបាត់ខ្លួន គេអត់មានលើកនិយាយ មិនដឹងថាតើមានបញ្ហាស្អីដែលគេលើកឡើង ហេតុអីបានគេយកមនុស្សឈ្មោះហ្នឹងចេញ អ្នកខ្លះអត់។

**សះ** ដើម្បីត្រឡប់មកខាងក្រោយបន្តិច ខ្ញុំចង់សួរលោកស្រីស្គាល់មនុស្សម្នាក់ដែលជាអ្នកបើកឡានឱ្យ អៀង ធីរិទ្ធ <ចាប់ពីចុងឆ្នាំ១៩៧៧ ដល់ដើមឆ្នាំ១៩៧៩> ឈ្មោះថា ខាំ ផាន់ ឬ <ផាន> វ៉ាន ជាកូនប្រុសរបស់លេខាតំបន់១០៥ គឺចន្លោះឆ្នាំ៧៧ ដល់ឆ្នាំ<៧៩> លោកស្រីស្គាល់គាត់ទេជាអ្នកបើកឡានឱ្យ អៀង ធីរិទ្ធ?

**ឆះ** ខ្ញុំឱ្យស្គាល់ច្បាស់ប្រាកដខ្ញុំអត់ស្គាល់។ ប៉ុន្តែខ្ញុំដឹងគាត់មាន ខ្ញុំស្គាល់អ្នកបើកឡាន ដឹងឃើញអ្នកបើកឡាន ប៉ុន្តែឱ្យប្រាកដជាអ្នកណាចេញពីណាខ្ញុំអត់ច្បាស់។

**សះ** បាទ មិនអីទេ។ ខ្ញុំសូមអានសម្រង់នៃកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកបើកឡានឱ្យ អៀង ធីរិទ្ធ នេះ។ គាត់ត្រូវបានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/447 គឺចម្លើយ១៤, ៣១ និង៣២។ មុននឹងដកស្រង់ <ខ្ញុំចង់និយាយថា>គាត់បាននិយាយអំពីការចាប់ខ្លួន ស៊ូ និង យាយប៉ាក់ ជាប្រធានរោងចក្រផលិតថ្នាំ។ ហើយគាត់ថាគាត់នាំ<អ្នកទាំងពីរនោះ>ទៅមន្ទីរក-៧ <ដោយខ្លួនគាត់ គឺនាំយកទៅ>មន្ទីរនីរសារ <ហើយ>នេះជាចម្លើយរបស់ ខាំ ផាន់ <ចម្លើយទី១៤>។ "ក្រោយពីប្រមូលបុគ្គលិកក្រសួងសង្គមកិច្ចមក យាយភា បាននិយាយថា អ្នកទាំងពីរហ្នឹងជាជនក្បត់" ហើយគាត់អានសារាចររបស់មន្ទីរក-៣។ សំណួរ៣១៖ "តើលោកស្រី អៀង ធីរិទ្ធ មានបានរៀបចំប្រជុំស្តីអំពីការបោសសម្អាត និងតាមដានអ្នកដែលត្រូវចាប់ខ្លួនទេ? ចម្លើយរបស់ ខាំ ផាន់៖ នៅសម័យនោះ ការប្រជុំតាមដានហ្នឹងគឺធ្វើឡើងជាទៀតទាត់ គឺពេលនុ៎ងគេតាមដានឃ្លាំមើលគ្នាទៅវិញទៅមក ដើម្បីរកខ្មាំងបង្កប់ផ្ទៃក្នុង។ ចម្លើយ៣២៖ យើងដឹងរឿងនេះ តាមរយៈឯកសារផ្សេងៗ ដូចជា ឯកសារស្តីអំពីសភាពការណ៍ជាក់ស្តែង ឯកសារស្តីអំពីការវាយប្រយុទ្ធគ្នាជាមួយវៀតណាម ខ្មាំងស៊ីរូងផ្ទៃក្នុង ឯកសារស្តីអំពីបទពិសោធន៍នៃខេត្តផ្សេងៗ និងចម្លើយសារភាពរបស់មនុស្សជាច្រើន។ ហើយ យាយភា គាត់ជាអ្នកបង្រៀននៅពេលនុ៎ង។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះតើលោកស្រីមានប្រតិកម្មតបយ៉ាងណាដែរ? លោកស្រីបាននិយាយថា អៀង ធីរិទ្ធ បាននិយាយឈ្មោះមនុស្ស ហើយក៏ប៉ុន្តែពេលខ្លះ លោកស្រីថា ពេលខ្លះនោះគឺថា យាយភា ហ្នឹងគាត់អត់ដែលប្រាប់ឈ្មោះអ្នកដែលបាត់ខ្លួនទេ ប៉ុន្តែក្នុងនេះ ខាំ ផាន់ គាត់បាននិយាយច្បាស់ថា យាយភា ហ្នឹង

គាត់លើកឈ្មោះអ្នកទាំងអស់ហ្នឹងយកមកនិយាយ។

[១៤:៤១:០៤]

**ឆ៖** ចាស ខ្ញុំឧទាហរណ៍នៅពេលប្រជុំម្តង តាមខ្ញុំចាំ លោកហ្នឹងគាត់ខាង គាត់*ដង់ទីស្ត* គាត់ខាងពេទ្យធ្មេញ កូនសិស្សរបស់លោក ឌី ផុន នៅពេលបែក០៧ មករា គាត់មកចូលធ្វើការនៅមន្ទីរពេទ្យដែរ។ គេនិយាយឈ្មោះ គាត់។ ហើយអ្នកខ្លះបាត់ខ្លួន ដូចជាប្រជាជនថ្មី គេត្រូវការដំបូង។ ខ្ញុំឃើញគាត់ឃើញប្តីប្រពន្ធកូនអីមក ហើយបាត់ខ្លួន អត់ឃើញនិយាយ។ ខ្ញុំមិនដឹងថាតើគេ ហេតុអីអ្នកខ្លះ គេឈ្មោះបាត់ខ្លួន អ្នកខ្លះចេញឈ្មោះ អ្នកខ្លះអត់ចេញឈ្មោះ។ មិនដឹងករណីណាធ្ងន់ស្រាល ឬយ៉ាងម៉េច ជាខ្មាំង ឬមិនជាខ្មាំង ឬក៏គ្រាន់តែទៅយកតែលត់ដំ ឬក៏យកទៅកម្ទេច ខ្ញុំ គេអត់មាននិយាយពីបញ្ហាហ្នឹងទេ។

**ប្រធានអង្គជំនុំ៖**

លោកស្រីឆ្លើយថា ១៧ មករា ក្រោយ១៧ មករា ឬក៏ក្រោយ១៧ មេសា ព្រោះលោកស្រីប្រើពាក្យថា ១៧ មេសា បែកភ្នំពេញ បានន័យថា អាចច្រឡំកាលបរិច្ឆេទទេដឹង ទំនងជាថ្ងៃ១៧ មេសា។

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** មេសា។ មករា កុម្ភៈ មីនា មេសា ចាស មេសា។ នៅពេលដែលខ្មែរក្រហមឈ្នះ ថ្ងៃ១៧ មេសា។

[១៤:៤២:៤៧]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេះ៖**

**ស៖** ប្រហែលជាសំណួរចុងក្រោយមុនពេលឈប់សម្រាក។ ខាំ ផាន់ បាននិយាយថា នៅពេលណាមួយនោះ គឺថា គេតាមដានគ្នាទៅវិញទៅមកដើម្បីស្វែងរកខ្មាំងបង្កប់។ អ៊ីចឹង<តើ>លោកស្រីនៅធ្វើការនៅក្រសួងហ្នឹង<ទេ> នៅពេលដែលមានការចាប់ផ្តើមតាមដានគ្នាទៅវិញទៅមកនោះ ហើយលោកស្រីឯកភាពជាមួយគាត់ទេ ដែលគាត់និយាយបែបហ្នឹង។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលណាដែលនៅក្នុងក្រសួងហ្នឹងគេចាប់ផ្តើមតាមដានគ្នាទៅវិញទៅមកហ្នឹង?

**ឆ៖** ក្រសួងនេះ នៅពេលចាប់ផ្តើមតាមដានគ្នាទៅវិញទៅមក នៅពេលឆ្នាំតឹងតែងមែនទែន ៧៧, ៧៨។ នៅពេលមុនគេយកប្តីខ្ញុំទៅ ៧៨។ ៧៦ អត់ទាន់តឹងតែងខ្លាំងទេ តែ៧៧, ៧៨ មនុស្សកាន់តែបាត់ខ្លួនទៅ។ មានការតឹងតែង ខ្ញុំក៏គេតាមដានដែរ ពីព្រោះអី ខ្ញុំមានប្តីគេត្រូវយកទៅ ហើយគេមិនទាន់យកទៅ។ នៅពេលនោះ ការរស់នៅនៅទីនោះ កាន់តែមានការលំបាក តឹងតែងខាងផ្លូវចិត្ត ការ

តាមដានគ្នាទៅវិញទៅមក។ ខ្ញុំភ័យពីគេ គេក៏ភ័យពីខ្ញុំ។

**ស៖** មុននឹងនិយាយអំពីការរៀបការរបស់លោកស្រី ខ្ញុំចង់ដឹងថា លោកស្រីធ្លាប់ឮ អៀង ធីរិទ្ធ និយាយក្នុងពេលប្រជុំធំៗ ឬក៏ប្រជុំតូច ឬក៏ពេលនិយាយគ្នាជាមួយលោកស្រីនោះ <តើលោកស្រីធ្លាប់ឮ>គាត់<>និយាយអំពី<វៀតណាម>ខ្មាំងសត្រូវ<ដែលសំដៅទៅលើ>យួនទេ?

[១៤:៤៤:៥៣]

**ឆ៖** បញ្ហា ចាស មាននិយាយយួនទាំងអស់។ ធម្មតាគេមានបី មានយួន មានអាមេរិក សេ.អ៊ី.អា ពួករុស្ស៊ី កា.ហ្សេ.បេ។ *យ៉ាណាត្រូវ* បីនាក់ហ្នឹង គឺមានបីហ្នឹង មានបី មានយួន។ យួនឮសូរក្រោយទេ។ មុនដំបូងបង្អស់ ដែលគេមានការបារម្ភមែនទែន សេ.អ៊ី.អា, កា.ហ្សេ.បេ. យួនបន្ទាប់ក្រោយមកទៀត។

**ស៖** តើគាត់មានបាននិយាយ<នៅចំពោះមុខលោកស្រី>ថា យួនហ្នឹងមានបានបង្កប់ចូលនៅក្នុងជួរក្រសួងទេ?

**ឆ៖** គាត់ៗអត់មាននិយាយពីយួនបញ្ចប់ បង្កប់ខ្លួននៅក្នុងក្រសួងទេ ប៉ុន្តែគាត់និយាយជាទូទៅ គឺថាមានការបង្កប់ខ្លួននៅៗជុំវិញខ្លួនយើង។ ធម្មតាគេនិយាយថា សត្រូវនៅជុំវិញខ្លួនយើង។

**ស៖** លោកប្រធាន ខ្ញុំចូលទៅប្រធានបទថ្មី គឺការរៀបអាពាហ៍ពិពាហ៍របស់សាក្សី។ តើខ្ញុំត្រូវបន្តទៀត ឬក៏យ៉ាងម៉េច? ព្រោះថាយើងចាប់ផ្តើមរាងយឺតពេលដែរហើយ លោកប្រធាន? លោកស្រីសាក្សី យើង<នឹង>ត្រឡប់ទៅនិយាយអំពីការបាត់ខ្លួនមនុស្សនៅក្នុងក្រសួងសង្គមកិច្ច ក៏ប៉ុន្តែខ្ញុំនិយាយសួរលោក អំពីការរៀបការសិន។ លោកស្រីអាចជម្រាបបានទេ លោកស្រីរៀបការនៅឆ្នាំណាដែរ? ហើយនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំរៀបការនៅឆ្នាំ១៩៧៦ ខ្ទង់ខែ៩ ជិតចុងឆ្នាំ៧៦ នៅមន្ទីរសង្គមកិច្ច ហើយជាអ្នកៗដែលអ្នកដែលមកជា -- ពេលនុំងមានបីគូ។ ពីរ ខ្ញុំ ហើយនិងមួយគូទៀត គឺគាត់មកពីស្រុកបារាំងដែរ ដែលខ្ញុំនិយាយអំមិញ ម្នាក់ដែលថាធ្វើការជាមួយខ្ញុំ គាត់មកពីស្រុកបារាំងដែរ ឈ្មោះ ខន ហ្នឹង។ ហើយមួយគូទៀត ខ្មែរនៅនោះ។ បីគូហ្នឹង ខ្ញុំពួកខ្ញុំបីគូហ្នឹងការ បងស៊ូ គាត់ជាអ្នកធ្វើដូចជា ខ្មែរយើងថាមេបា។ គាត់ឡើងជំនួសឪពុកម្តាយ។

[១៤:៤៨:២២]

**ស៖** ការរៀបការច្រើនគូហ្នឹង ជាការរៀបការលើកដំបូង ពេលដែលលោកស្រីរៀបការហ្នឹង

រៀបការលើកដំបូង ឬក៏មុនលោកស្រីហ្នឹង គេមានរៀបការច្រើនគូបែបហ្នឹងរួចមកហើយ?

**ឆ៖** ខ្ញុំដូចជាអត់ចាំ ប៉ុន្តែមិនចាំច្បាស់ ប៉ុន *ហេវ៉ឺវ័រកើ* ខ្ញុំលើកទី១ តាមមើល ខ្ញុំមិនចាំច្បាស់។ ប៉ុន្តែពេលនុ៎ង ពេលណាការ គឺបីគូៗ មានក្រោយ មានគេក្រោយមកទៀតការ មានដែរ ប៉ុន្តែមានមុនខ្ញុំ ខ្ញុំមិនបានចាំច្បាស់។

**ស៖** លោកស្រីដឹងទេថា ហេតុអីបានជាគេរៀបចំឲ្យមានការរៀបការអ៊ីចឹង? ហើយអង្គការ គេមានគោលបំណងបែបណាដែរ ដែលឲ្យបុគ្គលិកក្រសួងហ្នឹងរៀបការហ្នឹង? អៀង ធីរិទ្ធ ឬក៏ ស៊ូ ហ្នឹង មានបានប្រាប់ពីគោលបំណងរបស់បក្ស ក្នុងការរៀបការហ្នឹងទេ?

**ឆ៖** គេអត់មានប្រាប់យើងទេ ប៉ុន្តែអ្នកទទួលខុសត្រូវ អង្គការជាអ្នកជំនួសឪពុកម្ដាយរបស់យើង។ ដូច្នេះអ្នកដែលស្រករៗខ្ញុំ ក្នុងខ្ទង់២០ឆ្នាំ នៅមន្ទីរពេទ្យក្ដី នៅក្រសួងសង្គមកិច្ចក្ដី គឺអង្គការចាប់ឲ្យ អង្គការឲ្យការ។ ផ្សំផ្គុំនៅ ដោយមើលអ្នកណាត្រូវជាមួយពីណា អ្នកណាត្រូវជាមួយពីណា។ តាមខ្ញុំយល់ក្នុងអាយុយើង២០ជាង យើងត្រូវតែមានគ្រួសារ ដូច្នេះអាយុខ្ទង់ប៉ុណ្ណឹង មានអ្នកចាត់ចែង គេចាត់ចែងឲ្យការ ពីព្រោះនៅទីនោះ គេមិនអាច បើយើងមិនឲ្យការ គេត្រូវអាយុការ ហើយអត់មាន យើងអត់មានច្បាប់ស្រលាញ់ ត្រូវការខ្លួនយើង សុំខ្លួនយើងទេ។ ដូច្នេះមានតែគាត់ជាអ្នករៀបចំការឲ្យ អ្នកទទួលខុសត្រូវ គេហៅថា អង្គការហ្នឹង គេការឲ្យយើង។

[១៤:៥១:០៨]

**ស៖** អ៊ីចឹងគេមិនដែលប្រាប់លោកស្រីថា អង្គការមានគោលបំណងបង្កើនចំនួនប្រជាជនឲ្យបានច្រើនក្នុងរយៈពេលឆាប់រហ័សទេឬ?

**ឆ៖** *ណុង!* អត់មានដែលឮ ពេលហ្នឹងអត់មាននិយាយទេ ខ្ញុំអត់ដែលឮ។

**ស៖** អ្នកណាជាអ្នកប្រាប់លោកស្រីដំបូង ថាលោកស្រីត្រូវរៀបការហ្នឹង?

**ឆ៖** ម្នាក់ដែលមកប្រាប់ខ្ញុំមុនដំបូង គឺគាត់ធ្វើការជាមួយខ្ញុំ ប្ដីគាត់ៗជាធ្វើការជាមួយ បងស៊ូនៅក្នុងក្រសួងសង្គមកិច្ច។ ក្រៅពី អៀង ធីរិទ្ធ អ្នកទទួលខុសត្រូវក្រសួងទាំងអស់ ប្រធានមន្ទីរគឺ បងស៊ូ ក្រោមអំណាច បងស៊ូ មានជនជាតិខ្មែរលើលាវ -- ខ្មែរលើម្នាក់ គាត់ធ្វើការជាអ្នកអនុប្រធាន បងស៊ូ។ ហើយប្រពន្ធរបស់អនុប្រធាន បងស៊ូ ហ្នឹង ខ្មែរលើហ្នឹង គាត់ខ្មែរលើដែរ ប្រពន្ធហ្នឹង គាត់មកសួរខ្ញុំ។ គាត់សួរខ្ញុំថា ឥឡូវហ្នឹងអង្គការចង់ឲ្យ ស៊ីថន ឯងការ តើយល់យ៉ាងម៉េច? គឺប្រពន្ធ មិនមែន បងស៊ូ មកសួរខ្ញុំផ្ទាល់ទេ ឬក៏ អៀង ធីរិទ្ធ អត់មានអ្នកណាមកសួរ គឺអ្នកធ្វើការជាមួយខ្ញុំ ដែលអ្នកធ្វើការហ្នឹង

គាត់ជាប្រពន្ធអនុប្រធាន បងស៊ូ អនុប្រធានមន្ទីរសង្គមកិច្ចហ្នឹង គាត់មកសួរខ្ញុំ។ គាត់ជាជនខ្មែរលើ ជនជាតិខ្មែរលើ។

**ស៖** ចុះ ស៊ូ គាត់មានបាននិយាយរឿងរៀបការលោកស្រីហ្នឹង មុនពេលលោកស្រីរៀបការទេ?

**ផ៖** *ណុង!* ចាស គាត់អត់មាននិយាយទេ។

**ស៖** មុននេះលោកស្រីបាននិយាយថា លោកស្រីអត់មានជម្រើសទេ គឺថាយើងមិនអាចរៀបការជាមួយអ្នកដែលយើងស្រលាញ់បានទេ។ អ៊ីចឹងពេលដែលគេប្រកាសថា លោកស្រីត្រូវរៀបការហ្នឹង <តើ>លោកស្រីដឹងទេថា លោកស្រីត្រូវរៀបការជាមួយអ្នកណានោះ? ឬក៏នៅពេលណាដែលលោកស្រីដឹងថា ខ្លួនត្រូវរៀបការជាមួយអ្នកណានោះ?

[១៤:៥៣:៥៤]

**ផ៖** ខ្ញុំអត់សួរយល់សំណួរ ប៉ុន្តែខ្ញុំគ្រាន់តែថា មុនដំបូងខ្ញុំបដិសេធ។ ខ្ញុំថា ព្រោះខ្ញុំអត់សួរ ខ្ញុំដូចអត់សួរពេញចិត្តគាត់ ប្ដីខ្ញុំមុនដំបូង។ ខ្ញុំនិយាយថា ខ្ញុំអត់ទាន់ចង់បានប្ដីទេ។ ដល់បន្ទាប់មក គាត់ហ្នឹងមកសួរខ្ញុំម្ដងទៀត។ ដល់សួរខ្ញុំម្ដងទៀត ខ្ញុំនិយាយប្រាប់ថា បើសិនចង់ឲ្យខ្ញុំការ សូមឲ្យធានាខុសត្រូវឲ្យខ្ញុំ សូមឲ្យអង្គការធានាខុសត្រូវឲ្យខ្ញុំ ពីព្រោះប្ដីខ្ញុំគាត់មកពីស្រុកបារាំង ខ្ញុំអត់មាននិយាយប្រាប់គេអ៊ីចឹង ប៉ុន្តែក្នុងចិត្តខ្ញុំថា ប្ដីខ្ញុំមកពីស្រុកបារាំង ខ្ញុំមិនដឹងថាតើគាត់មានធ្លាប់មានប្រពន្ធមុន។ ពីដើមខ្ញុំអត់ដឹង ឲ្យខ្ញុំយល់ ខ្ញុំអត់យល់ថា គាត់ជា សេ.អ៊ី.អា ឬអីទេ ប៉ុន្តែបញ្ហាបារម្ភ ដែលខ្ញុំបារម្ភបំផុត គឺខ្ញុំខ្លាចគាត់មានប្រពន្ធមុន មានស្រីបារាំងមុន ឬយ៉ាងម៉េច។ ហើយខ្ញុំៗ បញ្ហាហ្នឹងខ្ញុំមានការស្ទាក់ស្ទើរ ហើយពិបាកដែរ ខ្ញុំមិនអាចការជាមួយអ្នកណាដែលខ្ញុំអត់ដែលស្គាល់គាត់សោះ ឃើញតែម្ដង ពីរដង ហើយគាត់ធ្វើការនៅដោយឡែកពីគ្នា។ ដូច្នេះខ្ញុំ ទី១ ខ្ញុំបដិសេធ ប៉ុន្តែទី២ ខ្ញុំថា បើសិនជាចង់ឲ្យខ្ញុំការ សុំធានាខុសត្រូវឲ្យខ្ញុំ។ ទទួលខុសត្រូវឲ្យខ្ញុំ ក្នុងន័យហ្នឹង ខ្ញុំមិន ខ្ញុំអត់ ពេលនុ៎ងអត់ទាន់មានជនក្បត់មកពីស្រុកបារាំង បញ្ហាជនអី ខ្ញុំអត់ទាន់មានបែកផ្ទុះផ្ទារអីទេ ប៉ុន្តែបញ្ហាដែលខ្ញុំបារម្ភគឺស្រីញីហ្នឹង ពីព្រោះគាត់មកពីស្រុកបារាំង មុន គ្នាគាត់បីនាក់ហ្នឹង មានម្នាក់ គាត់មាន គាត់ធ្លាប់នៅជាមួយស្រីបារាំង នៅស្រុកបារាំង មុនគាត់ទៅស្រុកខ្មែរ។ ការបារម្ភរបស់ខ្ញុំ បញ្ហាហ្នឹងទេដែលខ្ញុំបារម្ភ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយសុំជម្រាបភាគីថា នៅរសៀលនេះអង្គជំនុំជម្រះមិនសម្រាកទេ បន្តការសួរនេះសាក្សីរូបនេះ រហូតដល់ពេលម៉ោងសម្រាក ម៉ោងបួនទៅ ដើម្បីជួសជុលឡើងវិញនូវពេលវេលាដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានបាត់បង់ ដល់ភាគីខាងតំណាងសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

ហើយទី២ គឺបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-223 វិលទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកឲ្យបាន ដែលនឹងចាប់ផ្ដើមម៉ោងប្រាំបួនព្រឹក។

បាទ អញ្ជើញបន្តទៀត!

[១៤:៥៧:០៥]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯលៈ**

**ស៖** សូមអរគុណលោកប្រធាន។ លោកស្រីសាក្សី នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកស្រីនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតគឺ ឯកសារ E3/5305 នៅទំព័រជាភាសាបារាំង 00342208, ជាភាសាខ្មែរ <00349555> និងជាភាសាអង់គ្លេសគឺ <00345228> ទៅដល់ 29។ លោកស្រីបាននិយាយដូចតទៅ៖ “ស៊ូ ដែលជាមេរបស់ខ្ញុំបានសម្រេចដោយមានការឯកភាពពី អៀង ធីរិទ្ធ ថាខ្ញុំត្រូវរៀបការជាមួយនឹងឈ្មោះ វ៉ាសៃ។ នៅសម័យនោះ គឺនៅសម័យខ្មែរក្រហម គឺអ្នកទទួលខុសត្រូវ និងមេៗដែលជាអ្នកសម្រេចរឿងបែបនេះ។ យើងមិនអាចជ្រើសរើសថា យើងចង់រៀបការជាមួយអ្នកណាបានស្រេចតែចិត្តនោះទេ។ ចំពោះខ្ញុំ ៗមានចាប់ចិត្តទៅលើលេខារបស់ អៀង ធីរិទ្ធ ក៏ប៉ុន្តែខ្ញុំមិនអាចជំទាស់ទៅនឹងការសម្រេចហ្នឹងបានទេ។ ជាពិសេស ខ្ញុំមិនហ៊ានបង្ហាញអារម្មណ៍ ឬក៏មានមនោសញ្ចេតនាស្នេហាជាមួយបុរសណាទេ ព្រោះថានេះវាគឺជាឧក្រិដ្ឋកម្ម។”

នៅក្នុងសម្រង់នេះ លោកស្រីបាននិយាយថា ស៊ូ ជាអ្នករៀបចំការរៀបការរបស់លោកស្រីដោយមានការឯកភាពពី អៀង ធីរិទ្ធ។ អ៊ីចឹងលោកស្រីអាចជម្រាបបានទេថា ពេលណាដែល<លោកស្រីបានដឹងថា> ស៊ូ និង អៀង ធីរិទ្ធ នេះជាអ្នកសម្រេចថា លោកស្រីត្រូវរៀបការជាមួយអ្នកណានោះ?

[១៤:៥៩:០០]

**លោកស្រី ធុច ស៊ីថន៖**

**ធ៖** ចាស នៅខែ នៅមុននឹងសម្រេចឲ្យខ្ញុំការហ្នឹង ប្រហែលពីរបីខែមុន គេសួរខ្ញុំ។ ការពិត *សាហ្វាស់* ការពិតគឺខ្ញុំចាប់ចិត្តស្រឡាញ់លេខារបស់គាត់ ព្រោះខ្ញុំជួបគាត់ញឹកជាង ហើយរូបសម្បត្តិ

គាត់គ្រាន់បើជាងប្ដីរបស់ខ្ញុំ ប៉ុន្តែខ្ញុំអត់មានសិទ្ធិជ្រើសរើសខ្លួនឯង។ ខ្ញុំមិនអាច បើខ្ញុំ -- ខ្ញុំត្រូវបង្ខំចិត្តការជាមួយប្ដីរបស់ខ្ញុំ ព្រោះខ្ញុំគិតម្ដងទៀតដែរថា បើសិនជាខ្ញុំមិនការជាមួយទេ គេឲ្យខ្ញុំការជាមួយកម្មករកសិករ។ ហើយខ្ញុំពិបាកដែរ ព្រោះអីមុនហ្នឹង មុន បងស៊ូ ហ្នឹងឲ្យខ្ញុំការ ខ្ញុំឮសួរគេនិយាយថា គេចង់ឲ្យខ្ញុំការជាមួយម្នាក់ គាត់អ្នកបើកឡានខាងដឹកៗបន្លែអីទៅចង្ក្រានបាយ។ ខ្ញុំពិបាក ខ្ញុំមិនអាចការជាមួយ ខ្ញុំនិយាយត្រង់ ខ្ញុំមិនអាចការជាមួយអ្នកដែលគេអត់ចេះអក្សរអីសោះអ៊ីចឹង។ ដូច្នេះខ្ញុំថា ឥឡូវបើខ្ញុំមិនបាន ខ្ញុំអត់មានសិទ្ធិជ្រើសរើសមនុស្សល្អ មនុស្សដែលខ្ញុំស្រឡាញ់។ ខ្ញុំសុខចិត្តការជាមួយគាត់ចុះ ព្រោះគាត់ជាអ្នកបញ្ញាជន។ ហើយខ្ញុំបានសួរយោបល់បងស្រីម្នាក់ដែលរៀបចំពេទ្យជាមួយខ្ញុំផ្សេងទៀត។ បងស្រីហ្នឹងគាត់ថា អ្ហ៎! សុខចិត្តយកទៅ ព្រោះអីគាត់ គាត់អ្នកចេះដឹង មិនមែនជាមនុស្សល្ងង់អ៊ីចឹងទេ។ ខ្ញុំសួរយោបល់គេ អ្នកធ្វើការជាមួយខ្ញុំហ្នឹង បងស្រីហ្នឹង។ ដូច្នេះខ្ញុំថាឥឡូវ ខ្ញុំ មិនមែនខ្ញុំមិនពេញចិត្តប្ដីខ្ញុំ ខ្ញុំត្រូវថា ខ្ញុំត្រូវតែការ ជាជាងខ្ញុំទៅការជាមួយអ្នកដែលល្ងង់ អត់ចេះអក្សរ អត់ចេះអី។ ខ្ញុំអត់ពេញចិត្តកាន់តែអត់ពេញចិត្តជាងប្ដីខ្ញុំទៅទៀត។

**ស៖** ក្នុងដំណើរការដែលនាំទៅដល់ការរៀបការ ឬក៏ការប្ដេជ្ញាចិត្តនេះ តើ អៀង ធីរិទ្ធ មានបាន<និយាយអ្វីដែរ ឬ>ទេ? គាត់មានបានបញ្ចុះបញ្ចូលឲ្យលោកស្រីព្រមរៀបការទេ?

[១៥:០១:៣៣]

**ឆ៖** គាត់អត់ទេ បងស៊ូ ទេ គាត់អ្នកគាត់ -- ពីរនាក់ហ្នឹង ពីដើមខ្ញុំអត់មានទាក់ទងផ្ទាល់ *ជីវិត* ទៅ អៀង ធីរិទ្ធ ទេ ខ្ញុំតែទាក់ទងជាមួយ បងស៊ូ ព្រោះគាត់ជាអ្នកទទួលខុសត្រូវលើខ្ញុំ។ ដូច្នេះមានតែ បងស៊ូ ទេដែលខ្ញុំមានការទាក់ទងផ្ទាល់។ អៀង ធីរិទ្ធ ខ្ញុំអត់ដែលឮគាត់និយាយអីទាំងអស់។ ហើយ បងស៊ូ ហ្នឹងបានខ្ញុំដឹង គាត់ស្គាល់ប្ដីខ្ញុំហ្នឹងពីដើមដែរ តាមឮគាត់និយាយថា ពីដើមគាត់នៅភ្នំពេញ គាត់ធ្លាប់ស្គាល់ប្ដីខ្ញុំ ស្គាល់ឪពុកម្ដាយរបស់ប្ដីខ្ញុំ។ ដូច្នេះគាត់តែងដំណាលនិយាយពីប្ដីខ្ញុំពេលខ្លះ ពេលមុនការហ្នឹង គាត់និយាយប្រាប់ថា គាត់ស្គាល់អ៊ីចឹងៗ។

**ស៖** សមាជិកគ្រួសាររបស់លោកស្រី ឬក៏បងប្រុសរបស់លោកស្រីដែលឈ្មោះ <ធុច> រិន ហ្នឹង គាត់<អាច>ចូលរួមក្នុងការរៀបការរបស់លោកស្រីទេ?

**ឆ៖** *ណុង!* អត់ទេ អត់មានរួម អត់មានចូលរួម ហើយអត់ដែលស្គាល់ប្ដីខ្ញុំ ព្រោះតាំងពីខ្ញុំបែកមក ខ្ញុំមិនដែលមានការទាក់ទងជាមួយបងប្រុសខ្ញុំ។ ខ្ញុំអត់ដែលមានពេលទៅជួបបងប្អូនម៉ែឪខ្ញុំ ដែលខ្ញុំបែកតាំងពី៧២មក អត់ទេ។

**សះ** ក្នុងពេលរៀបចំពិធីការហ្នឹងគឺថា លោកស្រីថា បងស៊ូ ជា<អធិបតីនៅក្នុងពិធីហ្នឹង>។ អ៊ីចឹងក្នុងពិធីរៀបការហ្នឹង តើ បងស៊ូ គាត់បាននិយាយអ្វីខ្លះ? គាត់មានឡើងថ្លែងសុន្ទរកថា គាត់មានបាននិយាយអំពីគោលបំណងអង្គការដែលចង់ឲ្យគូនីមួយៗហ្នឹង រៀបការទេ?

**ឆះ** *ណុង!* គាត់អត់មាននិយាយអីច្រើនទេ គ្រាន់ថា ពួកខ្ញុំសំណាងហើយដែលបានការនៅក្នុងសម័យអង្គការ ដែលអង្គការការឲ្យ។

**សះ** ក្នុងពេលរៀបការ ឬក្នុងពេលប្ដេជ្ញា ហើយនិងក្រោយមកទៀត តើលោកមានបានទទួលសេចក្ដីណែនាំដោយផ្ទាល់ ឬដោយប្រយោល ឲ្យរួមដំណេកជាមួយស្វាមីទេ?

[១៥:០៤:២៨]

**ឆះ** អត់មាននិយាយផងបញ្ហាហ្នឹង។ គេអត់ នៅក្នុងជំនាន់នោះគេមិនដែលនិយាយពីរឿងរបៀបអ៊ីចឹងៗ គេអត់និយាយទេ គឺជាបញ្ហា – បារាំងហៅថា *"ឡាម៉ូរ៉ាល់លីតេ"* ខ្មែរយើងដឹងថា គេអត់និយាយទេ ពីរឿងការរួមដំណេក ពីរឿងស៊ីៗហ្នឹង គេអត់មាននិយាយទេ។

**សះ** ចុះអាជ្ញាធរក្រសួងមានបានរៀបចំមធ្យោបាយយ៉ាងម៉េច ដើម្បីឲ្យគូស្រករហ្នឹងរួមដំណេកជាមួយគ្នាទេ នៅយប់ដំបូង ហើយនិងយប់ក្រោយៗមកទៀតនោះ?

**ឆះ** អត់មានផងចាស។

**សះ** ខ្ញុំនឹងសួរឲ្យច្បាស់ គឺជាចម្លើយរបស់លោកស្រី ដែលលោកស្រីបានឆ្លើយជូនចៅក្រមស៊ើបអង្កេត គឺឯកសារ E3/378, ជាភាសាខ្មែរ 00349539 រហូតទៅដល់ទៅ40, ជាភាសាបារាំង 00342203, ជាភាសាអង់គ្លេស 00345541។ នេះជាអ្វីដែលលោកស្រីបានឆ្លើយ៖ "ខ្ញុំសូមបញ្ជាក់អស់លោកឲ្យបានជ្រាបថា នៅសម័យនោះ នាងខ្ញុំនិងស្វាមីបានរស់នៅបែកពីគ្នា។ នាងខ្ញុំរស់នៅជាមួយមនុស្សឯទៀតក្នុងអគារនៃក្រសួងសង្គមកិច្ច ចំណែកស្វាមីរបស់នាងខ្ញុំបានរស់នៅទីកន្លែងផ្សេង ប៉ុន្តែនៅពេលដែលពួកនាងខ្ញុំត្រូវការជួបគ្នាជាលក្ខណៈប្ដីប្រពន្ធនោះ លោកស្រី ស៊ូ បានឲ្យពួកយើងខ្ចីបន្ទប់មួយនៅក្នុងគេហដ្ឋានរបស់គាត់។ ចាប់តាំងពីថ្ងៃដែលនាងខ្ញុំបានទទួលព័ត៌មានថា ក្រុមគ្រួសាររបស់បង វ៉ាសែ ត្រូវបានបាត់ខ្លួនមក លោកស្រី ស៊ូ បានហាមប្រាមនាងខ្ញុំកុំឲ្យមកគេហដ្ឋានរបស់គាត់ជាមួយស្វាមីរបស់នាងខ្ញុំទៀត។"

ដូច្នេះក្នុងចម្លើយនេះគឺថា ស៊ូ បានរៀបចំឲ្យលោកស្រីមកជួបគ្នាជាលក្ខណៈប្ដីប្រពន្ធនៅក្នុងផ្ទះគាត់ គឺជួយសម្រួល។ អ៊ីចឹងចំពោះគូផ្សេងទៀតហ្នឹង ស៊ូ គាត់មានបានរៀបចំសម្រួលឲ្យប្ដីប្រពន្ធទៅជួប

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គ្នានៅក្នុងបន្ទប់ផ្ទះគាត់អ៊ីចឹងដូចលោកស្រីទេ?

[១៥:០៧:១៤]

**ឆ៖** គាត់ ខ្ញុំនៅផ្ទះគាត់ ព្រោះគាត់នៅខាងក្រោម ជាវីឡា ដូចជាវីឡា ដូចផ្ទះមួយធំ។ ខ្ញុំនៅជាន់លើ ហើយក្នុងជាន់លើហ្នឹងមានបន្ទប់មួយទៀត មានប្អូនស្រីម្នាក់ដែលការជាមួយនឹង ខន។ ខន ដែលមកពីស្រុកបារាំងដែរហ្នឹង ទាំងអស់មានបីគូ។ ខន ហ្នឹង ពួកខ្ញុំនៅបន្ទប់ដោយឡែក គាត់នៅបន្ទប់ដោយឡែក ប៉ុន្តែនៅក្នុងជាន់ដូចគ្នា។ ហើយមួយគូមួយទៀត ដឹងគាត់នៅផ្ទះផ្សេង។ ដល់ពេល នៅពេលដែលគេដឹងថា បងស៊ូ គាត់ប្រាប់ខ្ញុំថា ឪពុកម្តាយ ហើយនិងប្អូនរបស់គាត់ត្រូវគេយកទៅ គាត់ផ្លាស់ខ្ញុំចេញ។ គាត់ប្រាប់ខ្ញុំថា កុំមកនៅ ឈប់នៅហ្នឹងទៀត ឲ្យទៅៗផ្ទះផ្សេងទៀត។ ផ្ទះផ្សេងទៀតហ្នឹង ជាផ្ទះដែលគូទី៣ ដែលខ្ញុំនិយាយអំមិញថាមានបីគូហ្នឹង គាត់នៅនុ៎ង។ ជាផ្ទះ ជាបន្ទប់ល្វែង ខ្មែរយើងថាបន្ទប់ល្វែង។ ផ្ទះ បងស៊ូ ជាវីឡា។

**ស៖** អ៊ីចឹងក្រោយពីរៀបការរួច ដែលកើតឡើងនៅខែកញ្ញា ឆ្នាំ៧៦ហ្នឹង លោកស្រីមានផ្ទៃពោះនៅពេលណាដែរ? ហើយលោកស្រីសម្រាលកូននៅពេលណាដែរ?

**ឆ៖** ខ្ញុំផ្ទៃពោះប្រហែលជា--

**ប្រធានអង្គជំនុំ៖**

កុំអាល! កុំអាលទាន់ឆ្លើយ! សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី រ៉ិចទ័រ កូប៉េ!

[១៥:០៨:០៩]

**លោក រ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជាភស្តុតាងដ៏គួរឲ្យចាប់អារម្មណ៍មួយ ប៉ុន្តែខ្ញុំគិតថា ខ្ញុំបាននិយាយច្រើនដងរួចមកហើយ ថាយើងនៅក្នុងផ្នែកនិយាយអំពីតួនាទីរបស់ជនជាប់ចោទ។ <ដំបូង>យើង<ឮ>សួរអំពីក្រសួងសង្គមកិច្ច។ <ពេលនេះ> យើង<ឮ>សួរអំពីការរៀបការរបស់សាក្សីនេះ។ ប៉ុន្តែខ្ញុំគ្រាន់តែចង់ដឹងថា ហេតុអ្វីក៏យើង<ស្តាប់សក្ខីកម្មរបស់បុគ្គល>នេះ<>នៅផ្នែកចុងក្រោយនៃសវនាការនេះនៅពេលដែល<>មាន<សាក្សីសំខាន់ៗ>ជាច្រើន<ផ្សេងទៀតដូចជា ហេង សំរិន ជាដើម ដែលអាចផ្តល់សក្ខីកម្មដែរ>នោះ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតប។ ខ្ញុំបានចាប់ផ្ដើមសួរអំពីការរៀបការហើយ ហើយខ្ញុំក៏នឹងចូលទៅតួនាទីរបស់ជនជាប់ចោទ និងការជួប<ប្រជុំ>របស់សាក្សីជាមួយនឹងជនជាប់ចោទ។ ហើយខ្ញុំក៏នឹងនិយាយអំពីការបាត់ខ្លួន និងការចាប់ខ្លួនមនុស្សនៅក្នុងក្រសួងហ្នឹងដែរ ព្រោះថា វាពាក់ព័ន្ធទៅនឹងស-២១។ អ៊ីចឹងប្រធានបទទាំងបីរបស់ខ្ញុំហ្នឹង គឺចូលទៅក្នុងវិសាលភាពហើយ ហើយខ្ញុំសួរទៅតាមលំដាប់លំដោយដែលខ្ញុំចង់ ហើយគឺអង្គជំនុំជម្រះជាអ្នកសម្រេចដាក់បញ្ចូលសាក្សីរូបនេះទៅក្នុងវគ្គពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទនេះ។ អ៊ីចឹងខ្ញុំគោរពទៅតាមជម្រើសរបស់អង្គជំនុំជម្រះ។ <សហព្រះរាជអាជ្ញាបានស្នើសុំថា សាក្សីនេះត្រូវផ្ដល់សក្ខីកម្មនៅក្នុងវគ្គបោសសម្អាតផ្ទៃក្នុង និងការរៀបការ។> អ៊ីចឹង ខ្ញុំគិតថា ដូចជាអត់មានអីខុសពីវិសាលភាពទេ។ ឥឡូវខ្ញុំសួរពីរបីសំណួរទៀត ពាក់ព័ន្ធនឹងការរៀបការ ហើយក្រោយមក ខ្ញុំនឹងចូលទៅដល់តួនាទីរបស់ជនជាប់ចោទហើយលោកប្រធាន។

[១៥:១០:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ! តែទោះបីយ៉ាងណាក៏ដោយ ការកត់សម្គាល់របស់មេធាវីការពារក្ដី គឺជាការសមហេតុសមផលហើយដែរ ពីព្រោះថា យើងបានកំណត់កាលបរិច្ឆេទនៃការស្ដាប់សក្ខីកម្មសាក្សីដែលយើងកំណត់អង្គហេតុច្បាស់លាស់។ អង្គហេតុច្បាស់លាស់ជាក់លាក់នេះ គេហៅអង្គហេតុចម្បង។ ចំណែកអង្គហេតុផ្សេងទៀត បន្ទាប់បន្សំនោះទេ ហើយគួរតែប្រើប្រាស់ពេលវេលាឲ្យមានវាមានប្រសិទ្ធភាព។ យើងឃើញថាវាពាក់ព័ន្ធ អ្វីក៏ពាក់ព័ន្ធដែរ បើនិយាយពីអង្គហេតុដែលពាក់ព័ន្ធហ្នឹង ហើយនិងសាក្សីដែលពាក់ព័ន្ធឆ្លើយទៅណាក៏ត្រូវដែរ ពីព្រោះអង្គហេតុកើតឡើងទូទាំងប្រទេសកម្ពុជា។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ យើងត្រូវគោរពគោលការណ៍នៃការបែងចែក បែងចែកកំណត់អង្គហេតុសម្រាប់ធ្វើសវនាការជាក់លាក់ដែរ ដើម្បីឲ្យវាមានភាពច្បាស់លាស់។ អ៊ីចឹងរវាង អ្វីដែលជាចម្បង អ្វីជាបន្ទាប់បន្សំ គួរតែត្រូវបានជ្រើសរើសឲ្យបានច្បាស់លាស់ ហើយប្រើពេលវេលាឲ្យមានប្រសិទ្ធភាព ពីព្រោះយើងឥឡូវហ្នឹង យើងសុខចិត្តមិនសម្រាកទេ បានន័យថា មូលហេតុគឺពេលវេលា ដែលវាចង្អៀតពេក យើងបារម្ភថា ក្រែងលោវាធ្វើទៅមិនចប់ វានឹងឲ្យបង្កើតឡើងនូវបញ្ហាផ្សេងទៀតដែលកើតឡើងបន្តទៅសប្ដាហ៍បន្តបន្ទាប់ទៀត ដែលវាពាក់ព័ន្ធជាមួយនឹងការរៀបចំ នូវប្រព័ន្ធសោតទស្សន៍ក៏ដូចជាការដែលអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏សាក្សីម្ដងហើយ ម្ដងទៀត ម្នាក់មកពីរបីដង ហើយត្រឡប់ទៅវិញ ប្អូនដប់ថ្ងៃបានមកទៀត ជាការមិនល្អទេ។ សិទ្ធិយើងមាន ប៉ុន្តែគួរតែគោរពការលក្ខខណ្ឌចាំបាច់

ចំពោះអ្នកដទៃផងដែរ។

[១៥:១២:២៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ឥឡូវខ្ញុំចង់សួរលោកស្រីថា លោកស្រីមានផ្ទៃពោះ<ទេ>? ហើយលោកស្រីសម្រាលកូននៅពេលណា?

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** ខ្ញុំប្រហែលជា ប្រាំប្រាំមួយខែមក ខ្ញុំមានទម្ងន់ ហើយខ្ញុំឆ្លងទន្លេកូនខ្ញុំ នៅខែទី១ កូនខ្ញុំកើតនៅថ្ងៃ១៣ ខែទី១ ១៩៧៨។

**ស៖** ឥឡូវនេះខ្ញុំចូលទៅប្រធានបទមួយផ្សេងទៀត គឺជំនួបរបស់លោកស្រីជាមួយនឹង នួន ជា និងខៀវ សំផន <បើលោកស្រីបានចូលរួមប្រជុំបែបនេះ> និងតួនាទីរបស់បុគ្គលទាំងពីររូបនេះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ <តើលោកស្រីបានដឹងអ្វីខ្លះ បានឃើញអ្វីខ្លះ>?

[១៥:១៤:០២]

**ឆ៖** ចាស ខ្ញុំធ្លាប់ឃើញគាត់ពីរ ឬបីដង ពីរដង--។ លើកទី១ នៅឆ្នាំ៧៥ នៅពេលដែលពួកខ្ញុំទៅកត់នូវថ្នាំពេទ្យនៅភ្នំពេញ។ ទាំងអស់គ្នាបីនាក់ហ្នឹង ទៅជួបគាត់ឃើញគាត់ ពីដើមខ្ញុំអត់ដឹងថា នួន ជា ជាអ្នកណាគេទេ។ ប៉ុន្តែគាត់មក គាត់ជិះឡានហ្ស៊ីប ជាមួយនឹងអង្គរក្សរបស់គាត់ អ្នកបើកឡាន ហើយនិងអ្នកការពាររបស់គាត់ មកជួបពួកខ្ញុំ ព្រោះពួកខ្ញុំពេលទៅហ្នឹង នៅភ្នំពេញអត់មានមនុស្សទេ។ ដូច្នេះឃើញពួកខ្ញុំ ចេញមកក្រៅអ៊ីចឹង ពីកន្លែងថ្នាំ គាត់សួរថា អ្នកឯងមកពីខាងណា? ហើយពួកខ្ញុំឆ្លើយថា ពួកខ្ញុំមកពីខាងសង្គមកិច្ច។ ហ្នឹងលើកទី១ ដែលខ្ញុំជួបនៅឆ្នាំ៧៥ ប្រហែលជាប្រាំប្រាំមួយខែ ពេលចូលទៅភ្នំពេញ។ លើកទី២ នៅពេលប្រជុំពេលនុ៎ង ដូចជា៧៦ដែរ។ ឆ្នាំ៧៦ គេមានការប្រជុំច្រើន ពេលនុ៎ងសភាពតានតឹងនៅស្រុកខ្មែរ មិនជាខ្លាំងណាស់ណាទេ។ មានការប្រជុំអ្នកទៅច្រើន គ្នាច្រើន ប៉ុន្តែមិនដឹងប៉ុន្មាននាក់ទេ ពេលនោះ ពេលទៅខ្ញុំៗអត់ស្គាល់នរណាទេ ក្រៅពីអ្នកធ្វើការទៅជាមួយខ្ញុំ គ្នាច្រើនដែរ មានក្មេង មានគ្រប់ៗក្រសួងមក។ ខ្ញុំជួបលើកទី២ហ្នឹង គឺគាត់ជាអ្នកប្រជុំ។ ប្រជុំ ជាអ្នកនិយាយ ៗពីស្ថានការណ៍ស្រុកខ្មែរអ៊ីចឹង គឺគាត់ឃើញ នួន ជា។ ខ្ញុំអត់មានស្គាល់ ប៉ុល ពត ខ្ញុំអត់មានស្គាល់អ្នកណា

ទេ ឃើញគាត់ជាអ្នកនិយាយ ជាលើកទី២។ លើកទី៣ ខ្ញុំឃើញគាត់ នៅពេលដែលខ្ញុំ ៗនិយាយពីរឿងរៀបចំថ្នាំហ្នឹងមក ឃើញគាត់មួយលើកទៀត មកសង្គមកិច្ច ពេលនោះសង្គមកិច្ចកំពុងតែចាប់ផ្ដើមកសាង។ ដូច្នេះគាត់មក គាត់ជួប។ ពេលនោះ បងស៊ូ ខ្ញុំស្គាល់ បងស៊ូ ហើយ គាត់មកជួប បងស៊ូ។ ឃើញគាត់ដើរកាត់តាមផ្លូវមក គាត់ជួប បងស៊ូ។ ខ្ញុំឃើញគាត់តែបីនុ៎ង បីដងហ្នឹងទេ ចំពោះលោក នួន ជា។

**ស៖** ទាក់ទងទៅនឹងកាលប្បវត្តិកិច្ចប្រជុំទី៣ គឺការជួបលើកទី៣ ដែលលោកស្រីបានជួបគាត់នុ៎ង គឺនៅ ក-២។ តើមុន <ឬក្រោយ>ពេលប្រជុំនៅឆ្នាំ១៩៧៦ ដែលគាត់បានឡើងនិយាយ ឬក៏យ៉ាងណា?

[១៥:១៧:១៣]

**ឆ៖** ខ្ញុំថា ខ្ញុំមិនបានចាំច្បាស់ មុន ព្រោះកាលនុ៎ង គេអត់មានទាន់ការជ្រើសបែងចែកអ្នកណាអ្នកណីនៅឡើយទេ នៅឡើយទេ។ អ្នកណាទើបមកថ្មីអ៊ីចឹង គេ -- ការទទួលជ័យជម្នះថ្មី ដូច្នេះមានការប្រជុំគ្នាច្រើន រាប់រយនាក់ សឹង៣.០០០ពាន់ផង តាមខ្ញុំយល់ ដូច្នេះជាលើកដំបូង ថ្មីៗ នៅឆ្នាំ៧៦ហ្នឹង។ ហើយជួបលើកទី១ ខ្ញុំអត់ចាប់អារម្មណ៍ ខ្ញុំអត់ចាប់អារម្មណ៍គាត់ជាអ្នកណាទេ ពីព្រោះខ្ញុំអត់ដែលស្គាល់គាត់ផង ហើយខ្ញុំឃើញគាត់អ៊ីចឹង ខ្ញុំមិនបានចាប់អារម្មណ៍ថាជា គាត់មានមុខងាររបស់គាត់ធំអី ខ្ញុំអត់ចាប់អារម្មណ៍។

**ស៖** នៅពេលដែលគាត់មកក្រសួង គឺមក ក-២នេះ តើពេលហ្នឹងគាត់មកដើម្បីចូលរួមប្រជុំមួយ? លោកស្រីបាននិយាយថា គាត់មកជួប បងស៊ូ។ តើក្រៅពីហ្នឹង គាត់មានមកចូលរួមប្រជុំ ហើយលោកស្រីក៏មានវត្តមាននៅទីនុ៎ងដែរឬទេ កាលដែលគាត់មកហ្នឹង?

**ឆ៖** អត់ទេ ពេលនុ៎ងខ្ញុំមិនដឹងថា គេមានប្រជុំអត់ៗ ខ្ញុំអត់ដឹងទេ។ ពេលនុ៎ងពួកខ្ញុំនៅខាងក្រៅទាំងអស់គ្នា ប៉ុន្តែពេលនោះខ្ញុំអត់ស្គាល់ទាំង អៀង ធីរិទ្ធ គាត់មកទេ។ អៀង ធីរិទ្ធ ខ្ញុំអត់ដែល មុននឹងសង្គមកិច្ចរៀបចំស្រួលបួល រូប អៀង ធីរិទ្ធ ខ្ញុំអត់ស្គាល់ទេ ដូច្នេះមានតែ បងស៊ូ ដែលខ្ញុំស្គាល់។ លើកទី១ គាត់មក ខ្ញុំឃើញគាត់ដើរកាត់ផ្ទះមក ហើយមានទៅជួបពីណា មានតែជួប បងស៊ូ ជាអ្នកទទួលខុសត្រូវនៅក្នុងមន្ទីរ។ មើល៍ ខ្ញុំអត់ដឹងថាប្រជុំឬអត់ ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំដឹងថា គាត់មកជួប បងស៊ូ ព្រោះបងស៊ូ អ្នកទទួលខុសត្រូវនៅនុ៎ង។ ហើយពួកខ្ញុំនៅនុ៎ង នៅទើបចាប់ផ្ដើម មានតែក្មេងៗ ដូច្នេះអត់មានជួបពីណា គាត់មានត្រូវមកជួបពីណា មានតែ បងស៊ូ ហ្នឹងឯង។

[១៥:១៩:៤៥]

**ស៖** តើ បងស៊ូ នោះ ឬក៏ យាយភា ឬ អៀង ធីរិទ្ធ នេះ គាត់មានដែលធ្លាប់និយាយប្រាប់លោកស្រី អំពីទំនាក់ទំនង<ដែលមាន> បើសិនជាមាន<ដូចជាទំនាក់ទំនង> រវាងក្រសួងសង្គមកិច្ច និង នួន ជា ដែរឬទេ?

**ឆ៖** គាត់អត់ដែលនិយាយផង។ ក្នុងជំនាន់នុ៎ង ការប្រជុំវាមានពីរយ៉ាង។ ប្រជុំទី១ ប្រជុំអ្នកដែលគេនៅក្នុងជួរបក្ស។ ប្រជុំមួយទៀត ប្រជុំទូទៅ។ ប្រជុំទូទៅ ខ្ញុំប្រជុំ ព្រោះខ្ញុំអត់នៅក្នុងបក្ស ជួរបក្សទេ។ ដូច្នេះការសម្ងាត់ក្តី ឬស្អីក្តី ខ្ញុំអត់មានដឹងអី ខ្ញុំអត់។ គេនិយាយពីអី ខ្ញុំអត់ដឹង ព្រោះខ្ញុំអត់ចូលបក្ស។ ប្រជុំទូទៅ មានទាំងអស់គ្នា មានខ្ញុំចូលទៅ។

**ស៖** នៅក្នុងសំណុំរឿងគឺមានឯកសារ <E3/1733> ដែលជាកំណត់ហេតុប្រជុំនៃគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៥ នៅទំព័រទី១ ជាភាសាទាំងបីហ្នឹង គឺថា<សមមិត្ត ស៊ូ> លេខាដែលទទួលបន្ទុកការងារបក្ស ហើយសង្គមកិច្ច វប្បធម៌ ឃោសនាការ ហើយនិងអប់រំ។ ហើយសមមិត្ត ភា នោះទទួលបន្ទុកខាងវប្បធម៌ សង្គមកិច្ច និងកិច្ចការបរទេស។ ហើយ<ឈ្មោះ>សមមិត្ត ភា នេះមាននៅទំព័រទី២ នៃឯកសារនេះ។ តើលោកស្រី<អាច>បញ្ជាក់<បាន>ដែរឬទេ ថាមិនដែលមានគេប្រាប់លោកស្រីថា នួន ជា នេះមានឥទ្ធិពល ឬក៏មានអំណាចលើក្រសួងសង្គមកិច្ចទេ?

[១៥:២២:១៩]

**ឆ៖** ខ្ញុំអត់ដឹងទេ។ ខ្ញុំអត់ គេអត់ដែលនិយាយទេ ប៉ុន្តែគ្រាន់មានម្តង បងស្រីម្នាក់គាត់កាត់ គាត់ជាអ្នកបកប្រែ គាត់កាត់ចិន-ខ្មែរ។ គាត់ពីដើម គាត់មានប្តីរបស់គាត់ តាមខ្ញុំ គ្រាន់ខ្ញុំដឹងពីរឿងប្តីរបស់គាត់ កាលជំនាន់សម្តេច ប្តីគាត់ជាប់គុក ជាប់គុកយូរឆ្នាំដែរ។ ដល់ពេលចេញមក គាត់រត់ពីគុកទៅធ្វើការជាមួយពួកខ្មែរក្រហមក្នុងព្រៃ។ បងស្រីហ្នឹង ពីដើមគាត់មិនមកនៅជាមួយ ផ្ទះមួយពួកក្មេងៗជាមួយពួកខ្ញុំទេ នៅក្នុងផ្ទះល្វែងទេ គាត់នៅផ្ទះវីឡាមួយ ព្រោះប្តីគាត់ តាមខ្ញុំឮគាត់និយាយថា ធ្វើការជាមួយបង ប៉ុន្តែមិនដឹងបងណា ខ្ញុំមិនដឹងដែរ។ នៅពេលដែលថ្ងៃមួយ គាត់និយាយថា គាត់អត់មានសិទ្ធិទៅនៅផ្ទះនុ៎ងទៀតទេ ព្រោះលោក នួន ជា ហ្នឹងគាត់ដើរ គាត់ជិះឡានមក គាត់សួរថា ផ្ទះហ្នឹងពីណានៅផ្ទះធំហ្នឹង? ហើយគេប្រាប់ថា គាត់ហ្នឹង គាត់ប្តីគាត់ គាត់នៅហ្នឹង ព្រោះប្តីគាត់មកពី មកជួបគាត់នៅហ្នឹង។ ហើយលោក នួន ជា ថាអត់មានឲ្យនៅទៀតទេ អត់មានសិទ្ធិនៅទេ ដូច្នេះត្រូវគាត់មកនៅជាមួយពួកខ្ញុំវិញ។ ពេលណាប្តីគាត់មក បានគាត់ឲ្យទៅ ឲ្យទៅនៅផ្ទះនុ៎ង។ ដូចករណីរបស់ខ្ញុំអ៊ីចឹង គឺថា

ទាល់ជួបគ្នានៅពេលម្តងៗនៅផ្ទះ បងស៊ូ។ បងស្រីហ្នឹងអ៊ីចឹងដែរ ដូច្នេះតាំងពីនុំងមកខ្ញុំដឹងថា គាត់ហ្នឹងខ្លាំងហើយបានជា ព្រោះគាត់ហ្នឹងខ្លាំងហើយ បានជាមានសិទ្ធិដកបងស្រីហ្នឹង ដែលប្តីគាត់ធ្វើការជាមួយបង អង្គការធំ។ លោក នួន ជា ហ្នឹងមានសិទ្ធិធំហើយ បានឲ្យប្រពន្ធគាត់ ប្រពន្ធរបស់លោកហ្នឹង មកនៅជាមួយពួកខ្ញុំ។ ហើយដូច្នេះគាត់មានសិទ្ធិលើលោក លើ អៀង ធីរិទ្ធ ទៅទៀត ពីព្រោះធម្មតា សង្គមកិច្ច អៀង ធីរិទ្ធ ជាអ្នកទទួលខុសត្រូវលើ បងស៊ូ ទៅទៀត។ ដូច្នេះខ្ញុំពេលនោះ ខ្ញុំមានការចាប់អារម្មណ៍ថា មុខងាររបស់លោក នួន ជា មិនមែនតូចទេ ប៉ុន្តែមិនដឹងធ្វើអី ខ្ញុំអត់ដឹងដែរ។

**ប្រធានអង្គជំនុំ៖**

សូមផ្អាកមួយនាទី ប្តូរ ដូរឌីសថតសំឡេង។

*(ប្តូរឌីវីឌីថតសំឡេង)*

[១៥:២៥:១៦]

**ប្រធានអង្គជំនុំ៖**

បាទ សុំអញ្ជើញបន្តទៀតសហព្រះរាជអាជ្ញារងអន្តរជាតិ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

**ស៖** លោកស្រីសាក្សី តើ អៀង ធីរិទ្ធ នេះគាត់អវត្តមានញឹកញាប់ដែរឬទេ បើតាមលោកស្រីដឹងនោះ គឺគាត់អវត្តមានដើម្បីទៅចូលរួមកិច្ចប្រជុំជាមួយមេរបស់គាត់មួយចំនួន ឬក៏មេរបស់គាត់តែម្នាក់ទេ? <តើស៊ូធ្លាប់ប្រាប់លោកស្រីអំពីរឿងនេះទេ?> តើ អៀង ធីរិទ្ធ ធ្លាប់និយាយអំពីបញ្ហាហ្នឹងទេ? ឬក៏មានអ្នកណាម្នាក់ធ្លាប់និយាយប្រាប់លោកស្រីអំពីការដែលគាត់អវត្តមាន ដើម្បីទៅប្រជុំជាមួយមេរបស់គាត់?

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** អ៎! បញ្ហាហ្នឹងឆ្ងាយណាស់ ខ្ញុំអត់ដែលដឹងសោះ គេមិនដែលនិយាយទេ ប្រជុំអ៊ីចឹងៗ គេអត់ៗទេ។

**ស៖** តើលោកស្រីមានធ្លាប់ឮនិយាយអំពីកន្លែងផ្សេងទៀត ក្រៅពីក-២ដែរឬទេ ដូចជាក-១ ឬក៏ ក-៣ ជាដើមនេះ? លោកស្រីមានធ្លាប់ឮគេនិយាយពីមន្ទីរអស់ហ្នឹងទេ?

**ឆ៖** ខ្ញុំអត់យល់សំណួរ។ ក-១ ខ្ញុំដឹងថាជាក្រសួងរបស់ប្តីរបស់គាត់។ ក-២ របស់គាត់។ ខ្ញុំមិនយល់សំណួរ តើចង់សួរខ្ញុំថាយ៉ាងម៉េច? ចាស សុំទោស។

**ស៖** ខ្ញុំចង់ដឹង ថាតើលោកស្រីមានធ្លាប់ឮ<>អំពីក-១ និងក-៣ ដែរឬទេ? ហើយខ្ញុំចង់ដឹងថា ក-១ ឬក-៣នេះ<មានន័យថាម៉េច? ហើយ>អ្នកណាខ្លះធ្វើការ <និងរស់>នៅទីហ្នឹង? <>

[១៥:២៧:២៤]

**ឆ៖** ក-១ ខ្ញុំអត់ដែលទៅ ប៉ុន្តែដឹងថានៅជាក្រសួងភៀវ បរទេស ដែលប្ដីរបស់គាត់ អៀង សារី។ ក-៣ ខ្ញុំអត់ចាំទេ ក-៣ ស្អី? ក-៣ស្អីខាងមន្ទីរពេទ្យៗ។

**ស៖** តើលោកស្រីអាចច្រឡំអំពីមន្ទីរក-១ នេះជាមួយនឹងប-១ទេដឹង លោកស្រី? ក-១ ហើយ និងប-១ នេះណា?

**ឆ៖** អ៎!ចាស ប្រហែលចាស។ ក-១ៗ គឺកន្លែងផលិតថ្នាំ *សេសា*។ ខ្ញុំដឹងថា ខ្ញុំអត់ដឹង ខ្ញុំអារឿង "ក" ខ្ញុំអត់ចាំទេ ប៉ុន្តែដឹង គ្រាន់ខ្ញុំដឹងថា កន្លែងពិសោធថ្នាំ *ឡាប័រកាទ័រ* បារាំងយើងថា *ឡាប័រកាទ័រ* គឺកូនស្រីរបស់គាត់ ពៅគេអ្នកទទួលខុសត្រូវ នៅជ្រោយចង្វា។ កូនស្រីបងគេ -- កូនស្រីទី២ *ណាង* កូនស្រីពៅគេ នៅខាងធ្វើថ្នាំពេទ្យខ្មែរ--

**ស៖** បាទ លោកស្រី <>អត់បញ្ហាអ្វីទេ។ <>លោកស្រី ខ្ញុំសួរសំណួរមួយ តើលោកស្រីធ្លាប់ចូលប្រជុំជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ហើយនិងកម្មាភិបាលនៃក្រសួងសង្គមកិច្ច ដើម្បីធ្វើការបូកសរុបប្រចាំឆ្នាំអំពីសកម្មភាពនៃក្រសួងសង្គមកិច្ចនេះដែរឬទេ? ហើយបើមិនអ៊ីចឹងទេ បើអត់បានចូលរួមទេ តើលោកស្រីធ្លាប់ឮគេនិយាយអំពីកិច្ចប្រជុំហ្នឹងដែរឬទេ ប្រជុំបូកសរុប?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោកស្រី!

[១៥:២៩:៣៨]

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** ធ្លាប់ធម្មតាគេ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់ឆ្លើយ!

សុំអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំជំទាស់ទៅនឹងសំណួរនេះ។ សាក្សី<ទើបតែ>បានបញ្ជាក់<>ថា គាត់មិន

មែនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា<ទេ> ហើយគាត់មិនដែលក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុ-ជានោះឡើយ។ ដូច្នេះគាត់មិនអាចឆ្លើយបានថាតើអ្នកណាជាមន្ត្រីជាន់ខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជាបានឡើយ។ ការសួរបែបនេះ គឺបានន័យថា ជាការឲ្យគាត់ទាយស្មានប៉ុណ្ណោះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សំណួរខ្ញុំ <ខុសពីនោះ។ ខ្ញុំចង់ដឹង>ថាតើគាត់បានចូលរួមក្នុងកិច្ចប្រជុំ<ណា>មួយដែលមានអ្នកដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងកម្មាភិបាលរបស់ក្រសួងសង្គមកិច្ច ដើម្បីធ្វើការបូកសរុប<ការងារប្រចាំឆ្នាំរបស់ក្រសួង>។ ហើយខ្ញុំសួរគាត់ទៀត ថាបើសិនជាគាត់មិនបានចូលរួមក្នុងកិច្ចប្រជុំហ្នឹងទេ តើគាត់ធ្លាប់ឮគេនិយាយអំពីកិច្ចប្រជុំបូកសរុបសកម្មភាពហ្នឹងដែរឬក៏អត់។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែដោយសារតែមិនមែនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា គាត់មិនអាចឆ្លើយបានថាអ្នកណាជាសមាជិក ឬក៏ជាអ្វីនោះបានឡើយ។ <វាមិនដូចថា ពួកគេមានពាក់របស់នៅលើអាវ ឬមានអ្វីផ្សេង។>

[១៥:៣០៥២០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ប៉ុន្តែអាចមាននរណាម្នាក់បានប្រាប់គាត់។> ខ្ញុំគិតថា នេះជាចំណុចដែលព្រះរាជអាជ្ញាចង់បាន។ ដូច្នេះហេតុអ្វីក៏យើងមិនទុកឲ្យព្រះរាជអាជ្ញាសួរ ហើយឲ្យសាក្សីឆ្លើយទៅវិញទៅ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកស្រីមានធ្លាប់ឮគេនិយាយពីកិច្ចប្រជុំនោះដែលគេប្រមូលលេខា អនុលេខា ហើយនិងថ្នាក់ដឹកនាំ<>បក្សកុម្មុយនីស្តកម្ពុជា មកប្រជុំជាមួយនឹងកម្មាភិបាល<ជាន់ខ្ពស់>នៃក្រសួងសង្គមកិច្ចដែរឬទេ?

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** បញ្ហាហ្នឹងខ្ញុំមិនដែលអត់ដឹងទេ ព្រោះដូចខ្ញុំជម្រាបអ៊ីចឹងថា នៅពេលណាយើងអត់ចូលក្នុងបក្សរបស់គេ ការប្រជុំវាមានដោយឡែកមួយសម្រាប់ប្រជុំទាំងអស់គ្នា ប្រជុំបក្សប្រជុំដោយឡែក។ ដូច្នេះបើគេប្រជុំ ក៏គេអត់ឲ្យខ្ញុំដឹងដែរ គេនិយាយពីស្អីខ្លះ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំអត់មាននៅក្នុងបក្សកុម្មុយនីស្តរបស់គេទេ។ ដូច្នេះគេអត់មានទុកចិត្តឲ្យយើងចូលទេ ឬក៏អត់និយាយឲ្យយើងដឹងឡើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ឥឡូវខ្ញុំសូមនិយាយអំពីកិច្ចប្រជុំនៅឆ្នាំ១៩៧៦ មហាសន្និបាតដែលលោកស្រីបាននិយាយថា ពេលនោះ នួន ជា ឡើងធ្វើឧទ្ទេសនាម។ តើមហាសន្និបាតហ្នឹងបានប្រព្រឹត្តទៅ<ក្នុងកាលៈទេសៈអ្វី?> នៅពេលណាដែរ? ហើយនៅកន្លែងណា? ហើយមានអ្នកចូលរួមប៉ុន្មាននាក់ដែរ?

[១៥:៣២:៣២]

**ឆ៖** ខ្ញុំមិន -- ខ្ញុំដឹងថានៅភ្នំពេញ ប៉ុន្តែកន្លែងណាច្បាស់ ខ្ញុំមិនស្គាល់ភ្នំពេញច្បាស់ទេ ពីព្រោះទៅជាមួយគេ។ ហើយជាៗលើកដំបូងដែលពួកខ្មែរក្រហមឈ្នះ ដូច្នេះមានមនុស្សច្រើនទាំងអស់គ្នា មិនដឹងប៉ុន្មាននាក់ ប៉ុន្តែរាប់រយ ហើយអាចរាប់ពាន់ ព្រោះគេហ្នឹងគេអត់មានរើសថាអ្នកណាចូលបក្ស មិនចូលបក្សទេ គេទៅដើម្បីនិយាយថា ខាងខ្មែរក្រហមឈ្នះ ជាលើកៗទី១។ ដូច្នេះពេលនុ៎ង ផែនការអត់តឹងតែងទេ អ្នកណាដែលបានចូលរួមនៅពេលមុនពួក គេមិនចាត់ទុកខ្ញុំជាប្រជាជនថ្មីទេ ពិតមែនខ្ញុំតែមិនចូលបក្សក៏ដោយ មិនមែនប្រជាជនថ្មីទេ មិនដូចជាប្រជាជនដែលជម្លៀសនៅភ្នំពេញទេ។ ដូច្នេះខ្ញុំអាចមានសិទ្ធិទៅប្រជុំជាមួយទៅ *សេកុង សេទីនកុងប្រេវង់* និយាយដើម្បីថា យើងបានឈ្នះហើយ អ៊ីចឹងតែប៉ុណ្ណឹង លើកទី១ ម្តងៗហ្នឹងគត់។

**ស៖** ដើម្បីឲ្យច្បាស់ទាំងអស់គ្នា លោកស្រីបាននិយាយពីឆ្នាំ១៩៧៦ ហើយនិងពីជ័យជម្នះថ្ងៃទី១៧ មេសា។ តើលោកស្រីចង់និយាយថា កិច្ចប្រជុំហ្នឹងបានប្រព្រឹត្តទៅនៅឆ្នាំ១៩៧៦ ក៏ប៉ុន្តែក្នុងឱកាសហ្នឹង គេនិយាយអំពី<ខួប>ជ័យ<ជម្នះ>នៅថ្ងៃទី១៧ មេសា ឬក៏ខ្ញុំយល់នេះ យល់ច្រឡំទេលោកស្រី?

**ឆ៖** ខ្ញុំអត់យល់សំណួរ ៧៥ ចាស ខ្ញុំប្រហែលជាច្រឡំឆ្នាំ៧៥ ៧៥, ៧២ ចិត -- ចាស ខ្ញុំសូមអ៊ំ! ដំបូងនៅក្នុងការប្រជុំ ទើបនឹងបែកថ្មីៗ ទើបនឹងបែកថ្មីៗនៅពេលដែលខ្មែរក្រហមចូល។

[១៥:៣៥:១០]

**ស៖** តើលោកស្រីនៅចាំអំពីអ្វីដែល នួន ជា បាននិយាយនៅថ្ងៃហ្នឹងដែរឬទេ ក្រៅពីអបអរសាទរជ័យជម្នះហ្នឹង? បើនិយាយឲ្យច្បាស់ទៅ តើគាត់<បាន>និយាយអំពី<អ្វីដែលអាចកើតឡើងចំពោះ> យោធា <និងអ្នករដ្ឋការ>លន់ នល់ ដែរឬទេ?

**ឆ៖** គាត់អត់មាននិយាយទេ។ ប៉ុន្តែតាមខ្ញុំយល់ គឺតាមខ្ញុំយល់ ព្រោះខ្ញុំ គេប្រជុំដោយឡែក អ្នកចូលបក្សផ្សេង អ្នកអត់ចូលផ្សេង ប៉ុន្តែពិបាកបន្តិចហើយ ព្រោះអីអ្នកដែលប្រឆាំងជាមួយ អ្នកដែលធ្វើទាហានរបស់ លន់ នល់ ពិបាកបន្តិច មិនអាច – តាមខ្ញុំយល់ គឺថាគេមិនអាចទុកឲ្យរស់ទេ។

**ស៖** ប្រធានបទចុងក្រោយ ទាក់ទងនឹងទំនាក់ទំនងរវាង អៀង ធីរិទ្ធ និង នួន ជា។ ខ្ញុំសូមឲ្យ

លោកស្រីមានប្រតិកម្មអំពីអ្វីដែល អៀង ធីរិទ្ធ គាត់និយាយអំពីទំនាក់ទំនងគាត់ជាមួយ នួន ជា មុនពេលដែល<គាត់ត្រូវបានពិចារណាថា មិនមានកាយសម្បទាគ្រប់គ្រាន់ ដើម្បី>ចូលរួមក្នុងការជំនុំជម្រះក្តីគាត់ទេ។ <នេះជាអ្វីដែលគាត់បាននិយាយ ជាការកត់សម្គាល់ គាត់បាននិយាយពីរឿងនេះច្រើនណាស់ ប៉ុន្តែ>នៅក្នុង<>ប្រតិចារឹកនៃ<សវនាការអង្គបុរេជំនុំជម្រះ នៅ>ថ្ងៃទី២៤ កុម្ភៈ ឆ្នាំ២០០៩ គឺឯកសារ E3/39 នៅម៉ោង១១:៥៩នាទី។ “និស្សិតខ្ញុំទាំងអស់នោះ ត្រូវបានចាប់ ហើយសម្លាប់។ ទាំងអស់នេះសុទ្ធតែជាកំហុសរបស់ នួន ជា។ អ៊ីចឹងកុំឲ្យយកខ្ញុំមកបូកបញ្ចូលជាមួយ នួន ជា។ គឺ នួន ជា នេះហើយអ្នកកម្ទេចកូនសិស្សរបស់ខ្ញុំ។ អយុត្តិធម៌ណាស់ គឺ នួន ជា គាត់អ្នកធ្វើរឿងរ៉ាវទាំងអស់ហ្នឹង។”

នៅម៉ោង១២:០៥នាទី អៀង ធីរិទ្ធ ឡើងផងដែរ នៅថ្ងៃដដែល។ លោកប្រធាន ខ្ញុំសូមបញ្ចប់ បើសិនជាលោកប្រធានមិនយល់ទាស់អីទេ។ “នៅពេលដែល នួន ជា នាំនិស្សិតរបស់ខ្ញុំទៅឲ្យ ឌុច ហៅ កាំង ហ្កេកអ៊ាវ សម្លាប់នោះ អ៊ីចឹងហើយនៅពេលនោះហើយដែលខ្ញុំដឹងថា មានរឿងអ្វីកើតឡើង ហើយខ្ញុំដឹងថាគាត់ធ្វើអី។ នៅសល់ មានកូនសិស្សមួយទេ ដែល<ខ្ញុំប្រគល់ការងារឲ្យ>គាត់ធ្វើការនៅមន្ទីរ។ ហើយអ្នកផ្សេងទៀតនោះ ធ្វើការនៅកន្លែងផលិតថ្នាំ <និងមន្ទីរពេទ្យ> ត្រូវបានសម្លាប់អស់ទៅហើយ។” អ៊ីចឹងបញ្ចប់ការដកស្រង់។ សំណួរខ្ញុំដូចតទៅនេះ នៅរបបកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីធ្លាប់ឮ អៀង ធីរិទ្ធ និយាយអំពីទំនាក់ទំនង<មិនល្អ>ជាមួយ នួន ជា ដែរឬទេ? កាលសម័យនោះ គាត់មានធ្លាប់<រិះគន់>អំពីការចាប់ខ្លួនកម្មាភិបាលនៅក្រសួងសង្គមកិច្ច <ឬក៏អ្នកដែលគាត់ថាជា>កូនសិស្សរបស់<គាត់>ហ្នឹង ដែរឬទេ?

[១៥:៣៨:៣០]

**លោក វ៉ិចទ័រ កូប៉េះ**

បាទ លោកប្រធាន ខ្ញុំជំទាស់ទៅនឹងសំណួរនេះ។ ខ្ញុំមិនដឹងថា ត្រូវចាប់ផ្តើមនិយាយពីស្អីទេ ព្រោះថាវាខុសច្រើនជាន់ណាស់មកហើយ។ ទី១ ព្រះរាជអាជ្ញាអាននូវឯកសារដែល អៀង ធីរិទ្ធ បាននិយាយនៅចំពោះមុខអង្គបុរេជំនុំជម្រះ គឺច្រើនឆ្នាំណាស់មកហើយ នៅក្រោយពេលដែលអង្គហេតុបានកើតឡើង។ គឺនៅក្នុងស្ថានភាពមួយដែលយើងទាំងអស់គ្នាដឹងច្បាស់ថា គឺថានៅក្នុងស្ថានភាពមួយដែលគាត់មិនមានសម្បទាគ្រប់គ្រាន់។ ហើយការដែលដកស្រង់ពីអង្គបុរេជំនុំជម្រះ អំពីស្ថានភាពមួយដែលគាត់មិនសម្បទាគ្រប់គ្រាន់ <ខ្ញុំគិតថា>គឺប្រាកដណាស់ថា វាជាការ<ខុសប្រក្រតី។ បន្ថែមពីលើនោះ វាជាការ>នាំមុខមួយ ដោយ<ការ>អានឲ្យសាក្សីស្តាប់ ហើយបន្ទាប់មកទៀត ឲ្យសាក្សីឆ្លើយបែបនេះ។

ដូច្នេះខ្ញុំគិតថា ដោយសារតែពីរចំណុចនេះ ដែលខ្ញុំលើកឡើងនេះ គឺថាសំណួរហ្នឹង គួរតែត្រូវបានហាមឃាត់មិនឲ្យសួរ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន <ថ្មីបើ>យើងអាចគិតអំពីបញ្ហា សម្បទាបញ្ញារបស់ អៀង ធីរិទ្ធ<នៅឆ្នាំ២០០៩> យ៉ាងម៉េចក៏ដោយ <ខ្ញុំជឿថា ទើបតែនៅឆ្នាំ២០១២ទេ ដែលគេប្រកាស>ថាគាត់មិន<មានកាយសម្បទាគ្រប់គ្រាន់>ក្នុងការជំនុំជម្រះ<ក្តី។ រហូតដល់ពេល>នោះ <រាល់ការពិសោធន៍ដែលត្រូវបានធ្វើឡើងត្រូវបានអនុគ្រោះ ហើយ>វេជ្ជបណ្ឌិត<និយាយថា គាត់មានសុខភាពល្អដើម្បីធានាដល់ការការពារក្តីរបស់គាត់>។ ហើយខ្ញុំ<ផ្ទាក់ផ្អើល>ដែរដែលមេធាវី នួន ជា នេះគាត់និយាយថា យើងអានសក្ខីកម្មរបស់អ្នកណាម្នាក់ ឬក៏ចម្លើយរបស់អ្នកណាម្នាក់ ហើយយើងទៅសួរឲ្យសាក្សីហ្នឹងធ្វើសេចក្តីអត្ថាធិប្បាយ។ ហើយចំណុចនេះគឺមេធាវី នួន ជា ហ្នឹងគាត់ធ្វើតែអ៊ីចឹង មេធាវីការពារក្តី គាត់អនុវត្តតែអ៊ីចឹងដែរ លោកប្រធាន។ អ៊ីចឹងខ្ញុំគិតថា គួរតែអនុញ្ញាតឲ្យខ្ញុំសួរសំណួរនេះ ទៅកាន់លោកស្រីសាក្សី។

[១៥:៤០:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី។ សំណួរនេះ អាចសួរបាន ហើយការដកស្រង់នេះគឺដកស្រង់បានដែរ ពីព្រោះបញ្ហានេះ កើតឡើងមុនពេលដំណាក់កាលដែលអង្គជំនុំជម្រះសម្រេចថា គាត់មិនមានសម្បទាចូលរួមសវនាការបាន។

សាក្សីឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ប្រសិនបើលោកស្រីអាចឆ្លើយបាន នៅចាំសំណួរ។

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** ចាស ខ្ញុំអាចឆ្លើយបាន។ ខ្ញុំជំនាន់នោះ ខ្ញុំអត់ដឹងថាតើពីណាឲ្យបញ្ជាឲ្យយកប្តីខ្ញុំ ឬអត់ដឹងទេ។ ប៉ុន្តែ បងស៊្វ គាត់ប្រាប់ខ្ញុំថា អង្គការឲ្យយកបីនាក់មកពីស្រុកបារាំងហ្នឹងទៅ។ បងស៊្វ គាត់ថា កុំឲ្យខ្ញុំនិយាយប្រាប់ពីណា ប៉ុន្តែ អៀង ធីរិទ្ធ គាត់ទៅជួបបង ជួបអង្គការ ព្រោះខ្ញុំមិនដឹងថាបងណា បងមិនដឹងអ្នកណា ប៉ុន្តែខ្ញុំពេលនោះ ខ្ញុំសង្ស័យថា ប៉ុល ពត ជាង នួន ជា ព្រោះខ្ញុំមិនដឹងថា អ្នកណាបងអង្គការហ្នឹង មានប៉ុន្មាននាក់ ហើយអ្នកណាមុខងារអី ខ្ញុំអត់ស្គាល់ច្បាស់ ខ្ញុំអត់ដឹងទេ។ ដូច្នេះ បងស៊្វ គាត់ថា បងភា គាត់ទៅសុំបង ដើម្បីឲ្យទុកប្តីខ្ញុំ ព្រោះខ្ញុំជាប្អូនរបស់ ធុច រិន ហើយខ្ញុំទម្ងន់ហើយ។ គេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពីរនាក់ការផ្សេងទៀត គេអត់ទម្ងន់ទេ ប៉ុន្តែខ្ញុំទម្ងន់។ ដូច្នេះ មីងភា នោះគាត់ទៅសុំបងឲ្យទុកខ្ញុំ ឲ្យទុកប្ដីខ្ញុំ។ ដូច្នេះលើកទី១ហ្នឹង ប្ដីខ្ញុំនៅ គេអត់យកទេ ប៉ុន្តែពីរនាក់គាត់បាត់ខ្លួនហើយ។ បន្ទាប់មក ប្ដីខ្ញុំគេដកចេញពីកន្លែងផលិតថ្នាំ អត់ឲ្យធ្វើការនៅនុ៎ងទេ ឲ្យមកនៅធ្វើការជាមួយផ្ទាល់របស់ មីងភា ជាអ្នកចាត់ចែងសំបុត្រ ធ្វើដូចជាម្នាក់មួយដែលចេញទៅបាត់នោះ ម្នាក់ដែលគ្នាគាត់បីនាក់ហ្នឹង ម្នាក់ដែលធ្វើការផ្ទាល់សំបុត្រស្នាមអីហ្នឹង ឲ្យមកនៅធ្វើការហ្នឹងវិញ។ ទិញសំបុត្រ--

[១៥:៤៣:០២]

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារង--

**លោកស្រី ធុច ស៊ីថន៖**

**ឆ៖** ដល់លើកទី២ បាន--។ មានបញ្ហាបន្តិច សុំទោស ខ្ញុំអត់ស្ងួវឮពីខាងស្រុកខ្មែរ។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនដោយសារមានបញ្ហាបច្ចេកទេស។

**លោកស្រី ធុច ស៊ីថន៖**

ចាស មានបញ្ហារូប--

**ប្រធានអង្គជំនុំ៖**

បាទៗ មានបញ្ហា--

**លោកស្រី ធុច ស៊ីថន៖**

-- បច្ចេកទេស ចាស រូបក៏អត់ឃើញ។ ចាស អរគុណ។

[១៥:៤៣:៤០]

*(មានបញ្ហាបច្ចេកទេស)*

[១៥:៥៦:៥១]

**ប្រធានអង្គជំនុំ៖**

បាទ ហើយដោយសារបញ្ហាបច្ចេកទេសសោតទស្សន៍ អង្គជំនុំជម្រះមិនអាចជម្នះបញ្ហានេះបានទេ។ សវនាសការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការ

សវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅស្អែក ថ្ងៃអង្គារ ទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើ សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី2-TCCP-223នៅពេលព្រឹក ហើយនិងបន្តស្តាប់សក្ខីកម្ម សាក្សី ធុច ស៊ីថន នៅរសៀលតាមប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង សូមភាគីជ្រាប និងអញ្ជើញ ចូលរួមបានតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកស្រី ធុច ស៊ីថន សវនាការស្តាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជា សាក្សីនៅថ្ងៃនេះមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកផ្តល់សក្ខីកម្មនៅ ថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងដដែល ដែលត្រូវនឹងម៉ោងមួយ ដប់--

**លោកស្រី ធុច ស៊ីថន៖**

ចាស ម៉ោងដដែលចាស។

**ប្រធានអង្គជំនុំ៖**

បាទៗ ម៉ោងដប់បី និងសាមសិបនាទី នៅ--

**លោកស្រី ធុច ស៊ីថន៖**

ដូច្នេះស្អែក?

**ប្រធានអង្គជំនុំ៖**

បាទៗ ស្អែកនៅម៉ោងដដែលណ៎ា។ ត្រូវនឹងម៉ោងមួយ--

**លោកស្រី ធុច ស៊ីថន៖**

ចាស លោកប្រធាន ចាស។

**ប្រធានអង្គជំនុំ៖**

បាទៗ កន្លះរសៀលម៉ោងនៅកម្ពុជា។

បាទ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរ--

**លោកស្រី ធុច ស៊ីថន៖**

ចាសៗ អរគុណ។

**ប្រធានអង្គជំនុំ៖**

--ឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់

មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៨ នាទី)*